គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
អាស័យដ្ឋាន ផ្ទះ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទការិយាល័យ: ០២៣ ៨៨៤ ១៥០ ទូរសារ: ០២៣ ៨៨៣ ៧៥០

## របាយការណ៍

# ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖
# សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រី
# ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន



ខែកុម្ភៈ ឆ្នាំ២០១៦

# របាយការណ៍




## ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖

## សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រី

## ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន



ខែកុម្ភៈ ឆ្នាំ២០១៦

# មាតិកា


បុព្វកថា....4

សេចក្តីផ្តើម....6

I. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី....12

១. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន....12

តារាងទី១ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស....12

១.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី....14

តារាងទី២ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី....14

តារាងទី៣ ៖ ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្មគិតជាភាគរយ....15

តារាងទី៤ ៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្រ....16

បុរសនៃគណបក្សនីមួយៗ....16

តារាងទី៥៖ ចំនួនចុះបេសកកម្មនៃតំណាងរាស្ត្រស្ត្រីម្នាក់ៗ....17

២ សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (Women Parliamentarian Caucus)....19

សមាជិការដ្ឋសភា....19

៣. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបញ្ហាស្ត្រី និងកុមារ....23

តារាងទី៦៖ កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់នីតិកាលទី៥ (២០១៣-២០១៨)....23

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា....25

គោលការណ៍គ្រឹះនៃកម្មវិធីនយោបាយ....25

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា....26

II. ការសិក្សាលើក្រុមគោលដៅ ស្តីពី ការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ....31

សង្កាត់ក្នុងការបំពេញកិច្ចការងារនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល....31

១. ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ............................31
១.១. ព័ត៌មានទូទៅរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ............................31
ក្រាហ្វិកទី១ ............................32
១.២. ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ ............................32
ក្រាហ្វិកទី២ ............................33
១.៣. តួនាទីរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ............................33
ក្រាហ្វិកទី៣ ............................33
១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ............................34
ក្រាហ្វិកទី៤ ............................34
២. ស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន ............................34
២.១. ការរើសអើងស្ត្រី ............................34
២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ..34
២.១.២. អាកប្បកិរិយាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបំពេញកិច្ចការជាមួយស្ត្រី ..........35
ក្រាហ្វិកទី៥ ............................35
២.២. ការទទួលបានភារកិច្ចការងារ សិទ្ធិអំណាចពេញលេញរបស់ស្ត្រីតាមច្បាប់ ............................36
២.២.១. ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្ត្រីរបស់ខ្លួន.......36
ក្រាហ្វិកទី៦ ............................36
២.២.២. តើនៅតំបន់របស់លោកស្រី នាងកញ្ញា ធ្លាប់ដឹងថា មានគេបញ្ឈប់សមាជិកស្ត្រក្រុមប្រឹក្សាឃុំ សង្កាត់ដែរឬទេ? ............................37
២.៣.២. ការចុះចូលគណបក្សផ្សេងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ............................37
២.៣. ការបំពេញការងារទាក់ទងនឹងស្ត្រី និងកុមារ និងភាពសកម្មរបស់ស្ត្រី ............................37
២.៤ . ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ............................38
២.៤.១. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ ............................38
២.៤.២. ការបញ្ចេញមតិយោបល់ ឬ សំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំ............38
តារាងទី៧៖ ............................39
២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអង្គប្រជុំ.............40
តារាងទី៨៖ សំណើ និងយោបល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងអង្គប្រជុំ ................40
និងដោះស្រាយ ............................40

៣. ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់.....41
តារាងទី៩៖ ថវិកាសរុបប្រចាំឆ្នាំ.....41
៣.១. តម្លាភាពថវិកា.....42
៣.២. ការដកថវិកា.....43
ក្រាហ្វិកទី៧.....43
៤. ករណីសិក្សា.....45
៤.១ «សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន».....45
ករណីសិក្សាទី១.....45
ករណីសិក្សាទី២.....48
៤.២. «ភាពបរាជ័យរបស់ស្ត្រីបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន».....52
ករណីសិក្សាទី៣.....52
III. ចំនួនស្ត្រីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ (ស្ថិតិ និងតួនាទី).....55
១. ព្រឹទ្ធសភា.....55
២. រដ្ឋសភា.....55
៣. រដ្ឋាភិបាល.....56
៤. តុលាការ.....57
៥. ថ្នាក់ក្រោមជាតិ.....57
៦. ក្រុមប្រឹក្សាឃុំ សង្កាត់.....58
IV. សេចក្តីសន្និដ្ឋាន និងសង្ខេប.....59
ផ្នែកឧបសម្ព័ន្ធ.....62
ផ្នែក.....62
ឧបសម្ព័ន្ធ.....62

# បុព្វកថា

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា "ខុមហ្វ្រែល"** ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមគោលការណ៍ កសាងសមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ ប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។ បន្ថែមពីលើនេះទៀត ការមានគណនេយ្យភាពរបស់គណបក្សជាប់ឆ្នោត និងមន្ត្រីជាប់ឆ្នោតក្នុងការបំពេញតាមការសន្យារបស់ខ្លួន ការលើកស្ទួយ ការការពារការចូលរួមក្នុងការសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញនូវតួនាទី ភារកិច្ច និងការទទួលបានសិទ្ធិអំណាចពេញលេញរបស់ស្ត្រីជារឿងសំខាន់បំផុតក្នុងអភិក្រមប្រជាធិបតេយ្យ ។

របាយការណ៍ស្តីពី *« ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ ៖ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន »* គឺជាទម្រង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់តំណាងជាប់ឆ្នោតស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ និងក្នុងដំណើរការសម្រេចចិត្ត ជាពិសេស ការតាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងរយៈពេល ១ឆ្នាំ កន្លងទៅនេះ។

របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ សភា និងតំណាងរាស្ត្រស្ត្រីក្នុងអំឡុងពេលបំពេញការងារទាក់ទងនឹងសកម្មភាព និងគោលបំណងរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋានតាមមណ្ឌលខេត្ត ក្រុងនានា ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរសនៃគណបក្សនីមួយៗ សកម្មភាពរបស់សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី ។ បន្ថែមលើនេះទៀត របាយការណ៍នេះក៏បានបង្ហាញផងដែរ អំពីសមិទ្ធផលចម្បងៗ និងការប្រឈមក្នុងការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា រួមទាំងការប្រែប្រួលចំនួនសមាជិកសភាស្ត្រីនៅក្នុងរដ្ឋសភាផងដែរ ។ ម្យ៉ាងទៀត របាយការណ៍នេះ ក៏ផ្តល់នូវលទ្ធផលនៃការសិក្សាលើក្រុមគោលដៅស្តីពី ការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញ

កិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល និងករណីសិក្សា៣ ព្រមទាំងចំនួនស្ត្រីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ផងដែរ។

**ខុមហ្វ្រែល** សង្ឃឹមថា របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយនេះ ជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសមន្ត្រីរដ្ឋាភិបាល សមាជិកសភា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរបស់ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។

តាំងនាមឲ្យខុមហ្វ្រែល យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយដូចជា៖ **Norwegian People's Aid (NPA), Oxfam, Daikonia, Foundation Open Society Institute (FOSI) and Canada Fund** ។

ជាពិសេស សូមថ្លែងអំណរគុណចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដូចជា **លោកស្រី សឺនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍វិភាគនេះ ។ លោកស្រីក៏ជាអ្នកដឹកនាំក្រុមការងារ ដូចជា **លោក នាង សុវណ្ណ** និង**អ្នកសង្កេតការណ៍ស្ត្រី** ដែលខិតខំអនុវត្តតាមផែនការសកម្មភាពដើម្បីប្រមូលទិន្នន័យ និងរចនាបថរបាយការណ៍នេះ ដោយមានការ**គាំទ្រពីក្រុមការងាររបស់ខុមហ្វ្រែល ផ្នែកអង្កេត និងលេខាធិការខុមហ្វ្រែលទាំង២៥ខេត្ត ក្រុង រាជធានី** ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោក គល់ បញ្ញា និងលោក គីម ឈន** ដែលបានផ្តល់មតិយោបល់ល្អៗធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦

**នាយកប្រតិបត្តិខុមហ្វ្រែល**

**គល់ បញ្ញា**

# សេចក្តីផ្តើម

យោងតាមលទ្ធផលនៃការអនុវត្តន៍ការងារលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា និងផ្អែកតាមការសិក្សាស្រាវជ្រាវនៅក្នុងពិភពលោក ភស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់ថា ការចូលរួម**ស្របច្បាប់ និងពេញលេញ**របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចអាចធ្វើឲ្យគោលនយោបាយ ច្បាប់ និងកម្មវិធីនានាកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនទាំងអស់ ជាពិសេសលើបញ្ហាសុខុមាលភាពគ្រួសារ និងសង្គម ដែលជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយភាពក្រីក្រឈានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព[1] ។

ដូច្នេះ ការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងស្ត្រីជាប់ឆ្នោតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន គឺជារបៀបវារៈសំខាន់បំផុតដែលត្រូវស្វែងយល់ និងឃ្លាំមើលដោយយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ប្រយោជន៍លើកស្ទួយ ការពារការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ រួមទាំងការទទួលបាននូវសិទ្ធិអំណាចពេញលេញរបស់ស្ត្រី ។

របាយការណ៍ឃ្លាំមើលរបស់ខុមប្រែហ្វលប្រចាំឆ្នាំ២០១៥នេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រផ្អែកលើការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាព និងការងាររបស់តំណាងស្ត្រីជាប់ឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការបំពេញការងាររបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងកម្មវិធីនយោបាយស្តីពីបញ្ហាស្ត្រី និងកុមារ ។

សំណួរចំបងគឺ *តើស្ត្រីជាប់ឆ្នោតទាំងនោះធ្វើការបានលទ្ធផលយ៉ាងណាខ្លះ? មានការរើសអើងដែរឬទេ? តើអ្វីជាការប្រឈមរបស់ពួកគាត់? និងមូលហេតុអ្វី? ថាតើការការពារការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញ និងទទួលបាននូវតួនាទី ភារកិច្ចស្របតាមច្បាប់ និងទទួលបានសិទ្ធអំណាចពេញលេញបានកម្រិតណា? តើអ្វីខ្លះជាការបំពេញរបស់រដ្ឋាភិបាលស្តីពីគោលនយោបាយទាក់ទងនឹងស្ត្រី និងកុមារ?*

[1] សុន្ទរកថារបស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយសភា ព្រឹទ្ធសភា និងអធិការកិច្ចក្នុងពិធីបើកវេទិកា ជាតិ ស្តីពី ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

សម្រាប់ឆ្នាំទី២ នីតិកាលទី៥(ឆ្នាំ២០១៣-២០១៨)នៃរដ្ឋសភា មានគណបក្សនយោបាយចំនួនពីរជាប់ឆ្នោត មានអាសនៈនៅក្នុងរដ្ឋសភាជាតិគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ។ ដោយឡែក អាណត្តិទី៣ (ឆ្នាំ២០១២-២០១៧)នៃក្រុមប្រឹក្សាឃុំ សង្កាត់ មានគណបក្សចំនួន៥បានជាប់ឆ្នោតគឺ គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សសិទ្ធិមនុស្ស ។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពី សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា ក្នុងរយៈពេលចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែធ្នូ ឆ្នាំ២០១៥ មានតំណាងរាស្ត្រចំនួន**៩៤នាក់** (ស្ត្រី១៧នាក់ និងបុរស ៧៧នាក់) ក្នុងនោះ៤២នាក់មកពីគណបក្សប្រជាជនកម្ពុជា មាន**ស្ត្រី១២នាក់** និង៥២នាក់មកពីគណបក្សសង្គ្រោះជាតិ ក្នុងនោះមាន**ស្ត្រី៥នាក់**)ក្នុងចំណោមតំណាងរាស្ត្រ ១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១១០៧លើក ឆ្នាំ២០១៥** (គណបក្សប្រជាជនកម្ពុជាចំនួន ២៨៧លើក ស្មើនឹង ២៥,៨៤% និងគណបក្សសង្គ្រោះជាតិចំនួន ៨២១លើក ស្មើនឹង ៧៤,១៦%) ។ ចំនួននេះ**ថយចុះ**ចំនួន **១៦៧លើក** ពី **១២៧៤លើក** ឆ្នាំ២០១៤ មកត្រឹម **១១០៧លើក** ឆ្នាំ២០១៥ ។

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **តិចជាង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៧០,៨៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៧នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ តិចជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន ៧៧,៧៧% ស្មើនឹង៧៧នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម**បានថយចុះ** ពី៨៤%ឆ្នាំ២០១៤ មកត្រឹម ៧០,៨៣%ឆ្នាំ២០១៥ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មមានការ**កើនឡើងតិចតួចបំផុត** គឺពី ៧៦,៥៣%ឆ្នាំ២០១៤ ទៅ ៧៧,៧៧%ឆ្នាំ២០១៥ ។

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង១៧នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន ២៥០លើក ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន ១៩៧លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន ១៧លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សចំនួន១៧លើក និងការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលចំនួន១២លើក ព្រមទាំងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា មាន៧លើក* ។ ចំនួនសកម្មភាពនេះមានការ**កើនឡើង**បន្តិចចំនួន **១២លើក** ពី **២៣៨លើក** ឆ្នាំ២០១៤ ទៅ **២៥០លើក** ឆ្នាំ២០១៥ ។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**១៩៧លើក (៧៨,៨០%)** ជាមួយនឹងការចុះ*

*អន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ* ***៧លើក (២,៨០%)****ប៉ុណ្ណោះ។* តួលេខនេះ បង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានការ****កើនឡើង****ចំនួន****៧៥លើក*** *ពី ១២២លើកឆ្នាំ២០១៤ ទៅ ១៩៧លើកឆ្នាំ២០១៥ ខណៈដែលសកម្មភាពចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ មានការ****ថយចុះ****ទៅវិញ ពី ១២លើក ឆ្នាំ២០១៤ មកត្រឹមតែ ៧លើក ឆ្នាំ២០១៥ ។*

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានចុះបេសកកម្មមានចំនួន **៧០,៥៩%** (១២នាក់ក្នុងចំណោម១៧នាក់) **ច្រើនជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ**៥៨,៨២%** (៣០នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** គឺពី ៨៣,៣៣% ឆ្នាំ២០១៤ មកត្រឹម ៧០,៥៩% ឆ្នាំ២០១៥ ។ រីឯភាគរយអ្នកតំណាងរាស្ត្របុរសក៏មានការ**ថយចុះដែរ** ពី ៧០% ឆ្នាំ២០១៤ មកត្រឹម ៥៨,៨២%ឆ្នាំ២០១៥ ។

ផ្ទុយទៅវិញ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៧១,៤៣%** (៥នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួនដល់ទៅ**៩៧,៩២%** (៤៧នាក់ក្នុងចំណោម៤៨នាក់) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** ពី ៨៥,៧១% ឆ្នាំ២០១៤ មកត្រឹម៧១,៤៣% ឆ្នាំ២០១៥ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសមានការ**កើនឡើងខ្ពស់**គួរឲ្យកត់សម្គាល់ ពី៨៣,៣៣% ឆ្នាំ២០១៤ ទៅ ៩៧,៩២% ឆ្នាំ២០១៥ ។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានក្នុងឆ្នាំ២០១៥ តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **តិចជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១២នាក់ បានធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួនតែ៨៥លើក គឺមានការ**ថយចុះជាងពាក់កណ្តាល**បើធៀបនឹងឆ្នាំ២០១៤ មានចំនួន១៥នាក់ បានធ្វើសកម្មភាពនៅមូលដ្ឋានចំនួន១៨២លើក ។ ផ្ទុយទៅវិញ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៥នាក់ បានខិតខំធ្វើសកម្មភាពនៅមូលដ្ឋានដល់ទៅ ១៦៥លើកក្នុងឆ្នាំ២០១៥ គឺ**កើនឡើងបីដង**បើធៀបនឹងឆ្នាំ២០១៤ មានចំនួន៦នាក់ បានតែ៥៦លើកប៉ុណ្ណោះ ។

ការ**ថយចុះ**ចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេស **តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា**ក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា *(ទី១)តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាខ្វះកិច្ចសហការក្នុងការផ្តល់ព័ត៌មាន អំពីសកម្មភាពរបស់ខ្លួនទាំងការចុះមូលដ្ឋាន និង*

*សកម្មភាពនៅរដ្ឋសភា (ទី២)តំណាងរាស្ត្រមួយចំនួនមិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងមានការយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះរួមមាន មន្ត្រីអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាពច្រើនហើយ* និង*(ទី៣)ការិយាល័យតំណាងរាស្ត្របំពេញការងាររបស់ខ្លួនមិនបានពេញលេញ* ។ ដោយឡែក សកម្មភាព **តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ**មានការ**កើនឡើង** ក៏ព្រោះតែមិនសូវមានសកម្មភាពការងារចំពោះកិច្ចនៅរដ្ឋសភា មានបញ្ហាអំពីការដកតំណែង ដកអភ័យឯកសិទ្ធិអ្នកដឹកនាំនៃតំណាងរាស្ត្ររបស់ខ្លួន និងបានធ្វើ ពហិការមិនចូលកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋានបានច្រើន[2] ។

ឆ្នាំ២០១៥ នៅឆ្នាំទី២ (ចន្លោះឆ្នាំ២០១៤-ឆ្នាំ២០១៥)ចំនួនអ្នកតំណាងរាស្ត្រស្ត្រីបន្ត**ធ្លាក់ចុះ**មកត្រឹម២៤នាក់ ស្មើនឹង ១៩,៥១% ក្នុងចំណោមសមាជិកសភា១២៣នាក់ ក្នុងនោះគណបក្សប្រជាជនកម្ពុជាចំនួន១៧នាក់ ស្មើនឹង ១៣,៨២% និងគណបក្សសង្គ្រោះជាតិចំនួន៧នាក់ ស្មើនឹង ៥,៦៩% ។ ការបន្តធ្លាក់ចុះអ្នកតំណាងរាស្ត្រស្ត្រីនេះ ដោយសារតែសភាជាតិពុំមានគោលនយោបាយលើកកម្ពស់ស្ត្រីនៅក្នុងស្ថាប័នកំពូលមួយនេះ ដើម្បីរក្សាការពារចំនួនដែលមានស្រាប់ និងក្នុងការបង្កើនចំនួនតំណាងរាស្ត្រស្ត្រី ខណៈដែលការអនុវត្តរបស់ស្ថាប័ននេះគឺដើរស្របតាមខ្សែបន្ទាត់នយោបាយរបស់គណបក្សតែប៉ុណ្ណោះ ។ ជាក់ស្តែង **លោកជំទាវ ចែម សាវៃ** ជាតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានសុំលាលែងពីតំណែងដោយសារមានជំងឺ និងមានការសំរេចឲ្យលាលែងពីតំណែងដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ ។ ជាមួយគ្នានេះដែរ រដ្ឋសភាបានប្រកាសសុពលភាពអ្នកតំណាងរាស្ត្រថ្មីជំនួស**លោកជំទាវ ចែម សាវៃ** គឺ **ឯកឧត្តម កែវ ពិសិដ្ឋ** មកពីគណបក្សប្រជាជនកម្ពុជា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ ។ ការណ៍នេះ បង្ហាញឲ្យឃើញថា អ្នកដឹកនាំសភាជាតិមិនមានការយល់ដឹងអំពីយេនឌ័រ ឬរំញោចយេនឌ័រ (Gender Sensitive) និងពុំមានការប្តេជ្ញាចិត្តខ្ពស់ដូចស្ថាប័ននីតិប្រតិបត្តិ ដែលបានកំណត់ចំនួនជាក់លាក់នៅក្នុងគោលនយោបាយរបស់ខ្លួន *«ត្រូវធានាក្របខណ្ឌពី២០% ទៅ ៥០%ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មីជាស្ត្រី និងដាក់ស្ត្រីជំនួសមន្ត្រីរាជការណាដែលចូលនិវត្តន៍*[3] *»* ដើម្បីអនុវត្ត និងខិតខំលើកស្ទួយដល់ការចូលរួមរបស់ស្ត្រី ក្នុងគោលបំណងធ្វើឲ្យមានសមភាពយេនឌ័រនៅកម្ពុជាស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

ចំណែកឯ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ មានការកើនឡើងបន្តិចចំនួន **២០៥១នាក់ស្មើនឹង ១៧,៨៩%** ក្នុងចំណោម ១១ ៤៥៩នាក់ ក្នុងឆ្នាំ២០១៥នេះ គឺ កើនមេឃុំ ចៅសង្កាត់ជាស្ត្រី ចំនួន **៦,៦១% ស្មើនឹង ១០៨នាក់** ដែលឆ្នាំ២០១៤ មានតែ ៩៥នាក់ប៉ុណ្ណោះ ។ ការកើនឡើងនេះ ដោយសារតែប្រធានក្រុមប្រឹក្សាជាបុរសខ្លះស្លាប់ ខ្លះទៀតលាលែងពីតួនាទីដោយសារមានជំងឺមិនអាចធ្វើការបាន ឯខ្លះទៀតចាស់ខ្លាំងពេ

[2] សេចក្តីប្រកាសព័ត៌មានរបស់ខុមហ្វ្រែល ស្តីពី «ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២នៃនីតិកាលទី៥» កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

[3] ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទវេទិកាជាតិស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ។

ក។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានចំនួនតិចក្នុងមុខតំណែងធ្វើសេចក្តីសម្រេចសំខាន់មួយនេះ ថ្វីបើមានការកើនឡើងបន្តិចក្នុងឆ្នាំ២០១៥នេះក៏ដោយ ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា [Cambodian Millennium Development Goals (CMDG)]ទាក់ទងនឹងការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយត្រូវបានបរាជ័យ ។ ជាក់ស្តែងឆ្នាំ២០១៥ តំណាងរាស្ត្រស្ត្រីមានចំនួនតែ ១៩,៥១% និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១៧,៨៩% ដែលCMDG បានកំណត់ថា នៅឆ្នាំ២០១៥ *«មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិយ៉ាងតិច ៣០% និងថ្នាក់ឃុំ សង្កាត់ ២៥%»* ។ ការពុំសម្រេចបានតាមគោលដៅនេះ មូលហេតុចំបងដោយសារ ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរទាំងនៅក្នុងគណបក្សនយោបាយ និងនៅក្នុងច្បាប់បោះឆ្នោតក្នុងការកំណត់ចំនួនស្ត្រីច្បាស់លាស់សម្រាប់ការឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត បើទោះបីមានការបង្ហាញពីភាពរីកចម្រើនខ្លះក៏ដោយ ។

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុរនៅទូទាំង២៤រាជធានី ខេត្តទៅលើការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ឆ្នាំទី២ ក្នុងឆ្នាំ២០១៥ទាក់ទងនឹង***ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និង តួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួល បានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន*** ជាលទ្ធផលបង្ហាញថា ម្ចាស់ឆ្នោត***ពេញចិត្តខ្លះ****ចំនួន៣០,៦៧% (២០៨នាក់)* ដែលជាភាគរយខ្ពស់ជាងគេ ។ ភាគរយខ្ពស់បន្ទាប់ គឺ***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច*** *ចំនួន២៧,៦៣%(១២០នាក់)* និង***ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល*** *ចំនួន២០,៦១%(១៨៦នាក់)* ។ រីឯ ភាគរយទាបជាងគេ គឺ ***ពេញចិត្តច្រើន*** *ចំនួន១១,៣២%(១២៧នាក់)* និង***ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង****ចំនួនតែ ៨,១៩% (៧២នាក់)* ប៉ុណ្ណោះ ។ តួលេខនេះ បង្ហាញឲ្យឃើញថា ម្ចាស់ឆ្នោតនៅពុំទាន់ពេញចិត្តនៅឡើយចំពោះរដ្ឋាភិបាលក្នុងការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានពិតប្រាកដ ។

ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយបើទោះបីមានការថយចុះខ្លះក៏ដោយ ។ ជាក់ស្តែង បុរសក្រុមប្រឹក្សាឃុំ សង្កាត់នៅតែរើសអើង និងមិនចង់សហការជាមួយស្ត្រី និងមានការរិះគន់ចំពោះស្ត្រីនៅឡើយ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការរើសអើងមានការថយចុះគឺពី១៩,៣៥% ឆ្នាំ២០១៤ មកត្រឹម ១២,១៩% ឆ្នាំ២០១៥ ។

ចំណែកឯការរើសអើងទាក់ទងនឹងការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទៅសមាជិកស្ត្រីស្របតាមតួនាទីរបស់ខ្លួននោះ របាយការណ៍ខុមហ្វ្រែលរកឃើញថា ប្រធានក្រុមប្រឹក្សាបានប្រគល់តែភារកិច្ចការងារខ្លះៗប៉ុណ្ណោះជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការរើសអើងប្រគល់តែភារកិច្ចខ្លះៗនេះ មានការថយ ពី ១៦,១២% ឆ្នាំ២០១៤ មកត្រឹម ៩,៧៥%ឆ្នាំ២០១៥ ។

ទោះបីជាយ៉ាងណាក៏ដោយតាមការសិក្សា ៨២,៩២%បានការគាំទ្រ និងលើកទឹកចិត្តពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រីដោយយល់ថា ស្ត្រីជាដៃគូដ៏សំខាន់មិនអាចខ្វះបាន ស្ត្រីធ្វើការងារសម្រេចបានដូចបុរសដែរ ។ ចំណែកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួនឯងបានប្រើប្រាស់សក្តានុពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានា បើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ។

ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ ។

ក្នុងចំណោម២៥ឃុំ មាន **១៧ឃុំ**មានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ។ ឯ **១០ឃុំ**ទៀតមានការ**ពិបាក**ក្នុងការដកថវិកាពីរតនាគារ ការទទួលបានថវិកានៅមានភាពយឺតយ៉ាវ និងស្មៀនមិនបើកថវិកាឲ្យគ្រប់ចំនួនតាមគំរោង ។ មាន២ឃុំ សង្កាត់ក្នុងចំណោម២៥ឃុំ សង្កាត់បានផ្តល់ចម្លើយផ្ទុយគ្នា ជាក់ស្តែង *១ឃុំនៅសង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ* ស្ត្រីសមាជិកក្រុមប្រឹក្សាសង្កាត់ ២នាក់មកពីគណបក្សប្រជាជនកម្ពុជា បានឆ្លើយផ្ទុយគ្នា ម្នាក់ថាពិបាក ម្នាក់ទៀតថាងាយស្រួលដក និង*១ឃុំទៀត នៅឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង* មានស្ត្រីសមាជិកក្រុមប្រឹក្សាឃុំ ២នាក់ ឆ្លើយចំលើយផ្ទុយគ្នាដែរ ម្នាក់មកពីគណបក្សសង្គ្រោះជាតិ ឆ្លើយថាពិបាកដក ឯម្នាក់ទៀតមកពីគណបក្សប្រជាជនកម្ពុជា ឆ្លើយថា ងាយស្រួលដក ។

# I. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី

## ១. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន

តារាងទី១ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស

| គោលបំណង នៃការចុះមូលដ្ឋាន ទាំង១១០៧លើក របស់អ្នកតំណាងរាស្ត្រ ទាំងស្ត្រី-បុរសចំនួន៩៤នាក់ | គណបក្សនយោបាយ | | | | សរុប |
|---|---|---|---|---|---|
| | ៤២នាក់ | | ៤៩នាក់ | | ៩៤នាក់ |
| | ស្ត្រី ១២ នាក់ | បុរស ៣០ នាក់ | ស្ត្រី ៥ នាក់ | បុរស ៤៧ នាក់ | ស្រី ១៧នាក់ ប្រុស ៧៧នាក់ |
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធផលនានា | ៥៦ លើក | ១៣៧ លើក | ១៩១ លើក | ៣៨៨ លើក | ៧២២ លើក ៦៥,២២% |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៨ លើក | ២៦ លើក | ៩ លើក | ១១១ លើក | ១៥៤ លើក ១៣,៩១% |
| ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | ១២ លើក | ២៨ លើក | ៥ លើក | ១០៥ លើក | ១៥០ លើក ១៣,៥៥% |
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ៤ លើក | ៥ លើក | ៨ លើក | ៣៥ លើក | ៥២ លើក ៤,៧០% |
| ការអន្តរាគមន៍ និង ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ | ៥ លើក | ៥ លើក | ២ លើក | ១៧ លើក | ២៩ លើក ២,៦២% |

| | | | | | |
|---|---|---|---|---|---|
| សរុបគោលបំណងតាមគណបក្ស | ៨៥ លើក | ២០១ លើក | ១៦៥ លើក | ៦៥៦ លើក | ១១០៧ លើក ១០០% |
| **សរុបរួម** | ២៨៦លើក ២៥,៨៤% | | ៨២១ លើក ៧៤,១៦% | | |

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពី សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមរយៈការចុះសង្កេតដោយផ្ទាល់ ប្រព័ន្ធផ្សព្វផ្សាយ ការិយាល័យអ្នកតំណាងរាស្ត្រតាមមណ្ឌលខេត្ត និងតាមរយៈស្នាក់ការគណបក្សនយោបាយនៅតាមបណ្តាខេត្តឃើញថា ក្នុងរយៈពេលចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែធ្នូ ឆ្នាំ២០១៥ មានតំណាងរាស្ត្រចំនួន**៩៤នាក់** (៤២នាក់មកពីគណបក្សប្រជាជនកម្ពុជា ក្នុងនោះមាន**ស្ត្រី១២នាក់** និង៥២នាក់មកពីគណបក្សសង្គ្រោះជាតិ ក្នុងនោះមាន**ស្ត្រី៥នាក់**)ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១១០៧លើក** (គណបក្សប្រជាជនកម្ពុជាចំនួន ២៨៧លើក ស្មើនឹង ២៥,៨៤% និងគណបក្សសង្គ្រោះជាតិចំនួន ៨២១លើក ស្មើនឹង ៧៤,១៦%) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ចំនួននេះ**ថយចុះ**ចំនួន **១៦៧លើក** ពី ១២៧៤លើក ឆ្នាំ២០១៤ មកត្រឹម ១១០៧លើក ឆ្នាំ២០១៥ ។

គ្រប់សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺបានធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន **៥** រួមមាន *(១)ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា (២)ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស (៣)ការចុះអមដំណើរថ្នាក់ដឹកនាំ (៤)ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការស៊ីវិល និង(៥)ការចុះជួយអន្តរាគមន៍ ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។*[4]

គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានាមានចំនួនដល់ទៅ*៧២២លើក (៦៥,២២%)ជាតួលេខខ្ពស់ជាងគេបំផុត* ខណៈដែលការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន*ចំនួន ១៥៤លើក (១៣,៩១%)* និងការចុះអមដំណើរថ្នាក់ដឹកនាំមាន*ចំនួន១៥០លើក (១៣,៥៥%) ជាតួលេខខ្ពស់បន្ទាប់* ។ ផ្ទុយទៅវិញ ការ*ចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋដែលជាសកម្មភាពរបស់អ្នកតំណាងរាស្ត្របានធ្វើនោះ នៅមានកម្រិតទាបបំផុតចំនួនតែ២,៦២%(២៩លើក) ប៉ុណ្ណោះ។ រីឯការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលមានចំនួន៥២លើក (៤,៧០%)ឆ្នាំ ២០១៥ បើប្រៀបធៀបឆ្នាំ២០១៤មិនមានការចូលរួមទាល់តែសោះ ។*

[4] របាយការណ៍ឃ្លាំមើលសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នីតិកាលទី៥ របស់ ខុមហ្វ្រែល ចេញផ្សាយ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

## ១.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី

<u>តារាងទី</u>២ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី

| គោលបំណងនៃការចុះមូលដ្ឋានទាំង២៥០លើក របស់អ្នកតំណាងរាស្ត្រស្ត្រី ចំនួន១៧នាក់ | គណបក្សនយោបាយ | | សរុប |
|---|---|---|---|
| | ១២ នាក់ | ៥ នាក់ | ១៧ នាក់ |
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា | ៥៦លើក | ១៤១ លើក | ១៩៧ លើក ៧៨,៨០% |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស | ៨ លើក | ៩ លើក | ១៧ លើក ៦,៨០% |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ១២ លើក | ៥ លើក | ១៧ លើក ៦,៨០% |
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ៤ លើក | ៨ លើក | ១២ លើក ៤,៨០% |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ | ៥ លើក | ២ លើក | ៧ លើក ២,៨០% |
| **សរុបគោលបំណងតាមគណបក្ស** | **៨៥ លើក ៣៤%** | **១៦៥ លើក ៦៦%** | **២៥០ លើក (១០០%)** |

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង១៧នាក់នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន ២៥០លើក ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន ១៩៧លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន ១៧លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សចំនួន១៧លើក និងការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលចំនួន១២លើក ព្រមទាំងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា មាន៧លើក* ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ចំនួនសកម្មភាពនេះមានការ**កើនឡើង**បន្តិចចំនួន **១២លើក** ពី **២៣៨លើក** ឆ្នាំ២០១៤ ទៅ **២៥០លើក** ឆ្នាំ២០១៥ ។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**១៩៧លើក (៧៨,៨០%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ **៧លើក (២,៨០%)**ប៉ុណ្ណោះ*។ តួលេខនេះ បង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានការ**កើនឡើងចំនួន៧៥លើក** ពី ១២២លើកឆ្នាំ២០១៤ ទៅ ១៩៧លើកឆ្នាំ ២០១៥ ខណៈដែលសកម្មភាពចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ មានការ**ថយចុះ** ទៅវិញ ពី ១២លើក ឆ្នាំ២០១៤ មកត្រឹមតែ ៧លើក ឆ្នាំ២០១៥ ។*

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានក្នុងឆ្នាំ២០១៥ តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **តិចជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១២នាក់ បានធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួនតែ**៨៥លើក** គឺមានការ**ថយចុះជាងពាក់កណ្តាល**បើធៀបនឹងឆ្នាំ២០១៤ មានចំនួន១៥នាក់ បានធ្វើសកម្មភាពនៅមូលដ្ឋានចំនួន១៨២លើក ។ ផ្ទុយទៅវិញ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួន៥នាក់ បានខិតខំធ្វើសកម្មភាពនៅមូលដ្ឋានដល់ទៅ **១៦៥លើក**ក្នុងឆ្នាំ២០១៥ គឺ**កើនឡើងបីដង**បើធៀបនឹងឆ្នាំ២០១៤ មានចំនួន៦នាក់ បានតែ៥៦លើកប៉ុណ្ណោះ ។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាទាំង១២នាក់នោះ ផ្តោតទៅលើគោលបំណងចុះ*សំណេះសំណាលសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាបានចំនួន ៥៦លើក ចុះអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនបានចំនួន១២លើក ចុះអន្តរាគមន៍បញ្ហានានារបស់ម្ចាស់ឆ្នោត ចំនួន៥លើក និងការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សបានចំនួន៨លើក ព្រមទាំងការចូលរួមក្នុង វេទិកាសាធារណៈរបស់អង្គការស៊ីវិលចំនួន ៤លើក*។

ដោយឡែក តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិទាំង៥នាក់នេះ បានចុះមូលដ្ឋានផ្តោតលើគោលបំណងចុះសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតបានចំនួន១៤១លើក ចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សបានចំនួន៩លើក ចុះអមដំណើរថ្នាក់ដឹកនាំចំនួន៥លើក ចុះអន្តរាគមន៍ ដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោតចំនួន២លើក និង*ចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការស៊ីវិលចំនួន៨លើក*។

តារាងទី៣ ៖ ចំនួនតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្មគិតជាភាគរយ

| តំណាងរាស្ត្របានចុះបេសកកម្ម៩៤នាក់ | | | |
|---|---|---|---|
| ស្ត្រី | % | បុរស | % |
| ១៧នាក់ | ៧០,៨៣% | ៧៧នាក់ | ៧៧,៧៧% |

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **តិចជាង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៧០,៨៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៧នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ តិចជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន ៧៧,៧៧% ស្មើនឹង៧៧នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម**ធានថយចុះ** ពី៨៤%ឆ្នាំ២០១៤ មកត្រឹម ៧០,៨៣% ឆ្នាំ២០១៥ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មមានការ**កើនឡើងតិចតួចបំផុត** គឺពី ៧៦,៥៣% ឆ្នាំ២០១៤ ទៅ ៧៧,៧៧% ឆ្នាំ២០១៥ ។

<u>តារាងទី៤</u> ៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរសនៃគណបក្សនីមួយៗ

| ឈ្មោះគណបក្ស | តំណាងរាស្ត្របានចុះបេសកកម្មធៀបនឹងចំនួនអាសនៈនៅក្នុងបក្សតាមភេទ | | | |
|---|---|---|---|---|
| ប្រជាជនកម្ពុជា | តំណាងរាស្ត្រចុះបេសកកម្ម ៤២នាក់(៦១,៧៦%) នៃ៦៨កៅអី | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ១២រូប | ៧០,៥៩% នៃ១៧កៅអី | ៣០រូប | ៥៨,៨២% នៃ៥១កៅអី |
| សង្គ្រោះជាតិ | តំណាងរាស្ត្រចុះបេសកកម្ម ៥២នាក់(៩៤,៥៤%) នៃ៥៥កៅអី | | | |
| | ស្ត្រី | %នៃសមាជិកសភាស្ត្រី | បុរស | %នៃសមាជិកសភាបុរស |
| | ៥រូប | ៧១,៤៣% នៃ៧កៅអី | ៤៧រូប | ៩៧,៩២% នៃ៤៨កៅអី |

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស របាយការណ៍ឃ្លាំមើលរបស់ខុមហ្វ្រែលរកឃើញថា ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានចុះបេសកកម្មមានចំនួន **៧០,៥៩%** (១២នាក់ក្នុងចំណោម១៧នាក់) **ច្រើនជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួន ដែលមានចំនួនតែ**៥៨,៨២%** (៣០នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** គឺពី ៨៣,៣៣% ឆ្នាំ២០១៤ មកត្រឹម ៧០,៥៩% ឆ្នាំ២០១៥ ។ រីឯភាគរយអ្នកតំណាងរាស្ត្របុរសក៏មានការ**ថយចុះដែរ** ពី ៧០% ឆ្នាំ២០១៤ មកត្រឹម ៥៨,៨២%ឆ្នាំ២០១៥ ។

ផ្ទុយទៅវិញ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៧១,៤៣%** (៥នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួនដល់ទៅ**៩៧,៩២%** (៤៧នាក់ក្នុងចំណោម៤៨នាក់) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** ពី ៨៥,៧១% ឆ្នាំ២០១៤ មកត្រឹម៧១,៤៣% ឆ្នាំ២០១៥ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសមានការ**កើនឡើងខ្ពស់**គួរឲ្យកត់សម្គាល់ ពី៨៣,៣៣% ឆ្នាំ២០១៤ ទៅ ៩៧,៩២% ឆ្នាំ២០១៥ ។

ការ**ថយចុះ**ចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេស **តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា**ក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា *(ទី១)តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាខ្វះកិច្ចសហការក្នុងការផ្តល់ព័ត៌មាន អំពីសកម្មភាពរបស់ខ្លួនទាំងការចុះមូលដ្ឋាន និងសកម្មភាពនៅរដ្ឋសភា (ទី២)តំណាងរាស្ត្រមួយចំនួនមិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងមានការយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះរួមមាន មន្ត្រីអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាពច្រើនហើយ* និង*(ទី៣)ការិយាល័យតំណាងរាស្ត្របំពេញការងាររបស់ខ្លួនមិនបានពេញលេញ* ។ ដោយឡែក សកម្មភាព **តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ**មានការ**កើនឡើង** ក៏ព្រោះតែមិនសូវមានសកម្មភាពការងារចំពោះកិច្ចនៅរដ្ឋសភា មានបញ្ហាអំពីការដកតំណែង ដកអភ័យឯកសិទ្ធិអ្នកដឹកនាំនៃតំណាងរាស្ត្ររបស់ខ្លួន និងបានធ្វើ ពហិការមិនចូលកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋានបានច្រើន[5] ។

**តារាងទី៥៖ ចំនួនចុះបេសកកម្មនៃតំណាងរាស្ត្រស្ត្រីម្នាក់ៗ**

**អក្សរកាត់គោលបំណងនៃបេសកកម្មទាំង៥គឺ ៖**

**(ក) ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា**

**(ខ) ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស**

**(គ) ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ**

---

[5] សេចក្តីប្រកាសព័ត៌មានរបស់ខុមហ្វ្រែល ស្តីពី «ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២នៃនីតិកាលទី៥» កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

(ឃ) ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល

(ង) ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា

| ល.រ | ឈ្មោះ តំណាងរាស្ត្រស្ត្រី | ឈ្មោះ គណបក្ស | រូបសញ្ញា | គោលបំណងនៃបេសកកម្ម | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | (ក) | (ខ) | (គ) | (ឃ) | (ង) | សរុប |
| ១ | កែ សុវណ្ណរតន៍ | សង្គ្រោះជាតិ | | ៧៦ | ៦ | ០ | ៤ | ២ | ៨៨ |
| ២ | ពត ពៅ | សង្គ្រោះជាតិ | | ២៧ | ៣ | ១ | ០ | ០ | ៣១ |
| ៣ | មូរ សុខហួរ | សង្គ្រោះជាតិ | | ២៣ | ០ | ០ | ២ | ០ | ២៥ |
| ៤ | ឡោក ខេង | ប្រជាជនកម្ពុជា | | ១៣ | ២ | ២ | ១ | ១ | ១៩ |
| ៥ | តែ ច័ន្ទមនី | សង្គ្រោះជាតិ | | ១១ | ០ | ៣ | ១ | ០ | ១៥ |
| ៦ | និន សាផុន | ប្រជាជនកម្ពុជា | | ៩ | ០ | ២ | ០ | ០ | ១១ |
| ៧ | កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | | ៧ | ១ | ១ | ០ | ០ | ៩ |
| ៨ | លី គឹមលៀង | ប្រជាជនកម្ពុជា | | ៦ | ០ | ១ | ០ | ០ | ៧ |
| ៩ | ត្រឹង ថាវី | ប្រជាជនកម្ពុជា | | ៤ | ២ | ០ | ០ | ០ | ៦ |
| ១០ | ជូឡុង សូមូរ៉ា | សង្គ្រោះជាតិ | | ១ | ០ | ១ | ១ | ០ | ៣ |
| ១១ | ម៉ែន សំអន | ប្រជាជនកម្ពុជា | | ០ | ០ | ៣ | ០ | ០ | ៣ |
| ១២ | ឃួន សុដារី | ប្រជាជនកម្ពុជា | | ១ | ០ | ១ | ០ | ០ | ២ |
| ១៣ | នូម សុភ័ណ | ប្រជាជនកម្ពុជា | | ២ | ០ | ០ | ០ | ០ | ២ |
| ១៤ | ឈុន សារឹម | ប្រជាជនកម្ពុជា | | ០ | ០ | ០ | ០ | ១ | ១ |
| ១៥ | បាន ស្រីមុំ | ប្រជាជនកម្ពុជា | | ០ | ០ | ០ | ០ | ១ | ១ |
| ១៦ | ស៊ុន សាភឿន | ប្រជាជនកម្ពុជា | | ០ | ១ | ០ | ០ | ០ | ១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៧ | ពៅ សារឿន | ប្រជាជនកម្ពុជា | | ១ | ០ | ០ | ០ | ០ | ១ |
| សរុប ចំនួនលើក | | | | ១៨១ | ១៥ | ១៥ | ៩ | ៥ | ២២៥ |
| គិតជា (%) | | | | ៨០ ,៤៤ | ៦,៦ | ៦,៦ | ៤% | ២,២ | ១០០ |

តារាងទី៥ បង្ហាញថា តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម**ច្រើនជាងគេបំផុត** នៅក្នុងឆ្នាំសង្កេតទី២ នេះ គឺ **លោកជំទាវ កែ សុវណ្ណរតន៍** តំណាងរាស្ត្រមណ្ឌលសៀមរាបមកពីគណបក្សសង្គ្រោះជាតិមានចំនួន **៨៨លើក** គឺ**ច្រើនជាង២ដង**បើធៀបនឹងឆ្នាំ២០១៤មានចំនួនតែ**៤០លើក**ប៉ុណ្ណោះ ។ អ្នកដែល**ច្រើនបន្ទាប់**មានចំនួន៣នាក់ ក្នុងនោះ ២នាក់មកពីគណបក្សសង្គ្រោះជាតិ និង១នាក់មកពីគណបក្សប្រជាជនកម្ពុជា ។ រីឯអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មក្នុង**កម្រិតមធ្យម**មានចំនួន៥នាក់ ក្នុងនោះ៤នាក់មកពីគណបក្សប្រជាជនកម្ពុជា និង១នាក់មកពីគណបក្សសង្គ្រោះជាតិ ។ ដោយឡែកអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មក្នុង**កម្រិតទាបជាងគេបំផុត**មានចំនួន៨នាក់ ក្នុងនោះគណបក្សប្រជាជនកម្ពុជាមានចំនួន៧នាក់ និងគណបក្សសង្គ្រោះជាតិ មានចំនួន១នាក់ ។

## ២ សភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (Women Parliamentarian Caucus)

### សមាជិការដ្ឋសភា

ក្រុមតំណាងរាស្ត្រស្ត្រីជាឧបករណ៍ដ៏មានប្រសិទ្ធភាព និងជាយន្តការមួយក្នុងចំណោមយន្តការជាច្រើនដែលប្រទេសជាច្រើនបាននិងកំពុងអនុវត្តដើម្បីអាចធ្វើឲ្យស្ត្រីពង្រឹងឥទ្ធិពលនយោបាយរបស់ខ្លួន។ ប្រទេសទាំងនេះបានប្រមូលផ្តុំតំណាងរាស្ត្រស្ត្រីមកពីគណបក្សផ្សេងគ្នារួមគ្នាជាសម្ព័ន្ធដែលមានប្រសិទ្ធភាពមួយ ដើម្បីសម្រេចគោលដៅរួម។ ក្រុមតំណាងរាស្ត្រស្ត្រីគឺអាចជួយក្នុងការនាំយកមកកាន់តែប្រសើរឡើងនូវសមភាពរវាងបុរស និងស្ត្រីនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ (ធ្វើការងារ) និងកិច្ចការរបស់សភា។ ក្រុមស្ត្រីទាំងនេះក៏នឹងអាចជួយឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងច្បាប់ពីយេនឌ័រ និងបង្កើនការយល់ដឹងអំពីសមភាពយេនឌ័រ ។ ចំណែកឯប្រទេសកម្ពុជាវិញ មិនទាន់មានយន្តការក្នុងការអនុវត្តនៅឡើយទេ។ ម្យ៉ាងវិញទៀត តំណាងរាស្ត្រស្ត្រី និងរដ្ឋសភាកម្ពុជាទាំងមូលមិនបានផ្តោតការយកចិត្តទុកដាក់ឲ្យខ្លាំងគ្រប់គ្រាន់ទៅលើបញ្ហាស្ត្រី និងកុមារនោះទេ។ នេះជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលធ្វើឲ្យបញ្ហានេះនៅបន្តកើតមាន។ ក្រោមជំនួយមនុស្សធម៌របស់ប្រជាជនណ័រវេ ផ្នែកអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែលដែលកំពុងធ្វើការលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ ដោយសហ

ការជាមួយក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិល បានធ្វើការតស៊ូមតិ និងបញ្ចុះបញ្ចូលរដ្ឋសភាដើម្បីបង្កើតក្រុមតំណាងរាស្ត្រស្ត្រី។

*"ដោយមើលឃើញពីសារៈសំខាន់របស់ក្រុមតំណាងរាស្ត្រស្ត្រី ខុមហ្វ្រែលបានលើកគំនិតនេះឡើងទៅក្រុមស្ត្រីដែលធ្វើការលើកកម្ពស់សិទ្ធិស្ត្រី រួមមាន គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន) និងក្រុមស្ត្រីដើម្បីទាំងអស់គ្នា។"* យោងតាមប្រសាសន៍របស់លោកស្រី **សឺនកេត សិរីលក្ខណ៍** ជាអ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល។

ក្នុងកិច្ចសហការជាមួយខុមហ្វ្រែល គសន និងក្រុមស្ត្រីដើម្បីទាំងអស់គ្នាបានរៀបចំផែនការដើម្បីតស៊ូមតិតាមរយៈកម្មវិធីវិទ្យុ ប្រព័ន្ធព័ត៌មានសង្គម កិច្ចប្រជុំ និងការដាក់ញត្តិដើម្បីបញ្ចុះបញ្ចូលរដ្ឋសភាកម្ពុ



ជាឲ្យអនុម័តបង្កើតក្រុមតំណាងរាស្ត្រស្ត្រីនៅក្នុងសភាជាតិ។ យោងតាមប្រសាសន៍របស់លោកស្រីសឺនកេត សិរីលក្ខណ៍។

លោកស្រីបានបញ្ជាក់បន្ថែមទៀតថា *"ដើម្បីធ្វើឲ្យមានឥទ្ធិពលកាន់តែខ្លាំងទៅលើអ្នកបង្កើតច្បាប់ ក្រុមស្ត្រីរបស់យើងបានធ្វើយុទ្ធនាការជាច្រើន រួមទាំងការជួបជាមួយអ្នកពាក់ព័ន្ធផ្សេងៗដើម្បីទទួលការគាំទ្រ។ អ្វីដែលសំខាន់ជាងនេះទៅទៀត ក្រុមរបស់យើងបានទៅជួប**លោកជំទាវ កែ សុវណ្ណរតន៍** ជាប្រធានគណៈកម្មការទី៨នៃរដ្ឋសភា និងតំណាងរាស្ត្រដទៃទៀត នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ និង**ឯកឧត្តម កឹម សុខា** ជាអនុប្រធានទី១នៃរដ្ឋសភានៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤។ ជំនួបនេះត្រូវបានពិភាក្សាអំពីឱកាសសហប្រតិបត្តិការដើម្បីលើកកំពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត និងការជជែកអំពីក្រុមតំណាងរាស្ត្រស្ត្រីក្នុងរដ្ឋសភាជាតិផងដែរ។ ក្រោយជំនួបតំណាងរាស្ត្របានគាំទ្រ និងបានសន្យាថានឹងលើកយកគំនិតនេះទៅជជែកពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា។"*



បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសង្គមស៊ីវិល និងតំណាងរាស្ត្រស្ត្រីមួយចំនួន នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ រដ្ឋសភាបានអនុម័តឲ្យមាន «ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយ

សភាស្ត្រី (Women Parliamentarian Caucus)សមាជិការដ្ឋសភា» ដែលហៅកាត់ថា «កសកនស»ជាផ្លូវការ ដោយមានសមាសភាពស្ត្រីជាតំណាងរាស្ត្រចំនួន៨រូបដែលជាក្បាលម៉ាស៊ីនដឹកនាំ ក្នុងនោះ៤រូបមកពីគណបក្សប្រជាជនកម្ពុជា និង ៤រូបទៀតមកពីគណបក្សសង្គ្រោះជាតិ និងមានសមាជិកាមកពីគណបក្សទាំងពីរដែលមានអាសនៈនៅក្នុងរដ្ឋសភា សរុបចំនួន ២៧រូប ។ *(សូមមើលឯកសារផ្លូវការនៅក្នុងឧបសម្ព័ន្ធ)*

លោកជំទាវ **មួរ សុខហួរ** ត្រូវបានតែងតាំងជាអនុប្រធានក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី បានមានប្រសាសន៍ថា *«ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី គឺពិតជាសំខាន់ដើម្បីប្រមូលសមាជិកសភាស្ត្រីជាក្រុមតែមួយនៅក្នុងរដ្ឋសភា ដោយគ្មានការរើសអើងគណបក្សនយោបាយ ប្រយោជន៍លើកស្ទួយសិទ្ធិ និងតួនាទីរបស់ស្ត្រីនៅគ្រប់កំរិត និងដើម្បីដោះស្រាយបញ្ហារបស់ស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។»* ស្របពេលជាមួយគ្នានោះដែរ តំណាងគណបក្សប្រជាជនកម្ពុជា លោកជំទាវ **ជូ ប៊ុនអេង** ដែលជារដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាប្រធាននៃលេខាធិការដ្ឋានជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បានពន្យល់ពីសារៈសំខាន់នៃក្រុមតំណាងរាស្ត្រនេះថា *«វាជារឿងល្អមួយក្នុងការបង្កើតឲ្យមានក្រុមតំណាងរាស្ត្រស្ត្រី ប៉ុន្តែត្រូវការការជជែកគ្នាក្នុងស្មារតីស្មោះត្រង់ដោយមិនគិតពីផលប្រយោជន៍គណបក្សជាធំ។»*

ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី (កសកនស) មានតួនាទី និងភារកិច្ចដូចខាងក្រោម[6]៖

- ចូលរួមផ្តួចផ្តើមគំនិតធ្វើច្បាប់ វិសោធនកម្មច្បាប់ ផ្តល់យោបល់ ឬអនុសាសន៍ និងសំដែងមតិសំដៅធ្វើឲ្យប្រសើរឡើងនូវស្ថានភាពស្ត្រី និងកុមារ ។
- តាមដាន ត្រួតពិនិត្យលើការអនុវត្តច្បាប់ យុទ្ធសាស្ត្រ គោលនយោបាយ បទដ្ឋានគតិយុត្តិ លើកអនុសាសន៍ និងចូលរួមផ្សព្វផ្សាយអប់រំបណ្តុះបណ្តាលអំពីសិទ្ធិ សមត្ថភាព និងបំណិនជីវិត ដើម្បីលើកស្ទួយឋានៈ និងតួនាទីស្ត្រីនៅក្នុងសង្គម ។
- ចូលរួមជម្រុញវប្បធម៌សន្ទនា សំដៅរួមចំណែកដល់ការស្រុះស្រួលជាតិ
- តាមដានការអនុវត្ត អនុសញ្ញា ពិធីសារអន្តរជាតិពាក់ព័ន្ធដល់បញ្ហាស្ត្រីដែលរដ្ឋសភាបានផ្តល់សច្ចាប័ន ដូចជា CEDAW ជាដើម ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមការងារស្ត្រីនៅក្នុងតំបន់ និងអន្តរជាតិក្នុងកិច្ចការដែលពាក់ព័ន្ធនឹងការលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រ ។

រយៈពេល១០ខែកន្លងមកនេះ **កសកនស** បានដំណើរការ និងមានសកម្មភាពសំខាន់ៗមួយ

[6] បទបង្ហាញរបស់លោកជំទាវ **ត្រឹង ថាវី** សមាជិការដ្ឋសភា និងជាសមាជិកនៃក្រុមសភាជាតិនៃអ្នកនយោបាយសភាស្ត្រី ក្នុងវេទិកាជាតិស្តីពី «ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ» កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

ចំនួន[7]៖

- ប្រជុំពិភាក្សារៀបចំផែនការសកម្មភាពតាមដំណាក់កាលត្រីមាស ឆមាស ប្រចាំឆ្នាំ និងបានផ្តួចផ្តើមគំនិតពិភាក្សារកវិធានការដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រី និងការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងស្ថាប័ននីតិប្រតិបត្តិ ។
- កសកនស បានរៀបចំផែនការសកម្មភាពរយៈពេលបីឆ្នាំ (ឆ្នាំ២០១៦-ឆ្នាំ២០១៨)ដាក់ជូនថ្នាក់ដឹកនាំរដ្ឋសភាពិនិត្យ ដោយបានជួបប្រជុំពិភាក្សាជាមួយតំណាងក្រសួងចំនួន៥ រួមមានក្រសួងកិច្ចការនារី ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃ ដើម្បីស្វែងយល់ និងប្រមូលទិន្នន័យព័ត៌មានពីការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពររបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ។
- កសកនស ជួបប្រជុំពិភាក្សាជាមួយគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) ស្ត្រីជាថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិ និងស្ត្រីជាថ្នាក់ដឹកនាំវ័យក្មេងមកពី៨ខេត្ត ដើម្បីសំដែងមតិពីការងាយស្រួល ការលំបាក ការប្រឈមក្នុងពេលបំពេញភារកិច្ច ។ កសកនស បានទទួលយកសំណូមពរមួយចំនួនដើម្បីលើកជាមតិយោបល់ជូនថ្នាក់ដឹកនាំរដ្ឋសភា ។
- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយអង្គការជាតិ និងដៃគូអភិវឌ្ឍន៍ដើម្បីស្វែងរកការផ្លាស់ប្តូរបទពិសោធ ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។
- ប្រជុំពិភាក្សាជាបន្តបន្ទាប់ជាមួយតំណាង UN WOMEN ក្នុងការរៀបចំផែនការ និងគោលដៅនៃកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សមភាពយេនឌ័រ ពិសេសការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្រោយឆ្នាំ២០១៥ ។
- បានចុះតាមមូលដ្ឋានក្តាប់ព័ត៌មាន ស្តីពី ស្ថានភាពស្ត្រីក្នុងសង្គម ដើម្បីពិភាក្សាលើកជាមតិយោបល់ និងផ្តល់ជាអនុសាសន៍ដល់ការជួយដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រី ។
- សមាជិកនៃកសកនសចូលរួមក្នុងវេទិកាសភាស្ត្រីក្នុងតំបន់ និងលើសកលលោកជាច្រើនមានជាអាទ៍ វេទិកាស្ត្រីស្តីពីការជម្រុញស្ត្រីចូលរួមនយោបាយ និងការធ្វើសេចក្តីសម្រេច អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការប្រែប្រួលអាកាសធាតុ បញ្ហាសុខភាពស្ត្រី និងកុមារ ។ល។
- សមាជិកនៃកសកនសចូលរួមក្នុងកិច្ចប្រជុំពិសេសក្នុងតំបន់ AIPA សហការជាមួយអន្តរសភា IPU សភានៃបណ្តាប្រទេសប្រើភាសាបារាំង APF សភាអាស៊ី APA ដែលថ្មីៗនេះក្នុងពេលដែលសភាកម្ពុជាធ្វើម្ចាស់ផ្ទះ រៀបចំមហាសន្និបាតសភាអាស៊ី APAលើកទី៨ ដែលមាន២២

[7] បទបង្ហាញរបស់លោកជំទាវ **ត្រឹង ថារី** សមាជិការដ្ឋសភា និងជាសមាជិកនៃក្រុមសភាជាតិនៃអ្នកនយោបាយសភាស្ត្រី ក្នុងវេទិកាជាតិស្តីពី «ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ» កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

ប្រទេសសមាជិក និងប្រទេសអ្នកសង្កេតការណ៍ចំនួន៨ប្រទេសចូលរួមក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រីបានដឹកនាំកិច្ចប្រជុំពិសេសរបស់សមាជិកាសភាតំបន់អាស៊ី ដើម្បីជម្រុញលើកទឹកចិត្តឲ្យសមាជិកាសភាតំបន់អាស៊ីបានចូលរួមក្នុងមហាសន្និបាតប្រចាំឆ្នាំ ដើម្បីបានរួមគ្នាគិតគូរដោះស្រាយបញ្ហាប្រឈមនានាលើស្ត្រី ។

ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាយល់ច្បាស់ថា ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយស្ថានភាពស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ មិនអាចកាត់ផ្តាច់បានពីការចូលរួមគាំទ្រពីស្ថាប័ន នីតិបញ្ញត្តិ កិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល គណបក្សនយោបាយ និងវិស័យឯកជនដែលជាកម្លាំងសរុបជួយធ្វើឲ្យសម្រេចគោលនយោបាយលើកស្ទួយសមភាពយេនឌ័រ និងធ្វើឲ្យស្ថានភាពស្ត្រីនៅកម្ពុជាមានការប្រែប្រួលទៅរកភាពល្អប្រសើរមួយកម្រិតទៀត ។

ជាមួយគ្នានេះដែរ អង្គការសង្គមស៊ីវិលមានសុទិដ្ឋិនិយមថា ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រីនឹងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងប្រទេសកម្ពុជា ដើម្បីពង្រឹងសមភាព និងដោះស្រាយបញ្ហាជាតិ ជាពិសេសបញ្ហាស្ត្រី និងកុមារ។ ក្នុងនាមយើងជាអង្គការសង្គមស៊ីវិល នឹងបន្តអង្កេត ឃ្លាំមើលការអនុវត្តគោលនយោបាយរបស់តំណាងស្ត្រីនៅក្នុងរដ្ឋសភា ជាពិសេសការបញ្ចេញមតិក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី និងការដោះស្រាយបញ្ហាអាទិភាពមួយចំនួន។ ក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិល បានត្រៀមខ្លួនរួចជាស្រេចក្នុងការសហការដោយក្តីរីករាយជាមួយក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី ប្រយោជន៍លើកតំកើងស្ថានភាពស្ត្រីឲ្យកាន់តែមានភាពល្អប្រសើរឡើង និងចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ ។

## ៣. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបញ្ហាស្ត្រី និងកុមារ

**តារាងទី៦៖ កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់នីតិកាលទី៥** (២០១៣-២០១៨)

| ល.រ | កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់នីតិកាលទី៥ (២០១៣-២០១៨) |
|---|---|
| ១ | ពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឱ្យកាន់តែទូលំទូលាយ និងខ្លាំងក្លាថែមទៀតក្នុងការកសាង និងការពារមាតុភូមិ ។ |

| | |
|---|---|
| ២ | បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះ បណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់ កាលានុវត្តភាពដល់ស្ត្រីក្នុងការពង្រីកមុខរបរ បង្កើនចំណូល និងកសាង សហគ្រិនភាព ។ |
| ៣ | បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសនៅកម្រិតមធ្យម សិក្សាទុតិយភូមិ និង ឧត្តមសិក្សា ។ |
| ៤ | ពង្រីកលទ្ធភាពក្នុងការទទួលបានសេវាសុខាភិបាលប្រកបដោយ គុណភាពសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសនៅតាមតំបន់ជនបទ ។ |
| ៥ | ជំរុញកម្មវិធីអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅពង្រីកវប្បធម៌អហិង្សា ការកសាង គ្រួសារ និងសហគមន៍ប្រកបដោយសុភមង្គល ។ |
| ៦ | ពង្រឹងការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តី ពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសការអនុវត្តផែនការជាតិ ស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើម្បីលុបបំបាត់នូវឥរិយាបថប្រើអំពើហិង្សាលើស្ត្រី ។ |
| ៧ | បន្តបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានកាន់តែច្រើនឡើង នៅក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ដើម្បីឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា ការកសាងផែនការអភិវឌ្ឍន៍ និង អភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ |
| ៨ | ផ្តល់អាទិភាពលើការអភិវឌ្ឍសុខុមាលភាពកុមារឱ្យបានល្អប្រសើរ ដោយជំរុញការផ្សព្វផ្សាយ និងអនុ វត្តយ៉ាងម៉ត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ ជាពិសេសធានាឱ្យកុមារបានទទួលពិតប្រាកដ នូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ *“សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួល បានការការពារ និងសិទ្ធិចូលរួមរបស់កុមារ”* ។ |
| ៩ | បន្តខិតខំសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ដែលពាក់ព័ន្ធនឹងកុមារ ។ |
| ១០ | ពង្រឹងការអនុវត្តនយោបាយថែទាំជំនួសចំពោះកុមារ ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ បង្កើនការគ្រប់គ្រង និងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌលទាំងមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គ ការមិនមែនរដ្ឋាភិបាល ។ |
| ១១ | អនុវត្តម៉ឺងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមាន ដើម្បីរកគ្រួសារល្អសម្រាប់កុមារនៅក្នុង ប្រទេស និងអន្តរប្រទេស រាំងស្កាត់ការធ្វើអាជីវកម្មកុមារតាមគ្រប់រូបភាព ។ |
| ១២ | បន្តលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស និង កម្មវិធីបំណិនជីវិតដល់យុវជន ជាពិសេសយុវជនពុំសូវមានលទ្ធភាព យុវជនងាយរងគ្រោះ និងយុវជន ពិការឱ្យមានសមត្ថភាព និងកាលានុវត្តភាពក្នុងការបង្កើតមុខរបរ ឬស្វែងរកការងារធ្វើក្នុងទីផ្សារពល កម្មដែលកំពុងតែមានការរីកចម្រើន ។ បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព ប្រកបដោយគុណភាព និងសមធម៌ដល់យុវជន ពង្រីកសកម្មភាពសិល្បៈ កីឡា ការកម្សាន្តសម្រាប់ |

យុវជន សំដៅពង្រឹងកាយសម្បទា សុខភាព និងសាមគ្គីភាពក្នុងជួរយុវជន យុវនារី ។

## កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា

ក្រោយពីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ នៅខែកញ្ញា ឆ្នាំ ២០១៣ រាជរដ្ឋាភិបាលកម្ពុជានៃគណបក្សឈ្នះឆ្នោត បានបង្កើត «កម្មវិធីនយោបាយ» របស់ខ្លួន ដើម្បីអនុវត្តសកម្មភាពដែលមានរយៈពេល៥ឆ្នាំនៃការដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ។

### គោលការណ៍គ្រឹះនៃកម្មវិធីនយោបាយ

- ពង្រឹង និងពង្រីកប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីជួយគាំទ្រដល់ក្រុមជនងាយរងគ្រោះ, ពង្រឹងសមធម៌យេនឌ័រ, លើកកម្ពស់តួនាទី និងស្ថានភាពរបស់ស្ត្រីក្នុងសង្គម, ការពារ និងលើកស្ទួយសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ, ការពារ និងលើកកម្ពស់សិទ្ធិជនពិការ ព្រមទាំងយកចិត្តទុកដាក់ចំពោះសុខភាពជនចាស់ជរា
- បន្តពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម, លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ, លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឲ្យកាន់តែទូលំទូលាយ និងខ្លាំងក្លាថែមទៀតក្នុងកសាង និងការពារមាតុភូមិ ។
- បន្តលើកកម្ពស់សមធម៌យេនឌ័រ,ជម្រុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយការបណ្តុះបណ្តាល បំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់កាលានុវត្តភាពដល់ស្ត្រីក្នុងការពង្រីកមុខរបរ, បង្កើនចំណូល និងកសាងសហគ្រិនភាព, បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រីពិសេសនៅកម្រិតមធ្យមសិក្សា-ទុតិយភូមិ និងឧត្តមសិក្សា ។
- ពង្រីកលទ្ធភាពក្នុងការទទួលបានសេវាសុខាភិបាល ប្រកបដោយគុណភាពសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេស នៅតាមតំបន់ជនបទ ។
- ជំរុញកម្មវិធីអប់រំសីលធម៌សង្គម, តម្លៃស្ត្រី និងគ្រួសារខ្មែរសំដៅពង្រីកវប្បធម៌អហិង្សា, ការកសាងគ្រួសារ និងសហគមន៍ប្រកបដោយសុភមង្គល ។
- ពង្រឹងការអនុវត្តច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសការអនុវត្តផែនការជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដើម្បីលុបបំបាត់នូវឥរិយាបថប្រើអំពើហិង្សាលើស្ត្រី ។
- បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឲ្យបានកាន់តែច្រើនឡើងក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ដើម្បីឲ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា ក៏ដូចជាក្នុងការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

- បន្តផ្តល់អាទិភាពលើការអភិវឌ្ឍសុខុមាលភាពកុមារឲ្យបានល្អប្រសើរ ដោយជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងម៉ត់ចត់នូវអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ ពិសេសធានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ គឺ «សិទ្ធិរស់រានមានជីវិត, សិទ្ធិទទួលបានការអភិវឌ្ឍ, សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ» ។
- បន្តខិតខំសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ដែលពាក់ព័ន្ធនឹងកុមារ តាម រយៈការពង្រឹងការអនុវត្តនយោបាយថែទាំជំនួសចំពោះកុមារ, ការថែទាំកុមារតាមគ្រួសារ និងសហគមន៍, ការបង្កើនការគ្រប់គ្រង និងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល, ការអនុវត្តមឹងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមានដើម្បីរកគ្រួសារល្អសម្រាប់កុមារនៅក្នុងប្រទេស និងអន្តរប្រទេស, រាំងស្កាត់ការធ្វើអាជីវកម្មកុមារតាមគ្រប់រូបភាព ។

**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** [Cambodian Millennium Development Goals (CMDG)]ទាក់ទងនឹងការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ ត្រូវបានបរាជ័យ ។ ជាក់ស្តែងឆ្នាំ២០១៥ តំណាងរាស្ត្រស្ត្រីមានចំនួនតែ ១៩,៥១% និងស្ត្រីក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ១៧,៨៩% ដែលCMDG បានកំណត់ថា នៅឆ្នាំ២០១៥ *«មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិយ៉ាងតិច ៣០% និងថ្នាក់ឃុំ សង្កាត់ ២៥%»* ។ ការបរាជ័យនេះ មូលហេតុចំបងដោយសារ ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរទាំងនៅក្នុងគណបក្សនយោបាយ និងនៅក្នុងច្បាប់បោះឆ្នោតក្នុងការកំណត់ចំនួនស្ត្រីច្បាស់លាស់សម្រាប់ការឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត បើទោះបីមានការបង្ហាញពីភាពរីកចម្រើនខ្លះក៏ដោយ ។

[8]ផ្អែកតាមរបាយការណ៍ស្តីពី ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (ឆ្នាំ២០០៣-ឆ្នាំ២០១៥) សម្រេចបានគោលដៅជាច្រើនតាមរយៈការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងកិច្ចសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ ជាពិសេសគោលដៅទី៣ *«លើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី (Promote Gender Equality and Empower Women)»* សម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់មួយចំនួន ដូចជា ការកាត់បន្ថយគំលាតយេនឌ័រ អំពើហិង្សាប្រឆាំងនឹងស្ត្រី ដោយសង្គមចាត់ទុកអំពើហិង្សាជាបទល្មើសត្រូវផ្តន្ទាទោសដោយច្បាប់ និងបានអនុម័តបទបញ្ញត្តិនានាដើម្បីការពារស្ត្រីមានជាអាទិ៍ ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១០ ក្រមរដ្ឋប្បវេនីឆ្នាំ២០០៦ ។ល។ ថ្មីៗនេះ ផែនការសកម្មភាពជាតិលើកទី២ (ឆ្នាំ

[8] សុន្ទរកថារបស់លោកស្រី **ខឹម ម៉ាណាទី** នាយិកាអង្គការវិទ្យាស្ថានបើកទូលាយ ក្នុងពិធីបើកសន្និសីទលើកទី៣ ស្តីពីគោលដៅទី៥ *«ធ្វើឲ្យបានសម្រេចនូវសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារីទាំងអស់ក្នុងលោក»*នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាព កាលពីថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៦

២០១៤-២០១៨)ស្តីពី «ការទប់ស្កាត់អំពើហិង្សាលើស្ត្រី»ទទួលបានអនុម័ត និងប្រកាសប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០១៤ ។ ចំណែកឯការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយមានការកើនឡើងជាលំដាប់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សូមមើលស្ថិតិនៅចំណុច III)។

[9]ទោះបីជាប្រទេសកម្ពុជាបានធ្វើឲ្យមានភាពជឿនលឿនខ្លះទាក់ទងនឹងសមភាពយេនឌ័រ រួមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រីក៏ដោយ ក៏យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយបណ្តើរៗបន្ថែមទៀត ដែលក្នុងនោះរួមមាន៖ (១)ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងក្នុងវិស័យសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ ។ (២)វិសមភាពយេនឌ័រនៅមាននៅឡើយក្នុងវិស័យអប់រំ ជាពិសេសនៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ។ (៣)បញ្ហាសុខភាពស្ត្រី អាហារូបត្ថម្ភ អត្រាស្លាប់របស់ម្តាយនៅតែជាបញ្ហាប្រឈមដ៏សំខាន់ បើប្រៀបធៀបទៅនឹងប្រទេសដទៃនៅក្នុងតំបន់ ។ (៤)ការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារីទៅតាមនីតិវិធីតុលាការ និងផ្លូវច្បាប់ ព្រមទាំងការផ្តល់សេវាជួយជនរងគ្រោះ នៅពុំទាន់បានរលូន និងមិនទាន់ពេលវេលានៅឡើយ ។

ឆ្នាំ២០១៥ ជាឆ្នាំបញ្ចប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)នៃអង្គការសហប្រជាជាតិ ហើយក៏ជាឆ្នាំដែលកម្ពុជា និងបណ្តាប្រទេសក្នុងពិភពលោកបានប្តេជ្ញាបន្តអនុវត្តចំណុចសេសសល់ពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ តាមរយៈការបង្កើតគោលដៅថ្មីមានឈ្មោះថា **«គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals)»** សម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ពីឆ្នាំ២០១៦-ឆ្នាំ២០៣០ ដែលមាន១៧គោលដៅ និង១៦៩ទិសដៅ ។ ក្នុងចំណោមគោលដៅទាំង១៧ គោលដៅទី៥ បានចែងថា ***«ធ្វើឲ្យបានសម្រេចនូវសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារីទាំងអស់ក្នុងលោក»*** ។ ជាមួយគ្នានេះដែរ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពទាក់ទងនឹងធ្វើឲ្យបានសម្រេចសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារីទាំងអស់ក្នុងលោក ប្រទេសដែលជាសមាជិកនៃអង្គការសហប្រជាជាតិបានកំណត់គោលដៅជាក់លាក់ដោយឡែកសម្រាប់ប្រទេសរបស់ខ្លួនពី៣ ទៅ៥គោលដៅ ។

ប្រទេសកម្ពុជា ប្រមុខរាជរដ្ឋាភិបាលសម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្តលើឆាកអន្តរជាតិកំណត់គោលដៅរបស់ខ្លួនចំនួន៤ចំណុច ក្នុងគោលបំណងលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសិទ្ធិរបស់ស្ត្រី ដោយបន្តផ្តោតអាទិភាពទៅលើការងារ ដូចខាងក្រោម[10]៖

[9] សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងពិធីបិទវេទិកាជាតិស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ។

[10] ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងកិច្ចប្រជុំប្រមុខដឹកនាំពិភពលោក ស្តីពី *«សមភាពយេនឌ័រ និងការលើកកម្ពស់ស្ត្រី»* នៅទីក្រុងញូយ៉ក ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៥ ។

១. ការបង្កើនការវិនិយោគទៅលើសមភាពយេនឌ័រ
២. ការធានានូវការការពារសិទ្ធិរបស់ស្ត្រី ព្រមទាំងការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ។
៣. ការពង្រឹងយន្តការគណនេយ្យភាពសម្រាប់សមភាពយេនឌ័រ
៤. ការបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ។

ថ្មីៗនេះ ក្នុងវេទិកាជាតិ ស្តីពី «ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ» ប្រមុខរាជរដ្ឋាភិបាល និងមន្ត្រីជាន់របស់រដ្ឋាភិបាលកម្ពុជា បានបង្ហាញពីការយកចិត្តទុករបស់ខ្លួនបន្ថែមទៀត ដើម្បីសម្រេចនូវសមភាពយេនឌ័រ និងការបង្កើនចំនួនស្ត្រី និងសមត្ថភាពស្ត្រីជាអ្នកដឹកនាំឲ្យកាន់តែប្រសើរឡើងថែមទៀតក្នុងគ្រប់វិស័យ ជាពិសេស វិស័យសាធារណៈ និងនយោបាយ តាមរយៈការអំពាវនាវ និងបន្តផ្តោតអាទិភាពទៅលើការងារជាក់ស្តែងមួយចំនួនដូចខាងក្រោម[11]៖

**ទី១**. ការធានាលើការការពារសិទ្ធិស្ត្រី ព្រមទាំងការលើកកម្ពស់ការចូលរួមពេញលេញ និងដោយស្មើភាពរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ។ ក្នុងដំណើរឆ្ពោះទៅសម្រេចការងារនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តផ្តល់ឱកាស និងគាំទ្រឲ្យស្ត្រីបានចូលរួម បញ្ចេញទេពកោសល្យសមត្ថភាពរបស់ខ្លួន ព្រមទាំងត្រូវសកម្មចូលរួមដោះស្រាយបញ្ហាប្រឈមនានារបស់ស្ត្រីដែលជាមន្ត្រីរាជការ និងបុគ្គលិកនៅតាមក្រសួង ស្ថាប័ននីមួយៗ ។ ក្នុងស្មារតីនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់ស្ត្រីដែលត្រូវបំពេញតួនាទីជាអ្នកធ្វើសេចក្តីសម្រេច អ្នកទទួលខុសត្រូវលើការងារគ្រប់គ្រង និងរដ្ឋបាលសាធារណៈ ជាដើម ។
*«កុំតែងតាំងស្ត្រីឲ្យតែល្អមើល គឺត្រូវអនុវត្តតាមតួនាទីរបស់ខ្លួន ហើយស្ត្រីខ្លួនឯងត្រូវតែខិតខំធ្វើការ»*

**ទី២**. ការបង្កើន ការវិនិយោគទៅលើសមភាពយេនឌ័រ ជាពិសេសតាមរយៈការពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធ ដើម្បីបង្កើត និងបង្កើនចំណាយសាធារណៈទៅលើសមភាពយេនឌ័រ ព្រមទាំងត្រួតពិនិត្យ វិភាគពីផលប៉ះពាល់នៃចំណាយសាធារណៈទៅលើវិសមភាពយេនឌ័រ តាមរយៈការរៀបចំថវិកាកម្មវិធីដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ។ ទន្ទឹមនេះ ត្រូវអនុវត្តយុទ្ធសាស្ត្រ

[11] សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងពិធីបិទវេទិកាជាតិស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ។

បញ្ច្រាបយេនឌ័ររបស់គ្រប់ក្រសួង ស្ថាប័ន តាមរយៈការរៀបចំផែនការថវិកា និងបញ្ចូលក្នុងថវិកាតាមកម្មវិធីរបស់ក្រសួង ស្ថាប័ន ដើម្បីអាចទទួលបានថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍសម្រាប់អនុវត្តការងាររបស់ខ្លួន ។

**ទី៣**. ការពង្រឹងយន្តការគណនេយ្យភាពសម្រាប់សមភាពយេនឌ័រ គឺជាការងារគន្លឹះដើម្បីវាស់វែងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងវិធានការរបស់ក្រសួង ស្ថាប័ន ព្រមទាំងធានាឲ្យមានការផ្តល់ធនធានគ្រប់គ្រាន់សម្រាប់ការងារយេនឌ័រ ។ ដូច្នេះ ក្រសួង ស្ថាប័ននីមួយៗ ចាំបាច់ត្រូវពង្រឹងមធ្យោបាយនៃការតាមដាន និងត្រួតពិនិត្យ ព្រមទាំងវាយតម្លៃការបែងចែកធនធាន ការវិភាជថវិការបស់ខ្លួនសម្រាប់ការងារយេនឌ័រ ។

**ទី៤**. ការបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ច គឺជាអាទិភាពដើម្បីបង្កើនអំណាចសេដ្ឋកិច្ចគ្រប់គ្រាន់ជូនស្ត្រី និងក្រុមគ្រួសារ និអនុញ្ញាតឲ្យអ្នកទាំងនោះ មានលទ្ធភាពចូលរួមក្នុងការងារសាធារណៈ និងនយោបាយ ។ ក្នុងស្មារតីនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបន្តផ្តល់អាទិភាពទៅលើការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តាមរយៈការបង្កើនការយល់ដឹងដល់ស្ត្រី អំពីការទទួលបានសេវាពាក់ព័ន្ធ ដើម្បីអភិវឌ្ឍអាជីវកម្មសម្រាប់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងមធ្យម ។ ទន្ទឹមនេះ ត្រូវបង្កើតនូវកម្មវិធីនានា សំដៅជួយស្ត្រីឲ្យទទួលបាននូវជំនាញបច្ចេកទេស សហគ្រិនភាព និងសេវាហិរញ្ញវត្ថុ ដើម្បីគាំទ្រស្ត្រីក្នុងការចូលរួមធ្វើពិពិធកម្ម និពាណិជ្ជូបនីយកម្មលើវិស័យកសិកម្ម ។ ព្រមជាមួយនេះ ភាគីពាក់ព័ន្ធនានាក្នុងទីផ្សារការងារត្រូវសហការគ្នាជិតស្និទ្ធ ដើម្បីលុបបំបាត់ការរើសអើងស្ត្រីនៅកន្លែងការងារ រៀបចំស្តង់ដារពលកម្មសម្រាប់ស្ត្រី ផ្តល់ការគាំពារសង្គម និងជួយដោះស្រាយវិវាទជាដើម ។ល។

**ទី៥**. គណបក្សនយោបាយគួរគិតគូរបន្តបង្កើនចំនួនស្ត្រីចូលរួមក្នុងវិស័យនយោបាយ តាមរយៈការផ្តល់អាទិភាពឲ្យស្ត្រីមានឈ្មោះលើបញ្ជីក្នុងលេខរៀងដែលអាចជាប់ឆ្នោតបាន សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ។

**ទី៦**. ចំពោះវិស័យសាធារណៈ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តនូវវិធានការវិជ្ជមាន (វិធានការពិសេស) ដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមកក្នុងការបង្កើនចំនួនស្ត្រី ដូចជាការពន្យាអាយុស្ត្រីចូលនិវត្តន៍ ការជ្រើសរើសមន្ត្រីថ្មីជាស្ត្រីពី ២០% ទៅ៥០% និងការជំនួសអ្នកចូលនិវត្តន៍ដោយស្ត្រីដែលមានសមត្ថភាពក្នុងការបំពេញតួនាទីនោះ ។

**ទី៧**. ការកែទំលាប់ ឥរិយាបទក្នុងការដឹកនាំរបស់បុរស ។ ក្រសួងមហាផ្ទៃនឹងធ្វើការអប់រំ បណ្តុះបណ្តាលដល់អភិបាលខេត្ត ក្រុងជាបុរសទាំងអស់អំពីយេនឌ័រ ដែលការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ គឺជាកាតព្វកិច្ចរបស់អភិបាលខេត្ត ក្រុង ដោយហេតុថា បើអភិបាលខេត្ត ក្រុងជាបុរស

ទាំងនោះអត់យល់ដឹងអំពីយេនឌ័រ ដូច្នេះ ការសម្រេចចិត្តរបស់ពួកគេមិនសូវបានត្រឹមត្រូវ ហើយការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យសាធារណៈអាចនឹងមិនជោគជ័យ[12] ។

ឆ្លើយតបទៅនឹងចំណុចទី៥ខាងលើ ពិតប្រាកដណាស់ ប្រសិនបើគ្មានការកំណត់ចំនួនស្ត្រីឈរឈ្មោះបោះឆ្នោតជាក់លាក់នៅក្នុងច្បាប់ ឬក្នុងគោលនយោបាយទេ ជាពិសេស ច្បាប់ស្តីពី *ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់* និងច្បាប់ស្តីពី *ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ* ស្របតាមអនុសាសន៍របស់ក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិលទេ ផ្ទុយទៅវិញមានតែការអំពាវនាវតាមរយៈពាក្យសំដីបែបនេះ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG)របស់កម្ពុជានឹងត្រូវបរាជ័យដូចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(CMDG) អញ្ចឹង ពីព្រោះការអំពាវនាវប្រហាក់ប្រហែលនេះធ្វើឡើងតាំងពីឆ្នាំ២០១០ម្ល៉េះ ហើយក៏ពុំឃើញមានការអនុវត្តន៍តាមដោយប្រសិទ្ធភាពដែរ ។

***តើម្ចាស់ឆ្នោតពេញចិត្តការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និង តួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួល បានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានក្នុងកម្រិតណា?***

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុរនៅទូទាំង២៤រាជធានី ខេត្តទៅលើការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ឆ្នាំទី២ ក្នុងឆ្នាំ២០១៥ ជាលទ្ធផលបង្ហាញថា ម្ចាស់ឆ្នោត*ពេញចិត្តខ្លះចំនួន៣០,៦៧% (២០៨នាក់)* ដែលជាភាគរយខ្ពស់ជាងគេ ។ ភាគរយខ្ពស់បន្ទាប់ គឺ***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច*** *ចំនួន២៧,៦៣%(១២០នាក់)* និង***ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល*** *ចំនួន២០,៦១%(១៨៦នាក់)* ។ រីឯ ភាគរយទាបជាងគេ គឺ ម្ចាស់ឆ្នោត***ពេញចិត្តច្រើន*** *ចំនួន១១,៣២%(១២៧នាក់)* និង***ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង****ចំនួនតែ៨,១៤% (៧២នាក់)* ប៉ុណ្ណោះ ។ តួលេខនេះបង្ហាញឲ្យឃើញថា ម្ចាស់ឆ្នោតនៅពុំទាន់ពេញចិត្តនៅឡើយចំពោះរដ្ឋាភិបាលក្នុងការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានពិតប្រាកដ ។

[12] បទអន្តរាគមន៍ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋានគជអបក្នុងវេទិកាជាតិស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ។

# II. ការសិក្សាលើក្រុមគោលដៅ ស្តីពី ការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ

## សង្កាត់ក្នុងការបំពេញកិច្ចការងារនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល

ក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ៥ខេត្ត ដូចជា ខេត្តកំពង់ចាម/ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តតាកែវ បច្ចុប្បន្នមានស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន **៥២៦នាក់ (១៥,៣៩%)**ក្នុងចំណោម**៣៤១៨នាក់** ក្នុងនោះមេឃុំស្ត្រីមានចំនួន **២៦នាក់** ។ សកម្មជនបណ្តាញស្ត្រីខុមហ្វ្រែល(CWNA)នៃកម្មវិធីស្ត្រីអាចធ្វើបានចំនួន៤០នាក់ ត្រូវបានដាក់ពង្រាយនៅតំបន់គោលដៅខាងលើ ដោយផ្តោតលើ**ស្រុក ខណ្ឌចំនួន១០** និង និងឃុំ សង្កាត់ចំនួន**២៥** ដើម្បីសង្កេត ឃ្លាំមើលលើស្ថានភាព និងដំណើរការអនុវត្តកិច្ចការងារតាមតួនាទី ភារកិច្ចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៣(ឆ្នាំ២០១២-២០១៧)នេះ ជួបសម្ភាសន៍ផ្ទាល់ជាមួយស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**៤១នាក់** និងធ្វើករណីសិក្សាផងដែរ ។

### ១. ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

#### ១.១. ព័ត៌មានទូទៅរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ គឺមានអាយុ ស្ថានភាពគ្រួសារ និងមកពីប្រភពខុសៗគ្នា ក្នុងនោះស្ត្រីវ័យក្មេងអាយុចន្លោះពី២០ឆ្នាំដល់៣០ឆ្នាំមានចំនួន ៥នាក់ (១២,១៩%) ។ ស្ត្រីក្នុងវ័យកណ្តាលអាយុចន្លោះពី៣១ឆ្នាំដល់៤០ឆ្នាំមានចំនួន៨នាក់ (១៩,៥១%) ។ ស្ត្រីក្នុងបជ្ឈឹមវ័យអាយុចន្លោះពី៤១ឆ្នាំដល់៥០ឆ្នាំមានចំនួន៦នាក់ (១៤,៦៣%) និងស្ត្រីវ័យចំណាស់អាយុលើសពី៥០ឆ្នាំមានចំនួនច្រើន២២នាក់ (៥៣,៦៥%) ។ ចំណែកឯស្ថានភាពគ្រួសាររបស់ស្ត្រីទាំងនោះ ២៧នាក់មានគ្រួសារ ៩នាក់ជាស្ត្រីមេម៉ាយ និង៥នាក់នៅលីវដែលមានប្រភពមកពីសមាជិកគណបក្សនយោបាយ ជនបង្គោលឃុំ និងប្រជាពលរដ្ឋធម្មតា ។ តួលេខឆ្នាំនេះប្រហាក់ប្រហែលនឹងតួលេខឆ្នាំមុនដែរ គឺនៅតែបង្ហាញឲ្យឃើញថា ស្ត្រីវ័យក្មេងមានតួនាទីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតិចតួច ខណៈដែលស្ត្រីវ័យចំណាស់បាន និងកំពុងមានវត្តមានដ៏ច្រើន និងបង្ហាញអំពីទំនាក់ទំនងយ៉ាងខ្លាំងក្លាក្នុងការចូលរួមក្នុងកិច្ចការនយោបាយ និងការចូលជាសមាជិកគណបក្សនយោបាយ ព្រមទាំងបង្ហាញពីឆន្ទៈមោះមុតក្នុងការធ្វើឲ្យខ្លួនក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បើទោះបីជាប្រជាពលរដ្ឋធម្មតាក៏ដោយ ។

## ក្រាហ្វិកទី១




## ១.២. ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ មាន៩នាក់ដែលទើបតែជាប់ជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅអាណត្តិទី៣ (១អាណត្តិ) ។ ១៩នាក់បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ២អាណត្តិ ( អាណត្តិទី១ និងទី៣ចំនួន៣នាក់ និង១៦នាក់ក្នុងអាណត្តិទី២ និងទី៣) និង១៣នាក់បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣អាណត្តិ ។ ដូចឆ្នាំមុនដែរតួលេខបញ្ជាក់ឲ្យឃើញថា ស្ត្រីភាគច្រើនមិនអាចមានឱកាសបានធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣អាណត្តិឡើយ ទោះបីពួកគេខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ហើយកាន់តែមានឱកាសតិចតួចទៅទៀតចំពោះស្ត្រីដែលនឹងត្រូវជាប់ឆ្នោតថ្មីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ នេះអាចមកពីខ្វះការយកចិត្តទុកដាក់ពីប្រធានគណបក្សនៅថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក ឃុំ) ជាពិសេសប្រធានគណបក្សនៅថ្នាក់ឃុំ សង្កាត់ដែលភាគច្រើនជាបុរសមានតួនាទីជាមេឃុំ ចៅសង្កាត់បុរស និងខ្វះនូវគោលនយោបាយលើកស្ទួយស្ត្រីនៅក្នុងគណបក្សរបស់ខ្លួនផងដែរ ។

## ក្រាហ្វិកទី២




## ១.៣. តួនាទីរបស់ស្រ្តីក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៤១នាក់ ៥នាក់មានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំ ។ ៥នាក់មានតួនាទីជាជំទប់ទី១ ៤នាក់មានតួនាទីជាជំទប់ទី២ និង២៧នាក់មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ក្នុងនោះភាគច្រើនទទួលបន្ទុកកិច្ចការស្រ្តី និងកុមារ ។ តួលេខបង្ហាញយ៉ាងច្បាស់ថាស្រ្តីនៅតែមានឱកាសតិចតួចក្នុងការទទួលបានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាមេឃុំ ចៅសង្កាត់ ខណ:ដែលភាគច្រើនលើសលុបគ្រាន់តែជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ធម្មតាប៉ុណ្ណោះ។

## ក្រាហ្វិកទី៣



## ១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់

### ក្រាហ្វិកទី៤




សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ បានបង្ហាញពីមូលហេតុដែលពួកគាត់ចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ មាន១៣៥ចម្លើយ ក្នុងនោះ៣៩ចម្លើយបង្ហាញថា ចង់ការពារផលប្រយោជន៍ស្ត្រី និងកុមារដែលជាតួលេខនាំមុខគេ ៣២ចម្លើយចង់ជួយសង្គមដោយផ្ទាល់ ៣១ម្លើយចង់លើកកម្ពស់ស្ត្រី ១៩ចម្លើយគិតពីអនាគតកូនចៅ និង១៤ចម្លើយគិតពីជីវភាពគ្រួសារប្រចាំថ្ងៃ ។ ទោះបីចម្លើយមានផ្សេងៗគ្នាខ្លះក៏ដោយ ក៏ស្ត្រីទាំងអស់មានការប្តេជ្ញាចិត្តចូលរួមក្នុងកិច្ចការនយោបាយក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមជាតិដូចគ្នា ជាពិសេសយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាស្ត្រី និងកុមារ និងចង់លើកស្ទួយស្ថានភាពស្ត្រីឲ្យមានភាពប្រសើរឡើង ។

## ២. ស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

### ២.១. ការរើសអើងស្ត្រី

### ២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ដូចឆ្នាំមុនដែរ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ បានបង្ហាញថា បានទទួលការគាំទ្រស្ទើរតែទាំងស្រុងពីក្រុមគ្រួសារ (លើកលែងតែ ១នាក់ ពេលខ្លះគាំទ្រពេលខ្លះមិនគាំទ្រ) និងមានការអបអរសាទរពីប្រជាពលរដ្ឋចំពោះពួកគាត់ (លើកលែងតែ១នាក់មានការរិះគន់) ពេញចិត្តការងាររបស់ពួកគាត់ មាន

សមត្ថភាពជួយធ្វើការងារ ប្រជាពលរដ្ឋទុកចិត្ត ប្រជាពលរដ្ឋពេញចិត្តឲ្យធ្វើការបន្ត ព្រោះប្រជាពលរដ្ឋអាចពឹងពាក់បាន ចង់ឲ្យមានវត្តមានស្ត្រីច្រើននៅក្នុងឃុំ សង្កាត់របស់គាត់ ។

នេះបង្ហាញពីការផ្លាស់ប្តូរជាវិជ្ជមាននៃផ្នត់គំនិតសង្គមក្នុងការឲ្យតម្លៃ និងគាំទ្រយ៉ាងពេញទំហឹងចំពោះសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីជាអ្នកដឹកនាំ និងក្នុងវិស័យនយោបាយ ដែលជាកំលាំងជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រីកាន់តែខ្លាំង និងសកម្មថែមទៀត ។

### ២.១.២. អាកប្បកិរិយាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបំពេញកិច្ចការជាមួយស្ត្រី

**ក្រាហ្វិកទី៥**




ក្នុងចំណោមស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ មាន៣៤នាក់បញ្ជាក់ថា មានការគាំទ្រ និងលើកទឹកចិត្តពីបុរសជាក្រុមប្រឹក្សាឃុំ សង្កាត់ ។ ៥នាក់ប្រាប់ថា បុរសនៅតែរើសអើង និងមិនចង់សហការជាមួយស្ត្រីឡើយ ខណៈដែល២នាក់ទៀតមានការរិះគន់ចំពោះស្ត្រី ។ តួលេខនេះ បញ្ជាក់ថា បុរសក្រុមប្រឹក្សាឃុំ សង្កាត់នៅតែរើសអើង និងមិនចង់សហការជាមួយស្ត្រី និងមានការរិះគន់ចំពោះស្ត្រីនៅឡើយ បើទោះបីការរើសអើងមានការថយចុះក៏ដោយ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការរើសអើងមានការថយចុះ គឺពី១៩,៣៥% ឆ្នាំ២០១៤ មកត្រឹម ១២,១៩% ឆ្នាំ២០១៥ ។ តាមសំដីរបស់លោកស្រី **ជា សុខុន** សមាជិកក្រុមប្រឹក្សាឃុំដំរីជាន់ខ្លា ក្រុងស្ទឹងសែនមកពី គណបក្សប្រជាជន កម្ពុជា បញ្ជាក់ថា «*អាកប្ប*

*កិរិយារបស់បុរសហាក់មិនចង់សហការ មានការរើសអើងជាមួយពួកគាត់ដែលជាស្ត្រីក្រុមប្រឹក្សាឃុំ ដោយពួកបុរសគិតថា ស្ត្រីសមត្ថភាពនៅអន់ ការយល់ដឹងនៅមានកម្រិត»* ។

ទោះបីជាយ៉ាងណាក៏ដោយ ៨២,៩២%បានការគាំទ្រ និងលើកទឹកចិត្តពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រីដោយយល់ថា ស្ត្រីជាដៃគូដ៏សំខាន់មិនអាចខ្វះបាន ស្ត្រីធ្វើការងារសម្រេចបានដូចបុរសដែរ ។

## ២.២. ភារទទួលបានភារកិច្ចភារងារ សិទ្ធិអំណាចពេញលេញរបស់ស្ត្រីតាមច្បាប់

### ២.២.១. ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្ត្រីរបស់ខ្លួន

**ក្រាហ្វិកទី៦**




ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៤១នាក់ មាន៣៧នាក់ឆ្លើយថា ប្រធានក្រុមប្រឹក្សាបានប្រគល់ តួនាទី ភារកិច្ចជូនពួកគាត់ដែលជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ដូចមានចែងក្នុងច្បាប់ ។ ៤ នាក់ ឆ្លើយថាមានការប្រគល់ភារកិច្ចជូនខ្លះៗដែរ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការរើសអើងប្រគល់តែភារកិច្ចខ្លះៗជូនដល់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ មានការថយចុះ ពី ១៦,១២% ឆ្នាំ២០១៤ មកត្រឹម ៩,៧៥%ឆ្នាំ២០១៥ ។

បើទោះបីតួលេខរើសអើងនេះមានការថយចុះក៏ដោយ ក៏នៅតែបង្ហាញនូវការបន្តភាពរើសអើង និងនៅតែជាបញ្ហាបន្ទាន់ ដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ចំពោះសមាជិកក្រុមប្រឹក្សាណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនពេញលេញដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្តីពី « *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន ។

### ២.២.២. តើនៅតំបន់របស់លោកស្រី នាងកញ្ញា ធ្លាប់ដឹងថា មានគេបញ្ឈប់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែរឬទេ?

មិនខុសពីឆ្នាំមុនឆ្នាំ២០១៤ គឺមិនមានការបញ្ឈប់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយក្នុងតំបន់របស់ពួកគាត់ទេ យោងតាមចម្លើយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៤០នាក់ ក្នុងចំណោម៤១នាក់ ។

### ២.២.៣. ការចុះចូលគណបក្សផ្សេងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ខុសពីឆ្នាំ២០១៤ គឺឆ្នាំ២០១៥ មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រុស-ស្រីចំនួន ៤នាក់ បានចុះចេញពីគណបក្សខ្លួន ទៅចុះចូលគណបក្សផ្សេង ក្នុងនោះ ៣នាក់ ភេទប្រុសបានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា (១នាក់មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច នៅសង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ១នាក់ទៀតមកពីគណបក្សសមរង្ស៊ី នៅសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង និង១នាក់ផ្សេងទៀតមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច នៅឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ) និង ១នាក់ទៀត ភេទស្រីផ្លាស់ពីគណបក្សសម រង្ស៊ី ចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។

## ២.៣. ការបំពេញការងារទាក់ទងនឹងស្ត្រី និងកុមារ និងភាពសកម្មរបស់ស្ត្រី

ស្ថិតក្នុងតួនាទីរបស់ខ្លួន ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤១នាក់ កំពុងធ្វើការងារយ៉ាងមមាញឹកនាពេលបច្ចុប្បន្ន ។ ជាក់ស្តែង ស្ត្រីដែលមានតួនាទីជា**សមាជិកក្រុមប្រឹក្សាទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ សមាជិកផ្សេងទៀត** និង**ចៅសង្កាត់រងទី១/ជំទប់ទី១ទទួលបន្ទុកហិរញ្ញវត្ថុ** បាន និងកំពុងជាប់រវល់ជាមួយនឹងការដោះស្រាយបញ្ហាទំនាស់ក្នុងមូលដ្ឋានដូចជា ទំនាស់ដីធ្លី បញ្ហាព្រំដី ការចុះអត្រានុកូលដ្ឋាន (ចុះសំបុត្រកំណើត និង បញ្ជាក់សំបុត្រកំណើត ចុះសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់សំបុត្រមរណភាព) ផ្សព្វផ្សាយឲ្យកុមារចាក់ថ្នាំបង្ការ៧មុខ ផ្សព្វផ្សាយអំពីការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ សុខភាពមាតាទារក និងកុមារ និងធ្វើការណែនាំតាមផ្ទះដល់ជនក្រីក្រ។

ចំណែកឯស្ត្រីដែលមានតួនាទីជា**សមាជិកក្រុមប្រឹក្សាទទួលបន្ទុកសណ្តាប់ធ្នាប់ សមាជិកផ្សេងទៀត** និង**ចៅសង្កាត់រងទី២/ជំទប់ទី២ទទួលបន្ទុកសន្តិសុខ សណ្តាប់ធ្នាប់** កំពុងប្រតិបត្តិការជាមួយនឹងកិច្ចការមួយចំនួនរួមមាន ការរៀបចំសន្តិសុខតាមភូមិ ឃុំ ដោះស្រាយបញ្ហាសំណង់មិនគោរព ឬខុសច្បាប់ និងរៀបចំសណ្តាប់ធ្នាប់តាមផ្លូវលំ ផ្លូវថ្នល់ និងផ្លូវជាតិ រៀបចំសន្តិសុខ និងសណ្តាប់ធ្នាប់ផ្សារ ។ បន្ថែមពី

នេះ អនុវត្តគំរោងកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋភិបាល ដោយជ្រើសរើសក្រុមប្រជាពលរដ្ឋក្រីក្រ សម្រាប់ផ្តត់ផ្គង់ថវិកា ជាបីដំណាក់កាលក្នុងការបង្កើតរបរកសិកម្មធុនតូចជាលក្ខណៈគ្រួសារ គឺ (ដំណាក់ការទី១) ទឹកប្រាក់ ១០០ដុល្លារអាមេរិក (ដំណាក់ការទី២) ទឹកប្រាក់ ៨០ដុល្លារអាមេរិក និង(ដំណាក់ការទី៣) ទឹកប្រាក់ ៦០ដុល្លារអាមេរិក ។ ជាមួយជាគ្នានេះដែរ ធ្វើការស្រាវជ្រាវ តាមដាន និងផ្តល់អត្តសញ្ញាណដល់គ្រួសារក្រីក្រ តាមរយៈការសម្ភាសន៍តាមភូមិពិនិត្យស្ថានភាពជាក់ស្តែង ដោយធ្វើការបែងចែកប្រជាពលរដ្ឋក្រីក្រ៣ប្រភេទខុសគ្នា (ប្រភេទទី១) ក្រខ្លាំងបំផុត (ប្រភេទទី២) ក្រខ្លាំង និង (ប្រភេទទី៣) ក្រធម្មតា ដែលជាផែនការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ដោយឡែក ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ បាន និងកំពុងជាប់រវល់ជាមួយនឹងការទទួលខុសត្រូវរួមលើការគ្រប់គ្រងឃុំ សង្កាត់ ថាតើធ្វើយ៉ាងណាដើម្បីឲ្យឃុំ សង្កាត់របស់ខ្លួនមានការអភិវឌ្ឍន៍ និងចុះពិនិត្យ តាមដានសកម្មភាពការងារសមាជិកទាំងអស់ជាប្រចាំ ដើម្បីឲ្យមានគុណភាពខ្ពស់ និង ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.៤. ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត

### ២.៤.១. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់៤១នាក់ មាន២៧នាក់បានចូលរួមប្រជុំមួយដងក្នុង១ខែជាទៀងទាត់ និង មានការកើនឡើង១៤នាក់បានចូលរួមប្រជុំពីរដងក្នុង១ខែបើធៀបនឹងឆ្នាំ២០១៤ មានតែ៨នាក់ ប៉ុណ្ណោះ ។ ប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ស្ត្រីពិតជាមានឱកាសចូលរួមប្រជុំដោយពេញលេញស្របតាមច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែយើងនៅតែមានការព្រួយបារម្ភ និងហាក់បីដូចជាពុំទាន់មានទំនុកចិត្តខ្លះនៅឡើយអំពីការបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្តីសម្រេចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយបុរសភាគច្រើន ។ ជាទូទៅ ឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ឃុំ សង្កាត់ខ្លះមានស្ត្រីក្រុមប្រឹក្សាជាអតិបរមា ៤នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី៣នាក់ ឃុំ សង្កាត់ខ្លះទៀតមានស្ត្រី២នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី១នាក់ និងឃុំ សង្កាត់ខ្លះទៀតពុំមានស្ត្រីសោះ ។ នេះជាកត្តាធ្វើឲ្យការចូលរួមសម្រេចចិត្តរបស់ស្ត្រីជួបនូវការលំបាក និងត្រូវរងឥទ្ធិពលពីការសម្រេចចិត្តរបស់បុរសដែលជាមតិភាគច្រើន ។

### ២.៤.២. ការបញ្ចេញមតិយោបល់ ឬ សំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំ

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៤១នាក់ដែលបានចូលរួមប្រជុំ ស្ទើរតែទាំងអស់ ៣៩នាក់ ហ៊ានបញ្ចេញមតិយោបល់ និងលើកសំណើរដើម្បីឲ្យមានការដោះស្រាយ និងមានតែ២នាក់ប៉ុណ្ណោះមិនធ្លាប់បានបញ្ចេញយោបល់ ឬសំណើរអ្វីសោះដោយសារគាត់ជាសមាជិកក្រុមប្រឹក្សាឃុំថ្មីទើបតែតែងតាំង

ជំនួសអ្នកទទួលមរណភាព ។ លទ្ធផលនេះបញ្ជាក់ថា ស្ត្រីបានបង្ហាញពីសក្តានុពលរបស់ខ្លួន ភាពជឿជាក់លើខ្លួនឯង និងភាពក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំដែលភាគច្រើនផ្តោតលើបញ្ហាស្ត្រី កុមារ និងចាស់ជរា ។ ទោះជាយ៉ាងនេះក្តី យើងនៅតែប្រាថ្នាចង់ឃើញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចូលរួមបញ្ចេញមតិ យោបល់ក្នុងអង្គប្រជុំឲ្យបានគ្រប់ៗគ្នា ដោយមានការលើកទឹកចិត្ត និងផ្តល់ឱកាសពីមេឃុំ ចៅសង្កាត់ជាបុរស និងសមាជិកបុរសភាគច្រើន និងផ្តល់អំណាចឲ្យស្ត្រីចូលរួមដោយពេញលេញ ។

**តារាងទី៧៖**

| សំណើ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងអង្គប្រជុំ ដើម្បីដោះស្រាយ |
|---|
| បញ្ហាកុមារក្រីក្រគ្មានសម្ភារៈសិក្សា ខ្វះមធ្យោបាយធ្វើដំណើរ កុមារគ្មានសំបុត្របញ្ជាក់កំណើត ស្ត្រីក្រីក្រមានកូនច្រើនខ្វះអនាម័យ បណ្តាលឲ្យមាន ជម្ងឺផ្សេងៗ |
| ការបើកក្លិបសិក្សាសម្រាប់កុមារក្នុងឃុំ |
| បញ្ហាស្ត្រីរងគ្រោះ និងកុមារបោះបង់ការសិក្សា និងចំណាកស្រុក |
| បញ្ហាស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ |
| បញ្ហាសុខភាពស្ត្រី កុមារ និងចាស់ជរា |
| សុំថវិកាជួយដល់ស្ត្រីក្រីក្រមានផ្ទៃពោះ ស្ត្រីសំរាលកូន កុមារកំព្រា ចាស់ជរា ស្ត្រីមានវិបត្តិ |
| ការលំបាកពីបញ្ហាធ្វើអត្រានុកូលដ្ឋាន |
| សំណូមពរទៅស្មៀនឲ្យចែករបាយការណ៍រៀងរាល់ខែដល់សមាជិកក្រុមប្រឹក្សាឃុំ ទាំងអស់ |
| លើកឡើងពីយេនឌ័រ បុរសនិងស្ត្រីឲ្យមានភាពស្មើគ្នាចំពោះមុខច្បាប់ និងកិច្ចការងារ |
| បញ្ហារើសអើងរវាងគណបក្សនៅក្នុងឃុំ ។ ស្នើឲ្យអាជ្ញាធរឃុំធ្វើយ៉ាងណាកុំឲ្យរើសអើងរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ បើមានកិច្ចប្រជុំត្រូវអញ្ជើញឲ្យចូលរួម |
| ផ្តល់ឱកាសឲ្យយុវជនចូលរួម ក្នុងកិច្ចការសង្គមឲ្យបានច្រើន |

### ២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអង្គប្រជុំ

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ៣៩នាក់បានលើកសំណើ និងយោបល់ មាន៣៦នាក់ឆ្លើយថា សំណើ និងយោបល់របស់ពួកគាត់ត្រូវបានគេសម្រេចក្នុងអង្គប្រជុំ និងយកទៅដោះស្រាយ ។ ៣ នាក់ទៀតឆ្លើយថា បានត្រឹមតែយកសំណើ និងយោបល់របស់គាត់ទៅទុកពិចារណាដើម្បីសម្រេចពេលក្រោយដោយពុំមានកំណត់ពេលវេលាច្បាស់លាស់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំ និងដោះស្រាយលើសំណើរ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងបន្តិច ពី ៨៨,៨៨% ឆ្នាំ២០១៤ ទៅ ៩២,៣០% ឆ្នាំ២០១៥ ។

**តារាងទី៨៖ សំណើ និងយោបល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងអង្គប្រជុំ និងដោះស្រាយ**

| សំណើ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ | ការសម្រេច និងដំណោះស្រាយ |
|---|---|
| បញ្ហាកុមារក្រីក្រគ្មានសម្ភារៈសិក្សា ខ្វះមធ្យោបាយធ្វើដំណើរ កុមារគ្មានសំបុត្របញ្ជាក់កំណើត ស្ត្រីក្រីក្រមានកូនច្រើនខ្វះអនាម័យ បណ្តាលឲ្យមានជម្ងឺផ្សេងៗ | បញ្ហាទាំងនេះត្រូវបានដោះស្រាយរួច កុមារបានចូលរៀនទាំងអស់គ្នា |
| ការបើកក្លិបសិក្សាសម្រាប់កុមារក្នុងឃុំ | យល់ព្រមបើកក្លិបសិក្សាសម្រាប់កុមារក្នុងភូមិក្បាលទឹក ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ |
| បញ្ហាស្ត្រីរងគ្រោះ និងកុមារបោះបង់ការសិក្សា និងចំណាកស្រុក | រាល់សំណើរដែលស្ត្រីបានលើក ក្រុមប្រឹក្សាជាបុរសតែងតែគាំទ្រ ប៉ុន្តែសម្រេចតាមបញ្ហាណាដែលឃុំសម្រេចបាន និងស្នើឡើងទៅថ្នាក់លើ |
| បញ្ហាស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ<br>បញ្ហាសុខភាពស្ត្រី កុមារ និងចាស់ជរា | សំណើរត្រូវបានឯកភាពយកទៅដោះស្រាយ ពីព្រោះជាបញ្ហាដែលកំពុងកើតឡើងចំពោះមុខ |
| សុំថវិកាជួយដល់ស្ត្រីក្រីក្រមានផ្ទៃពោះ ស្ត្រីសំរាលកូន កុមារកំព្រា ចាស់ជរា ស្ត្រីមានវិបត្តិ | - ត្រូវបានការគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើនេះ<br>- បានដាក់សំណើនេះក្នុងផែនការវិនិយោគ ឃុំប្រចាំឆ្នាំ |

| | |
|---|---|
| | - ឯកភាពជួយផ្ដត់ផ្គង់ដល់ស្ត្រីក្រីក្រសំរាលកូនក្នុងម្នាក់៥០ ០០០រៀល |
| ការលំបាកពីបញ្ហាធ្វើអត្រានុកូលដ្ឋាន | ត្រឹមពិចារណាទុកពេលយូរដើម្បីដោះស្រាយ |
| សំណូមពរទៅស្មៀនឲ្យចែករបាយការណ៍រៀងរាល់ខែដល់សមាជិកក្រុមប្រឹក្សាឃុំ ទាំងអស់ | ឯកភាព |
| លើកឡើងពីយេនឌ័រ បុរសនិងស្ត្រីឲ្យមានភាពស្មើគ្នាចំពោះមុខច្បាប់ និងកិច្ចការងារ | ទទួលយកដោយគោលនយោបាយលើកកម្ពស់ចលនាស្ត្រី |
| បញ្ហារើសអើងរវាងគណបក្សនៅក្នុងឃុំ ។ ស្នើឲ្យអាជ្ញាធរឃុំធ្វើយ៉ាងណាកុំឲ្យរើសអើងរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ បើមានកិច្ចប្រជុំត្រូវអញ្ជើញឲ្យចូលរួម | ក្រុមប្រឹក្សាឃុំធ្វើការពិចារណា និងបានសម្រេចត្រឹម៥០% |
| ផ្ដល់ឱកាសឲ្យយុវជនចូលរួម ក្នុងកិច្ចការសង្គមឲ្យបានច្រើន | មិនមានដំណោះស្រាយទេ ពីព្រោះគិតថា យុវជនមិនទាន់មានសមត្ថភាពក្នុងការធ្វើការងារសង្គមបាន |

## ៣. ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់

របាយការណ៍ ឃ្លាំមើលខុមហ្វ្រែល ទាក់ទិននឹងថវិកាប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារសំរាប់ឃុំសង្កាត់ប្រចាំឆ្នាំបានបង្ហាញតាមរយៈស្ត្រីសមាជិកក្រុមប្រឹក្សាឃុំចំនួន៤១រូបមកពីឃុំ សង្កាត់ចំនួន២៥ ក្នុងនោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន ៥រូប មាន ៨ ឃុំ និងឃុំសង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន ៧រូប មាន ៥ ឃុំ និងឃុំសង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន ៩រូប មាន ៦ ឃុំ ហើយនិងឃុំសង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន ១១រូប មាន ៦ ឃុំ ដែលលទ្ធផលបង្ហាញក្នុងតារាងខាងក្រោមនេះ៖

### តារាងទី៩៖ ថវិកាសរុបប្រចាំឆ្នាំ

| ថវិកាសរុបប្រចាំឆ្នាំ ដែលក្រុមប្រឹក្សា ឃុំ សង្កាត់ ទទួលសំរាប់កិច្ចការស្ត្រី និងកុមារ | | | |
|---|---|---|---|
| ឃុំតូច | ឃុំមធ្យម (ក្រុមប្រឹក្សា ឃុំ សង្កាត់) | | ឃុំធំ |
| ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ៥រូប | សមាជិក ៧រូប | សមាជិក ៩រូប | ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ១១រូប |

| | | | |
|---|---|---|---|
| -១ ០០០ ០០០ រៀល (មួយលានរៀល)<br>-២ ០០០ ០០០ រៀល (ពីរលានរៀល)<br>-២ ៥០០ ០០០ រៀល (ពីរលានប្រាំសែនរៀល)<br>-៣ ០០០ ០០០ រៀល (បីលានរៀល)<br>-ឃុំស្តៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ បញ្ហាថវិកាស្ថិតក្នុងការគ្រប់គ្រងរបស់ស្មៀនទាំងអស់ សមាជិកហាក់មិនដឹងទេ។<br>-ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ បញ្ហាថវិកា សមាជិកមិនដឹងអំពីថវិកាមានប៉ុន្មាននោះឡើយ។ | -៣ ០០០ ០០០រៀល (បីលានរៀល)<br>-៤ ០០០ ០០០ រៀល (បួនលានរៀល)<br>-៦ ០៧០ ០០០រៀល (ប្រាំមួយលាន ប្រាំពីរម៉ឺន)<br>-៨០០ ដុល្លារ អាមេរិក (ប្រាំបីរយដុល្លារ)<br>-ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បញ្ហាថវិកា ពុំដែលដឹងថាមានសំរាប់កិច្ចការស្ត្រី និងកុមារ ក៏ប៉ុន្តែបានថវិកាពី UNFPA មាន៥០០ដុល្លារអាមេរិក (ប្រាំរយដុល្លារ) តែបច្ចុប្បន្នគេផ្តាច់វិញហើយ។ | -៣ ៧០០ ០០០ រៀល (បីលានប្រាំពីរសែនរៀល)<br>-៣ ទៅ៤ ០០០ ០០០ រៀល (បីទៅបួនលានរៀល)<br>-៤ ៦៤០ ០០០ រៀល (បួនលានប្រាំមួយសែនបួនម៉ឺនរៀល)<br>-៦ ៩៦០ ០០០ រៀល (ប្រាំមួយលាន ប្រាំបួនសែន ប្រាំមួយម៉ឺនរៀល)<br>-៧ ៩៩៦ ០០០ រៀល (ប្រាំពីរលាន ប្រាំបួនសែន ប្រាំបួនម៉ឺនប្រាំមួយពាន់រៀល) -១២ ០០០ ០០០ រៀល (ដប់ពីរលានរៀល)។ | -២ ០០០ ០០០ រៀល (ពីរលានរៀល)<br>-៤ ០០០ ០០០ រៀល (បួនលានរៀល)<br>-៥ ០០០ ០០០ រៀល (ប្រាំលានរៀល)<br>-៦ ០០០ ០០០ រៀល (ប្រាំមួយលានរៀល)<br>-១០ ០០០ ០០០ រៀល (ដប់លានរៀល)<br>-១២ ០០០ ០០០ រៀល (ដប់ពីរលានរៀល)<br>-ឃុំផ្សារឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បញ្ហាថវិកាមិនដែលមានថវិកាសំរាប់កិច្ចការស្ត្រី និងកុមារទេ។<br>- |

### ៣.១. តម្លាភាពថវិកា

ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ ។

របាយការណ៍រកឃើញទៀតថា តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំសង្កាត់មួយចំនួន ។ ការមិនសូវមានតម្លាភាពថវិកានេះ ដោយសារកញ្ចប់ថវិការបស់ពួកគេមានការលាក់បាំងខ្លះៗ ។ ឃុំ សង្កាត់ខ្លះថវិកាទាំងនោះមិនបានផ្សព្វផ្សាយ ឬបិទជាព័ត៌មាន ឬប្រជុំធ្វើបទបង្ហាញអ្វីឡើយ ។ ជាក់ស្តែង នៅក្នុងឃុំចំនួន៤ ដូចជា ***ឃុំស្តៅ*** *ស្រុកសង្គមថ្មី ខេត្តព្រះវិហារ* ថវិកាស្ថិតក្នុងការគ្រប់គ្រងរបស់ស្មៀនទាំងអស់ សមាជិកក្រុមប្រឹក្សាហាក់មិនដឹង ពេលមានគំរោងចង់ចំណាយលើកិច្ចការស្ត្រី និងកុមារម្តងៗ តែងមានការជជែកឈ្លោះប្រកែកតមាត់គ្នា ។ ***ឃុំត្បូងក្រពើ*** *ស្រុកសន្ទុក ខេត្តកំពង់ធំ* សមាជិកក្រុមប្រឹក្សាឃុំមិនដឹងអំពីថវិកាមានប៉ុន្មាននោះទេ។ ***ឃុំអភិវឌ្ឍន៍*** *ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង* ពុំដែលដឹងថាមានថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ក៏ប៉ុន្តែបានថវិកាពី UNFPAចំនួន៥០០ដុល្លារអាមេរិក តែបច្ចុប្បន្នគេផ្តាច់វិញហើយ ។ រីឯ***ឃុំផ្សារឆ្នាំង*** *ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង* ពុំដែលមានថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារទេ ។

*ខាងក្រោមនេះគឺជាសម្តីផ្ទាល់របស់បុរស-ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៖*

- **លោកស្រី កែវយ៉ាន** សមាជិកក្រុមប្រឹក្សាឃុំ ក្រាំងស្គា មកពីគណបក្សប្រជាជន បានមានប្រសាសន៍ថា *«ចំពោះថវិកាស្ត្រី និងកុមារ ពេលចំណាយ ទូទាត់ថវិកា គ្មានតម្លាភាព ពេលប្រជុំមិនមានការបង្ហាញ»* ។ ចំណែកឯ **លោក ជួប សុភីន** ជំទប់ទី១ឃុំក្រាំងស្គា មកពីគណបក្សសមរង្ស៊ី (សង្គ្រោះជាតិ) ក៏បានបញ្ជាក់បន្ថែមទៀតថា *«ថវិកាស្ត្រី និងកុមារ ពេលចំណាយ ទូទាត់ថវិកា គ្មានតម្លាភាព ពេលប្រជុំមិនមានការបង្ហាញដែរ »* ។

- **លោកស្រី កង ឡុងឌី** ជាសមាជិកក្រុមប្រឹក្សា នៅសង្កាត់ផ្សាឆ្នាំង ខ័ណ្ឌកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ បានបញ្ជាក់ថា *« មិនមានថវិកាទាំងនេះទេ ដោយលោកស្រីបានសាកសួរទៅប្រធានក្រុមប្រឹក្សាឆ្លើយថា មិនដឹងសួរទៅស្មៀនឆ្លើយថាមិនមានថវិកានេះទេ។ »*

## ៣.២. ការដកថវិកា

### ក្រាហ្វិកទី៧




ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៤១នាក់នៃ២៥ឃុំ សង្កាត់ មានតែ២៥នាក់ (**១៧ឃុំ**)ប៉ុណ្ណោះមានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ខណៈដែល១៦នាក់ (**១០ឃុំ**) ទៀតមានការពិបាកក្នុងការ**ដកថវិកា**ពីរតនាគារ ការទទួលបានថវិកានៅមានភាពយឺតយ៉ាវ និងស្មៀនមិនបើកថវិកាឲ្យគ្រប់ចំនួនតាមគំរោង ។ ឃុំទាំង១០ដែលពិបាកដកថវិកា មានដូចជា *ឃុំស្ពៅ* (ស្រុកសង្គមថ្មី ខេត្តព្រះវិហារ) *ឃុំត្បូងក្រពើ* (ស្រុកសន្ទុក ខេត្តកំពង់ធំ) *សង្កាត់កំពង់ធំ* និង *សង្កាត់អូរកន្ធ*(ក្រុងស្ទឹងសែន ខេត្តកំពង់ធំ) *ឃុំទួលសុភី និងឃុំចក* (ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ) *ឃុំក្រាំងស្គារ និងឃុំអភិវឌ្ឍន៍* (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង) *ឃុំកំពង់ឆ្នាំង និងឃុំផ្សាឆ្នាំង* (ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង)។ គួរកត់សម្គាល់ថា មាន២ឃុំ សង្កាត់ក្នុងចំណោម២៥ឃុំ សង្កាត់ បានផ្តល់ចម្លើយផ្ទុយគ្នា ជាក់ស្តែង *១ឃុំនៅ*

*សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ* ស្ត្រីសមាជិកក្រុមប្រឹក្សាសង្កាត់ ២នាក់មកពីគណបក្សប្រជាជនកម្ពុជា បានឆ្លើយផ្ទុយគ្នា ម្នាក់ថាពិបាក ម្នាក់ទៀតថាងាយស្រួលដក និង*១ឃុំទៀត នៅឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង* មានស្ត្រីសមាជិកក្រុមប្រឹក្សាឃុំ ២នាក់ ឆ្លើយចំលើយផ្ទុយគ្នាដែរ ម្នាក់មកពីគណបក្សសង្គ្រោះជាតិ ឆ្លើយថាពិបាកដក ឯម្នាក់ទៀតមកពីគណបក្សប្រជាជនកម្ពុជា ឆ្លើយថា ងាយស្រួលដក ។

ខាងក្រោមនេះគឺជាសម្តីផ្ទាល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៖

- តាមសម្តីរបស់**លោកស្រី មៀរ លី** សមាជិកក្រុមប្រឹក្សាឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំមកពីគណបក្សសមរង្ស៊ី បង្ហាញថា « *ថវិកាមានកង្វះខាតច្រើនមិនគ្រប់គ្រាន់ ពីព្រោះ បញ្ហាស្ត្រី និងកុមារមានការកើនឡើង* »។
- **លោកស្រី យ៉ាន ចំរើន** សមាជិកក្រុមប្រឹក្សាឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មកពីគណបក្សនរោត្តម រណឫទ្ធិ បានបញ្ជាក់បន្ថែមថា *«នៅឃុំនេះ មានកង្វះថវិកាសំរាប់ស្ត្រី និងកុមារច្រើន ព្រោះឃុំនេះមានបញ្ហាច្រើន ប៉ុន្តែថវិកាប្រចាំឆ្នាំសំរាប់ស្ត្រី និងកុមារ មានតែ ២លានរៀលប៉ុណ្ណោះ »* ។

សរុបសេចក្តីមក ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់បានប្រើប្រាស់សក្តានុពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានាបើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ខណៈដែលបុរសភាគច្រើនរួមទាំងផ្នត់គំនិតសង្គម មានការប្តូរឥរិយាបថមកឲ្យតម្លៃស្ត្រី យល់ថាការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្ត ជាមួយនឹងការគាំទ្រស្ទើរតែទាំងស្រុងពីក្រុមគ្រួសារ និងប្រជាពលរដ្ឋ ដែលបង្ហាញពីការយល់ដឹងអំពីយេនឌ័រក្នុងការជម្រុញ លើកទឹកចិត្តយ៉ាងខ្លាំងដល់ការចូលរួមរបស់ស្ត្រីឲ្យមានភាពកាន់តែសកម្មថែមមួយកម្រិតទៀត និងឈានទៅរកសមភាពរវាងស្ត្រី និងបុរសក្នុងកិច្ចការសង្គម ។ លើសពីនេះ បញ្ហាស្ត្រី និងកុមារក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រី ចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ ។

ទោះជាយ៉ាងនេះក្តី ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ បើទោះបីមានការថយចុះខ្លះក៏ដោយ ។ រីឯថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិត ។

## ៤. ករណីសិក្សា

### ៤.១ «សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន»

#### ករណីសិក្សាទី១

លោកស្រី ជួន ចេតនា ជាសមាជិកគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំស្ត្រី នៅឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ ក្នុងអាណត្តិទី៣ (ឆ្នាំ២០១២ ដល់ឆ្នាំ២០១៧) ដែលមានសមាជិកក្រុមប្រឹក្សាឃុំសរុប ចំនួន៧រូប (ស្ត្រី ២រូប = ២៨,៥៧%) មានពីរគណបក្សនយោបាយ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) | មកពីគណបក្សប្រជាជនកម្ពុជា | (ស្ត្រី) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១) | មកពីគណបក្សប្រជាជនកម្ពុជា | (បុរស) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២) | មកពីគណបក្សសម រង្ស៊ី | (បុរស) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | មកពីគណបក្សសម រង្ស៊ី | (បុរស) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | មកពីគណបក្សប្រជាជនកម្ពុជា | (ស្ត្រី) |
| ៦. សមាជិកក្រុមប្រឹក្សាឃុំ | មកពីគណបក្សប្រជាជនកម្ពុជា | (បុរស) |

នៅក្នុងឃុំរហ័សនេះ មានភូមិចំនួន៦ និង៥៥គ្រួសារ ដែលមានប្រជាពលរដ្ឋសរុបប្រមាណជាង ២៥៤៧នាក់ ក្នុងស្ត្រី១២៧១នាក់ ។



បច្ចុប្បន្នលោកស្រី មានអាយុ ៥៨ឆ្នាំ (១៩៦១កើតឆ្នាំ)ជាកូនកំព្រាឪពុកម្តាយដោយប៉ុលពតសំលាប់ និងមានបងប្អូនស្រីចំនួនពីរនាក់រស់នៅជាមួយម្តាយមីង ។ លោកស្រីបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៩១ដែលប្តីរបស់គាត់ជាកសិករធ្វើស្រែចម្ការ មានកូនចំនួន៥នាក់ ស្រី១នាក់ និងប្រុស៤នាក់ ។

លោកស្រីមានប្រវត្តិ បទពិសោធន៍ការងារ និងកំរិតវប្បធម៌ ដូចតទៅ៖

- ឆ្នាំ១៩៨១ រៀនថ្នាក់ទី ៤ថ្មី
- ឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៤ ចូលបំរើការងារនៅសាលាខេត្ត ក្នុងតួនាទីជាអ្នកវាយអង្គុលីលេខឲ្យ

សាលាខេត្តព្រះវិហារ

- ឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣ បំរើការងារនៅការិយាល័យស្រុករវៀង ខេត្តព្រះវិហារ ក្នុងតួនាទីជាចាត់តាំងដូចជា សម្ព័ន្ធយុវជនស្នូល។
- ឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០០ លាឈប់ពីការងារសំរាកមួយរយៈដោយសារស្ថានភាពគ្រួសារក្រីក្រ និងមានកូនក្នុងបន្ទុកត្រូវមើលថែរក្សា។
- ឆ្នាំ២០០១ បេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២

លោកស្រី **ជួន ចេតនា** បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាមកពីគណបក្សប្រជាជនកម្ពុជាចំនួន ៣អាណត្តិ គឺនៅអាណត្តិទី១ និងអាណត្តិទី២ លោកស្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំធម្មតា ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។ ដោយឡែកក្នុងអាណត្តិទី៣នេះលោកស្រីបានក្លាយជាប្រធានក្រុមប្រឹក្សាឃុំរហាស និងជាមេឃុំស្ត្រី ។

មូលហេតុដែលនាំឲ្យលោកស្រីចូលប្រឡូកក្នុងនយោបាយ ឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ ដោយសារតែមានការជម្រុញខ្លាំង និងពន្យល់ពីគណបក្សប្រជាជនកម្ពុជាថា គឺដើម្បីធ្វើការអភិវឌ្ឍន៍មូលដ្ឋាន និងដោយសារមានការជ្រោមជ្រែងពីប្តី ព្រមទាំងលោកស្រីខ្លួនឯងមានការចាប់អារម្មណ៍ដែរថា នៅក្នុងមូលដ្ឋានយើងមានការខ្វះខាតច្រើន ដូចជាផ្លូវថ្នល់ ឬធ្វើអ្វីមួយក៏ដោយ ពីព្រោះប្រជាពលរដ្ឋនៅមានការលំបាកច្រើន ក៏ដូចជាការលំបាកខ្លួនឯងផងដែរ ។ លោកស្រីបានបង្ហាញអំពីឆន្ទៈរបស់ខ្លួនថា «ខ្ញុំចង់ប្រឡូកក្នុងកិច្ចការនយោបាយ ដើម្បីជួយដល់ប្រជាពលរដ្ឋឲ្យមានជីវភាពធូរធារ កាត់បន្ថយនូវភាពក្រីក្រកន្លងមកនៅក្នុងមូលដ្ឋាននេះ គឺប្រជាពលរដ្ឋមានការលំបាកជាងគេគឺផ្លូវថ្នល់សំរាប់ធ្វើដំណើរ ។ ជាក់ស្តែង បើធ្វើដំណើរពីភូមិ ឃុំហ្នឹងទៅផ្សារគឺលំបាកណាស់ ត្រូវដើរឆ្លងទឹក ឆ្លងភក់ នេះជាផលលំបាកសំរាប់ស្ត្រី និងកុមារក្នុងការធ្វើដំណើរ ចំណាយពេលច្រើនឥតប្រយោជន៍ »។

ចំណុចខ្លាំងដែលបណ្តាលឲ្យលោកស្រី ជួន ចេតនា ក្លាយជាប្រធានក្រុមប្រឹក្សាឃុំ គឺដោយសារកាលពីក្នុងអាណត្តិទី១ និងអាណត្តិទី២ លោកស្រីត្រូវបានគណបក្សប្រជាជនកម្ពុជាអនុញ្ញាតឲ្យឈរឈ្មោះជាបេក្ខជន នៅលេខរៀងទី៤ និងលេខរៀងទី៣ ហើយបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារចំនួនពីរអាណត្តិ ។ ដោយឡែកនៅក្នុងអាណត្តិទី៣នេះ ដោយសារប្រធានក្រុមប្រឹក្សាទាំងពីរអាណត្តិមកពីគណបក្សប្រជាជនកម្ពុជា(មេឃុំចាស់) ឈ្មោះហោង ជ័យ ជាបុរសគាត់ចាស់ជរាមានបញ្ហាសុខភាព ដោយហេតុផលនោះ ខាងថ្នាក់ស្រុក ខេត្តរបស់គណបក្សប្រជាជនកម្ពុជា និងមានការណែនាំពីមេឃុំចាស់ អំពីស្នាដៃរបស់លោកស្រីកន្លងមក ព្រមទាំងមានការលើកទឹកចិត្តពីសមាជិកក្រុមប្រឹក្សាឃុំជាបុរសក្នុងបក្ស បានយល់ព្រមឯកភាពគ្នា បូកផ្សំជាមួយនឹងលោកស្រីបានដើរតួនាទីយ៉ាងសំខាន់ និងសកម្មក្នុងកិច្ចការស្ត្រី និងកុមារក្នុងអាណត្តិទី១ និងទី២កន្លងទៅ ។ ដូច្នេះហើយបក្សក៏បានរៀបចំឲ្យលោកស្រីឈរឈ្មោះជាបេក្ខជននៅលេខរៀងទី១ និងបានជាប់ឆ្នោតជាប្រធានក្រុម

ប្រឹក្សាឃុំ និងជាមេឃុំស្ត្រីសម្រាប់អាណត្តិទី៣នេះ។ លោកស្រីបានមានប្រសាសន៍ពន្យល់ថា «យើងជាស្ត្រី យើងដឹងសុខទុក្ខ ការលំបាករបស់ស្ត្រី ដូចជាស្ត្រីមានផ្ទៃពោះ ស្ត្រីសំរាលកូន សំរាលកូនរួច ជាពិសេសការអប់រំផ្នែកសុខភាព មាតា និងទារក។ល។»។ ម្យ៉ាងវិញទៀត លោកស្រីបញ្ជាក់ថា «ស្វាមីរបស់ខ្ញុំ គឺជាមនុស្សសំខាន់ដែលជាអ្នកជម្រុញលើកទឹកចិត្តខ្ញុំ ឲ្យចូលរួមក្នុងកិច្ចការសង្គម គាត់តែងតែលើកទឹកចិត្តខ្ញុំថា យើងចេះ យើងមានបទពិសោធន៍ យើងដើរតួនាទីជួយភូមិ ឃុំខ្លួនឯងឲ្យរីកចំរើនបាន »។

សម្រាប់ពេលអនាគត លោកស្រីមានឆន្ទៈចង់ធ្វើជាប្រធានក្រុមប្រឹក្សាឃុំ យ៉ាងហោចណាស់ក៏បានត្រឹមពីរអាណត្តិដែរ បើទោះបីជាបច្ចុប្បន្ននៅឃុំនេះមិនទាន់មានទីស្នាក់ការ និងការិយាល័យត្រឹមត្រូវផ្ទាល់ខ្លួនរបស់ឃុំនៅឡើយក៏ដោយ (សព្វថ្ងៃឃុំរហ័សនេះ លោកស្រីបានលះបង់ទីតាំងផ្ទះរបស់លោកស្រីផ្ទាល់សម្រាប់ឲ្យឃុំមានដំណើរការ ដោយទទួលកម្រៃឧបត្ថម្ភតិចតួចស្តួចស្តើងបំផុត) ប៉ុន្តែដោយសារចិត្តចង់ជួយប្រជាពលរដ្ឋ ចង់ជួយមូលដ្ឋានឲ្យមានការរីកចំរើន ។ មូលហេតុដែលលោកស្រីចង់បានដឹកនាំភូមិឃុំ ប្រជាពលរដ្ឋមូលដ្ឋានឲ្យបានពីរអាណត្តិ ពីព្រោះលោកស្រីយល់ថា ១អាណត្តិជារយៈពេលខ្លីពេក មិនបានចប់ចុងចប់ដើម ផែនការខ្លះមានរយៈពេលវែងត្រូវបន្ត។

ថវិកាពាក់ព័ន្ធនឹងស្ត្រី និងកុមារ លោកស្រីបានបញ្ជាក់ថា ឃុំរហ័សនេះ មិនមានបញ្ហាអ្វីឡើយដោយសារលោកស្រីមានបទពិសោធន៍ទទួលខុសត្រូវកិច្ចការងារនេះជាង១០ឆ្នាំហើយ ។ លោកស្រីមានប្រសាសន៍បន្តទៀតថា « នៅឃុំរហស័នេះ ការអនុវត្តន៍ប្រើប្រាស់ថវិកាមានតម្លាភាពទាំងអស់ » ។ ដើម្បីយកថវិកាមកប្រើប្រាស់ ត្រូវមានការប្រជុំក្រុមប្រឹក្សាពិភាក្សារៀបចំគំរោង ឬរៀបចំប្រាក់សំរាប់វិនិយោគជាមុនសិន ទោះបីជាសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សនយោបាយផ្សេងគ្នាក៏ដោយ ។ ជាក់ស្តែង គឺតាំងពីពេលដែលស្មៀនទៅបើកថវិកាបុរេប្រទានពីរដ្ឋាភិបាលតាមរយៈរតនាគារមក គឺចាប់ផ្តើមប្រជុំក្រុមប្រឹក្សាឃុំភ្លាម ធ្វើដូចនេះហើយដែលនាំឲ្យមានការជឿទុកចិត្តគ្នា មិនមានបញ្ហាចំណូលចំណាយថវិកាទេ។ ថវិកាសំរាប់កិច្ចការស្រី និងកុមារ ទទួលបាន៨០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ គឺអាចប្រើប្រាស់គ្រប់គ្រាន់ដោយសារប្រជាពលរដ្ឋក្នុងឃុំនេះមានចំនួនតិចតួច។

បច្ចុប្បន្ននេះ ឃុំរហ័សកំពុងមានភាពរមមាញឹកជាមួយសកម្មភាពស្ត្រី និងកុមារ ដូចជា សុខភាពមាតា ទារកមុន និងពេលសំរាល ការអប់រំសុខភាពអនាម័យក្នុងភូមិ និងការបញ្ជូនកូនទៅសាលារៀន។ ដោយឡែកបញ្ហាប្រឈមចំពោះមុខទូទៅជាក់ស្តែងក្នុងភូមិ គឺកំពុងមានការព្រួយបារម្ភអំពីសន្តិសុខស្បៀង ដោយសារតែអាកាសធាតុប្រែប្រួលបណ្តាលឲ្យការធ្វើស្រែ ចំការមានបញ្ហាខ្លះដែរ ដែលនាំឲ្យប៉ះពាល់ដល់ជីវភាពរបស់ពួកគាត់។

សំណូមពររបស់លោកស្រី ជួន ចេតនា «សូមឲ្យមានស្ត្រីចូលរួមក្នុងតួនាទីតាំងពីលើរហូតដល់ក្រោម យ៉ាងហោចឲ្យបាន ៣០% ឡើងទៅ តែអ្វីដែលជាការចង់បានរបស់លោកស្រីគឺ៥០% ស្មើនឹងបុរសដែរ។ ព្រោះថាស្ត្រីក៏អាចធ្វើបានដូចបុរស ហើយការងារមួយចំនួនក៏ល្អជាងបុរសផង ដូចជាការចេះគិតគូរ គឺគិតល្អជាងបុរសឆ្ងាយណាស់ »។

## ករណីសិក្សាទី២

*[ ដោយសារតែឆន្ទៈដ៏មោះមុតរបស់លោកស្រី **សួន សាមាន** បានធ្វើឲ្យស្ថានភាពផ្ទាល់របស់លោកស្រីមានការប្រែប្រួលជាវិជ្ជមាន គឺពីអ្នកគាំទ្រគណបក្សធម្មតា ទៅជាសមាជិកសកម្មរបស់គណបក្សនៅស្រុកបរិបូរណ៍ រហូតឈានដល់ដំណាក់កាលបានឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាឃុំ និងបានជាប់ឆ្នោតក្លាយជាមេឃុំស្ត្រី (ជាអ្នកដឹកនាំដ៏គំរូម្នាក់)។ ]*

លោកស្រី **សួន សាមាន** ជាសមាជិកគណបក្សសមរង្ស៊ី/គណបក្សសង្គ្រោះជាតិ(បច្ចុប្បន្ន) និងជាប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំស្ត្រី នៅឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ក្នុងអាណត្តិទី៣ (ឆ្នាំ២០១២ ដល់ឆ្នាំ២០១៧) ដែលមានសមាជិកក្រុមប្រឹក្សាឃុំសរុប ចំនួន៥រូប (ស្ត្រី ១រូប = ២០%) មានពីរគណបក្សនយោបាយ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) | មកពីគណបក្សសមរង្ស៊ី | (ស្ត្រី) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ(ជំទប់ទី១) | មកពីគណបក្សសមរង្ស៊ី | (បុរស) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ(ជំទប់ទី២) | មកពីគណបក្សប្រជាជនកម្ពុជា | (បុរស) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | មកពីគណបក្សសមរង្ស៊ី | (បុរស) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | មកពីគណបក្សប្រជាជនកម្ពុជា | (បុរស) |

នៅក្នុងឃុំត្រពាំងចាន់ មាន៨ភូមិ មានប្រជាជនប្រមាណជាង ៦០០០នាក់ ស្ត្រីជាង៤០០០នាក់ ។ នៅក្នុងស្រុកបរិបូណ៌ទាំងមូលមាន១១ឃុំ មានតែឃុំត្រពាំងចាន់នេះទេ ដែលបានបង្កើត «ប្រជាការពារភូមិ»មុនគេ។







បច្ចុប្បន្នលោកស្រី មានអាយុ ៥៤ឆ្នាំ(កើតឆ្នាំ១៩៦១) ជាកូនកំព្រាឪពុកតាំងពីអាយុ២ខែ និងម្តាយបានស្លាប់ក្នុងឆ្នាំ១៩៨៣ ។ លោកស្រីបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៨០ ប្តីរបស់គាត់ធ្លាប់ជាទាហាន ប៉ុន្តែបច្ចុប្បន្ននេះជាកសិករធ្វើស្រែចំការ និងពួកគាត់មានកូនសុទ្ធតែប្រុសទាំងអស់ចំនួន៣នាក់។

លោកស្រីមានប្រវត្តិ បទពិសោធន៍ការងារ និងកំរិតវប្បធម៌ ដូចតទៅ៖

- ឆ្នាំ១៩៧០ ដល់១៩៧៥ លោកស្រីជាសិស្សនៃសាលាបឋមសិក្សាភូមិក្រចៅ ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង រៀនរហូតបានត្រឹមថ្នាក់ទី៩ (ចាស់)។
- ឆ្នាំ១៩៧៩ ជាប្រធានគ្រប់គ្រងយុវជន យុវនារីមូលដ្ឋាននៃឃុំរ៉ុង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

លោកស្រី **សួន សាមាន** បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសម រង្ស៊ីចំនួន២អាណត្តិ គឺនៅអាណត្តិទី២ មានតួនាទីជាជំទប់ទី២ និងក្នុងអាណត្តិទី៣នេះ មានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំមេឃុំ/ស្ត្រី។

មូលហេតុដែលបណ្តាលឲ្យលោកស្រីចូលប្រឡូកក្នុងឆាកនយោបាយ លោកស្រីបានលើកឡើងថា ឆ្នាំ២០០០ស្ថានភាពពេលនោះមានទឹកជំនន់ធំ ទឹកទន្លេឡើងធំមែនទែន ធំលិចអស់ភូមិ ឃុំ ឮតែសំលេងទូក កាណូតរកស្តាប់អីមិនបាន។ ជាមួយគ្នានេះដែរ មានការយកអំណោយមកចែក ប៉ុន្តែគ្រួសារដែលលិចទឹកពិតប្រាកដមួយចំនួនធំមិនបានទទួលអំណោយទេ គឺគេចែកឲ្យតែគ្រួសារដែលជាបក្សពួករបស់គេតែប៉ុណ្ណោះ ។ ដោយសារតែមានការឈឺចាប់នឹងអ្នកដឹកនាំអត់ល្អ អត់ត្រឹមត្រូវ អ្នកកាន់ការងារគិតតែប្រយោជន៍ផ្ទាល់ខ្លួននៅកម្រិតមូលដ្ឋាន ហើយការឈឺចាប់ហាក់មិនមានការប្រសើរសោះបើទោះជាមានការបោះឆ្នោតឆ្នាំ១៩៩៣នោះហើយក៏ដោយ ។ ម្យ៉ាងវិញទៀតយើងឃើញថា បច្ចុប្បន្នក្នុងស្រុកខ្មែរយើងនេះ អ្នកដឹកនាំបានធ្វើអញ្ចឹង តែយើងបែរជាថាអ្នកដឹកនាំយើងល្អ អ្នកដឹកនាំយើងល្អៗពីមួយអាណត្តិទៅមួយអាណត្តិ មិនមានការផ្លាស់ប្តូរ មិនយូរមិនឆាប់ទេស្រុកយើង សង្គមខ្មែរនឹងវិនាសជាមិន ខាន។ គំនិត ឆន្ទៈ និងការយល់ឃើញទាំងអស់នេះហើយដែលធ្វើឲ្យសន្ទុះចិត្តរបស់លោកស្រីឡើងខ្លាំង ហើយប្រាប់ខ្លួនឯងថា «ខ្ញុំត្រូវតែធ្វើនយោបាយ» ។

ចាប់តាំងពីបានចូលជាសមាជិកគណបក្សសម រង្ស៊ីមក លោកស្រីបានទទួលការបណ្តុះបណ្តាលជាច្រើន គឺគណបក្សមានការជ្រើសរើសស្ត្រីដែលមានឆន្ទៈខ្លាំងយកមកបណ្តុះបណ្តាល អំពី ភាពជាអ្នកដឹកនាំដែលផ្តោតលើភាពទទួលខុសត្រូវ ឥរិយាបថ សីលធម៌ គួបផ្សំនឹងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ ។ ក្នុងន័យនេះ លោកស្រីបញ្ជាក់ថា បើយើងចង់ធ្វើនយោបាយ យើងមិនត្រូវរៀបចំខ្លួនខោមិនខោ អាវមិនអាវ គឺយើងធ្វើនយោបាយមិនកើតទេ គឺត្រូវចេះបត់បែន ។

លោកស្រីបានសង្កត់ធ្ងន់ថា ដើម្បីឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតពេញចិត្ត គឺលោកស្រីបានធ្វើសកម្មភាព និងឆ្លងកាត់ដំណាក់កាលជាច្រើន៖

ទី១៖ លោកស្រីហ៊ានចំណាយពេលវេលា

ទី២៖ លោកស្រីហ៊ានចំណាយធនធានរបស់ខ្លួន ដូចជាថវិកា។ល។ ធ្វើយ៉ាងណាដើម្បីប្រមូលផ្តុំអ្នកគាំទ្រ និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សជាដើម។ លោកស្រីអាចចំណាយថវិកាធនធានទាំងនោះបាន ដោយសារគាត់មានមុខរបរធ្វើស្រែហើយពេលទទួលបានផលចំណេញ ថវិកាទាំងនោះអាចយកមកប្រើប្រាស់បាន ។

ទី៣៖ មានចិត្តសណ្តោសប្រណីដល់ប្រជាពលរដ្ឋ

ទី៤៖ មានការគាំទ្រពីប្តី ពីគ្រួសារ ជាក់ស្តែងដូចជា ពេលមានរវល់ ឬមានកម្មវិធីម្តងៗជាមួយសកម្មជន និងអ្នកគាំទ្រ ប្តី និងកូនរបស់លោកស្រីតែងតែជួយដាំបាយ ធ្វើម្ហូបនៅផ្ទះ។ នេះជាចំណែកមួយដែលនាំឲ្យលោកស្រីក្លាយខ្លួនជាអ្នកដឹកនាំ ដោយការជួយជ្រោមជ្រែងពី ប្តី និងកូនៗរបស់គាត់ ។ លោកស្រីបញ្ជាក់យ៉ាងច្បាស់ថា «សំខាន់គឺគ្រួសារដែលមានបេះដូងស្អាតស្អំជួយខ្ញុំ»។

ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំស្ត្រី លោកស្រីកំពុងមមាញឹកជាមួយកិច្ចការស្ត្រី និងកុមារ ដោយជាប់រវល់ជាមួយនឹងទារកក្រោយពីសំរាលកូន ត្រូវប្រឹក្សាយោបល់ជាមួយមាតាបិតាអំពីការអប់រំ ថែទាំសុខភាពដល់មាតា និងទារក ។ អប់រំម្តាយៗឲ្យបញ្ជូនកូនទៅសាលារៀនសំរាប់កុមារដែលគ្រប់អាយុ និងអប់រំដល់ស្ត្រីដែលមិនទាន់ចេះអក្សរឲ្យទៅរៀនដោយបើកឲ្យមានសាលាអក្ខរកម្ម ។ ចំណែកឯថវិកាពាក់ព័ន្ធនឹងកិច្ចការស្ត្រី និងកុមារ ក្នុង១ឆ្នាំ ទទួលបាន ២ ៥០០ ០០០(ពីរលាន ហាសិបម៉ឺនរៀល) ដោយថវិកានេះគឺ ប្រើប្រាស់សំរាប់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដោយមានកិច្ចសហការជាមួយខាងមណ្ឌលសុខភាព ។

ដោយសារកិច្ចការងារក្នុងឃុំ មានលោកស្រីតែម្នាក់ឯងជាស្ត្រី និងជាប្រធានក្រុមប្រឹក្សាឃុំ/មេឃុំផងនោះ ធ្វើឲ្យលោកស្រីជួបការលំបាកមួយចំនួន លោកស្រីបានថ្លែងបញ្ជាក់ថា៖ ការលំបាកទី១ « ដោយសារទំលាប់ចាស់នៅតែមាន ដោយពួកគាត់ជាបុរសយល់ថា ស្ត្រីមិនអាចធ្វើអ្វីបាន មិនអាចធ្វើធំបាន មិនអាចធ្វើជាអ្នកដឹកនាំបាន គំនិតពួកគេនៅតែគិតអញ្ចឹង » ។ ការលំបាកទី២ «ពួកគាត់ជាបុរសសុទ្ធតែមានវ័យចាស់ៗជាងខ្ញុំ ក៏ជាហេតុនាំឲ្យពិបាកក្នុងការបញ្ជាបញ្ចូល និងអ្វីដែលលំបាកបំផុតនោះដោយសារជំទប់ទី២ បច្ចុប្បន្ននេះ(អាណត្តិទី៣) គាត់ធ្លាប់ជាប្រធានក្រុមប្រឹក្សាកាលពីអាណត្តិទី២ មកពីគណបក្សប្រជាជនកម្ពុជា គាត់មានវ័យចំណាស់ជាងឆ្ងាយបើធៀបជាមួយខ្ញុំ និងធ្លាប់ធ្វើជាមេរបស់ខ្ញុំផង គឺគាត់មិនព្រមចូលរួមធ្វើសកម្មភាពជាមួយខ្ញុំទេ និងបញ្ហាសមាជិកក្រុមប្រឹក្សាឃុំផ្សេងទៀតមានជំងឺញឹកញាប់»។

ភាពមោះមុត និងការតាំងចិត្តរបស់លោកស្រីនៅតែមាន បើទោះបីជាមានការរារាំង និងជួបការលំបាកដោយការមិនចូលរួមធ្វើសកម្មភាពពី ជំទប់ទី២ (អតីតមេឃុំ)មកពីគណបក្សប្រជាជនកម្ពុជាយ៉ាងណាក៏ដោយ លោកស្រីនៅតែមានទឹកចិត្តធ្វើ និងឈ្មុះឈ្មុលក្នុងការងារទាល់តែបានសម្រេច ។ ទោះយ៉ាងណាក៏ដោយ លោកស្រីបានមានប្រសាសន៍ថា «យើងត្រូវការការចូលរួម រួបរួមធ្វើការជាមួយគ្នា ព្រោះសកម្មភាពខ្លះពេលអវត្តមានជំទប់ទី២មិនមានបញ្ហាអ្វីទេ ប៉ុន្តែការងារមួយចំនួនទៀតមានការរាំងស្ទះមិន

អាចដំណើរការបានពេលដែលជំទប់ទី២មិនចូលរួមសហការ»។ ឧទាហរណ៍ជាក់ស្តែង ដូចជា ការធ្វើលទ្ធកម្មដេញថ្លៃ ការងារនេះតម្រូវឲ្យមានអាជ្ញាធរបីនាក់ចូលរួម គឺប្រធានក្រុមប្រឹក្សាឃុំ/មេឃុំ ជំទប់ទី១ និងជំទប់ទី២ ។ ដូច្នេះការមិនចូលរួមរបស់ជំទប់ទី២ នាំឲ្យស្ទះដល់ការអភិវឌ្ឍន៍។

ដើម្បីឲ្យការងារជោគជ័យ លោកស្រីមេឃុំប្រើវិធីសាស្ត្រដោះស្រាយបញ្ហា ដោយពាំនាំយកបញ្ហាណាដែលជួបប្រទះលើកទៅពិភាក្សាជាមួយថ្នាក់ស្រុកពេលប្រជុំម្តងៗ គឺលើកជារួមបង្ហាញច្បាស់លាស់អំពីបញ្ហានីមួយៗ ថាតើស្ទះមកពីបញ្ហាអ្វី? ការណ៍នេះក៏ជាផ្លូវល្អដែលនាំឲ្យមានដំណោះស្រាយពីថ្នាក់លើដែរ។ បែបម្យ៉ាងទៀត បើទោះបីជាមានបញ្ហារារាំង និងឧបសគ្គខ្លះក៏ដោយ ប៉ុន្តែលោកស្រីមានកំលាំងខ្លះនៅក្នុងសមាជិកក្រុមប្រឹក្សាឃុំ កំលាំងខ្លះនៅក្នុងសមាជិកមន្ត្រីជាប់កិច្ចសន្យា និងកំលាំងខ្លះជាមេភូមិទាំងអស់មាន៨ ទៅ ៩នាក់ដែរ ក៏រួបរួមកម្លាំងគ្នាក្នុងការធ្វើការឲ្យមោះមុត និងជោគជ័យ ។ លោកស្រីបានបង្ហាញពីមោទនភាពថា «សម្រាប់អាណត្តិទី៤ បើសិនជាខ្ញុំ នៅតែជាប់ជាប្រធានក្រុមប្រឹក្សាឃុំក្តី ឬធ្លាក់ទៅជាសមាជិកធម្មតាក្តី ឬក្លាយទៅជាប្រជាពលរដ្ឋធម្មតាក៏ដោយក្តី ក៏ខ្ញុំមិនមានបញ្ហាអ្វីទេ គឺនៅតែសប្បាយចិត្ត សំខាន់ក្នុងពេលដែលខ្ញុំកាន់តួនាទីជាប្រធានក្រុមប្រឹក្សាឃុំអាណត្តិទី៣នេះ មានការផ្លាស់ប្តូរ ។ អំពើល្អយើងបានធ្វើរួចទៅហើយ ដោយយើងមិនចាំតែថវិការបស់ឃុំប៉ុណ្ណោះទេ គឺយើងចេះស្វែងរកដៃគូរអភិវឌ្ឍន៍ ព្រះសង្ឃ អាចារ្យវត្តរួមគ្នាជាឯកច្ឆ័ន្ទមួយក្នុងការអភិវឌ្ឍន៍ ផ្លូវថ្នល់ ជាដើម» ។

លោកស្រីមានការតាំងចិត្តថា បើយោងតាមសកម្មភាពការងារអភិវឌ្ឍន៍សព្វថ្ងៃនេះ លោកស្រីមានការគាំទ្រពីប្រជាពលរដ្ឋច្រើនលើសលប់ ប៉ុន្តែលោកស្រីមិនហ៊ានធានា មិនហ៊ានថាទេ ព្រោះជីវិតនយោបាយមិនអមតៈ ។ លោកស្រីបានបញ្ជាក់ថា «ប្រសិនបើការបោះឆ្នោត ឆ្នាំ២០១៧ អាណត្តិទី៤ ប្រជាពលរដ្ឋលោកគាំទ្រខ្ញុំទៀត ខ្ញុំនឹងខិតខំអភិវឌ្ឍន៍ឃុំនេះឲ្យបានល្អប្រសើរឡើង ខ្ញុំមានគំនិតទុកជាស្រេចហើយ គឺចង់ពង្រីកមូលដ្ឋាន ដោយសារក្នុងឃុំមានសហគមន៍ព្រៃឈើជិតមួយពាន់ហិចតា ដូច្នេះ ខ្ញុំចង់ឲ្យប្រជាពលរដ្ឋក្នុងសហគមន៍មានមុខរបរគ្រប់ៗគ្នា។ សម្រាប់៥ឆ្នាំទៅមុខទៀត យើងនឹងទទួលបានផល (ទី១) អាចហូតអុសតែផ្នែដាក់ក្នុងឡ ពីព្រោះបច្ចុប្បន្ននេះ ឃុំមានឡរួចហើយ មានដៃគូរធ្វើឲ្យដោយចំណាយប្រាក់អស់ប្រហែល១០០០០ដុល្លារ (មួយម៉ឺនដុល្លារអាមេរិក) និងបានកំណត់រួចជាស្រេចថា ទុកអភិរក្សប៉ុន្មានហិចតា ត្រូវហូតជាអាជីវកម្មប៉ុន្មានហិចតា ដោយមានការចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ»។

លោកស្រីបានមានសំណូមពរថា «សូមឲ្យរដ្ឋាភិបាល បង្កើនកញ្ចប់ថវិកាឃុំក្នុងមួយឆ្នាំឲ្យបាន យ៉ាងតិចបំផុតត្រឹម ៣០០ ០០០ ០០០ (បីរយលានរៀល) និងសូមឲ្យរដ្ឋាភិបាលបើកបេះដូងឲ្យទូលាយ កុំគិតថា គណបក្សភាគតិច គណបក្សភាគច្រើន កុំប្រកាន់និន្នាកាគណបក្សនយោបាយ សូមឲ្យមានសមភាពរវាងគណបក្សនយោបាយ សូមឲ្យមានបេក្ខភាពស្ត្រីច្រើនជាក្រុមប្រឹក្សាឃុំសម្រាប់អាណត្តិក្រោយ ដើម្បីមានការងាយស្រួលក្នុងការងារអភិវឌ្ឍន៍ឃុំ»។

### ៤.២. «ភាពបរាជ័យរបស់ស្ត្រីបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន»

### ករណីសិក្សាទី៣

លោកស្រី សា សេត ជាសមាជិកក្រុមប្រឹក្សាឃុំ និងជាជំទប់ទី២ឃុំមកពីគណបក្សសមរង្ស៊ី/គណបក្សសង្គ្រោះជាតិ(បច្ចុប្បន្ន) នៅឃុំស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ក្នុងអាណត្តិទី៣ (ឆ្នាំ២០១២ ដល់ឆ្នាំ២០១៧) ដែលមានសមាជិកក្រុមប្រឹក្សាឃុំសរុបចំនួន៥រូប (ស្ត្រី ១រូប = ២០%) មានពីរគណបក្សនយោបាយៈ

១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) មកពីគណបក្សប្រជាជនកម្ពុជា (បុរស)
២. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១) មកពីគណបក្សប្រជាជនកម្ពុជា (បុរស)
៣. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២) មកពីគណបក្សសមរង្ស៊ី (ស្ត្រី)
៤. សមាជិកក្រុមប្រឹក្សាឃុំ មកពីគណបក្សសមរង្ស៊ី (បុរស)
៥. សមាជិកក្រុមប្រឹក្សាឃុំ មកពីគណបក្សប្រជាជនកម្ពុជា (បុរស)




បច្ចុប្បន្នលោកស្រី មានអាយុ ៥៣ឆ្នាំ(កើតឆ្នាំ១៩៦២) ឪពុកជាជនពិការ ម្តាយស្លាប់ ហើយលោកស្រីបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៨០ ប្តីគាត់ជាកសិករធ្វើស្រែចំការ មានកូនចំនួន៧នាក់(ប្រុស៣នាក់ និងស្រី៤នាក់) រៀបការអស់ចំនួន៥នាក់ ។

លោកស្រីមានប្រវត្តិ បទពិសោធន៍ការងារ និងកំរិតវប្បធម៌ ដូចតទៅៈ

- លោកស្រី មិនដែលបានចូលសាលា មិនមានការសិក្សាអ្វីទេពីមុន
- ឆ្នាំ២០០៧ ចូលរៀនអក្ខរកម្មជាមួយអង្គការ ការីតាស់ រយៈពេល៦ខែ ទើបចេះអាន ស្គាល់អក្សរ

ខ្លះៗ

លោកស្រី សា សេត ទើបតែបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសម រង្ស៊ី សម្រាប់អាណត្តិទី៣នេះ ក្នុងតួនាទីជាជំទប់ទី២ ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ។

មូលហេតុដែលលោកស្រី ចូលប្រឡូកក្នុងវិស័យនយោបាយ និងក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ ដោយសារកាលពីឆ្នាំ២០១០ មានបញ្ហារំលោភបំពានដីធ្លីរបស់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរ ធ្វើឲ្យប្រជាពលរដ្ឋមិនសុខចិត្តក៏នាំគ្នាប្រមូលផ្តុំ ដើម្បីធ្វើពាក្យបណ្តឹង ដោយមានការផ្តិតជាស្នាមមេដៃ ។ បន្ទាប់មកក៏មានខាងស្រុកចុះមក ក្នុងន័យបន្លំយកស្នាមមេដៃរបស់ប្រជាពលរដ្ឋ។ ដោយហេតុនោះ លោកស្រី សា សេត និងប្រជាជនក្នុងភូមិតាបោះ ឃុំស្តៅនេះ ប្រមាណ២៥នាក់ ទាមទារដកយកស្នាមមេដៃរបស់ប្រជាពលរដ្ឋនោះមកវិញ ប៉ុន្តែខាងស្រុកព្យាយាមគេចវេស ។ លោកស្រីបន្តថា លោកស្រីក៏បានចេញមុខក្នុងការទាមទារស្នាមមេដៃនោះ រហូតបានជោគជ័យ ។ លោកស្រីកាន់តែមានភាពក្លាហាន និងជាអ្នកយកឯកសារទាំងនោះទៅប្តឹងតាមមន្ទីរដល់ថ្នាក់ខេត្ត និងយកញត្តិទៅដល់រាជធានីភ្នំពេញ ដោយបានដឹកនាំប្រជាពលរដ្ឋប្រមាណ២០០នាក់ ទៅកាន់គេហដ្ឋានសម្តេច ហ៊ុន សែន ។ ដោយសារការឈឺចាប់ខ្លាំងជាមួយប្រជាពលរដ្ឋផ្សេងទៀត និងមានការគាំទ្រ និងយល់ឃើញពីប្រជាពលរដ្ឋថា « ខ្ញុំអាចជួយដោះស្រាយបញ្ហាពួកគាត់បាន អាចធ្វើជាតំណាងពួកគាត់បាន » ។ ដូច្នេះលោកស្រីក៏ទំនាក់ទំនងសុំចូលជាសមាជិកគណបក្សសម រង្ស៊ី និងបានឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ អាណត្តិទី៣នេះ ហើយក៏បានជាប់ឆ្នោតជាជំទប់ទី២ ។ ទោះជាយ៉ាងនេះក្តី លោកស្រីបញ្ជាក់យ៉ាងច្បាស់អំពីខ្លួនឯងថា « ខ្ញុំមិនចេះអ្វីច្រើនទេ គ្រាន់តែមានចិត្ត មានមនសិកា ចង់ជួយប្រជាពលរដ្ឋ » ។

លោកស្រីបញ្ជាក់ថា បច្ចុប្បន្ននៅឃុំស្តៅនេះ កំពុងមានសកម្មភាពមមាញឹកទាក់ទងនឹងកិច្ចការស្ត្រី និងកុមារ ។ ជាមួយគ្នានេះដែរ លោកស្រីក៏ញមានការកង្វល់ជាមួយបញ្ហាទូទៅនៅក្នុងឃុំនេះ គឺដោយសារប្រជាពលរដ្ឋចេះតែចង់ធ្វើបាតុកម្ម ដូចជាភូមិតាបោះ ។ ម្យ៉ាងវិញទៀត នៅក្នុងជួរក្រុមប្រឹក្សាឃុំ និងប្រធានក្រុមប្រឹក្សាឃុំជាញឹកញាប់បានចោទប្រកាន់មកលើរូបលោកស្រីថា គណបក្សសម រង្ស៊ី (គណបក្សសង្គ្រោះជាតិ) កេងចំណេញនយោបាយ ចោទថាលោកស្រីជាអ្នកបំផុសបំផុល ជាអ្នករុញច្រាន អូសទាញ និងជាអ្នកអុចអាលប្រជាពលរដ្ឋឲ្យធ្វើបាតុកម្ម ប៉ុន្តែលោកស្រីបញ្ជាក់ថា «នៅពេលដែលមានប្រជាពលរដ្ឋចង់ធ្វើបាតុកម្មមករកខ្ញុំ គឺខ្ញុំគ្រាន់តែជួយសួរនាំ ជួយសំរួលដល់ពួកគេប៉ុណ្ណោះ ។ ជាក់ស្តែងពួកគាត់មានបញ្ហាដីធ្លីសរុបប្រមាណ ១៣ ៧០០ហិចតា ស្ទើរទាំងអស់នៃប្រជាជនទាំង៥ភូមិ »។ ការចោទប្រកាន់ទាំងនេះ បានធ្វើឲ្យលោកស្រីមានការភ័យខ្លាច និងបារម្ភអំពីសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួនជាខ្លាំង ។

ទោះស្ថិតក្នុងតួនាទីជាជំទប់ទី២ និងជាសមាជិកក្រុមប្រឹក្សាឃុំស្តៅនៃស្រុកសង្គមថ្មីក៏ដោយ លោកស្រីមិនសូវជាដឹងអំពីថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារទេ ។ លោកស្រីបញ្ជាក់ថា «ថវិកាទាំងនោះមិនមានតម្លាភាពនៅឡើយ» ពីព្រោះថវិកាទាំងនោះមិនបានផ្សព្វផ្សាយ ឬបិទជាព័ត៌មានអ្វី ឬប្រជុំធ្វើបទ

បង្ហាញអ្វីទេ ។ ថវិកានោះស្ថិតក្នុងការគ្រប់គ្រងរបស់ស្មៀនទាំងអស់ ពេលមានគំរោងចង់ចំណាយចាយវាយអ្វីម្តងៗ តែងមានការជជែកឈ្លោះប្រកែកតមាត់គ្នា ឯស្មៀនវិញតែងតែថាចាំថ្ងៃនេះថ្ងៃនោះ ដល់យូរៗទៅប្រាប់ថាថវិកានោះអស់ រីឯរបាយការណ៍ក៏មិនមាន ។ ជាទំលាប់តែងតែចាយវាយតាមអំពើចិត្តមុនហើយបានគិតថាចង់ធ្វើរបាយការណ៍ មិនសូវប្រជុំធ្វើផែនការចាយវាយជាមួយគ្នាទេ។ លោកស្រីបញ្ជាក់ទៀតថា « ថវិកានោះជាទូទៅមិនចំណាយចំគោលដៅទេ ពីព្រោះ(ទី១) ថវិកានោះមិនមានតម្លាភាព (ទី២) ពេលចាយវាយគ្មានការពិភាក្សារៀបចំផែនការ (ទី៣) ចំណាយមុនគំរោង (ទី៤) ចាយវាយគ្មាការឯកភាពគ្មានរបាយការណ៍ចំណាយ » ។ ដូច្នេះហើយដល់ពេលសួរនាំ ស្មៀនឆ្លើយថា ស្ត្រី និងកុមារមិនសូវមានបញ្ហា បើមិនយកថវិកានោះមកចាយ នាំឲ្យថវិកានោះនៅសល់ ហេតុនេះចេះតែយកវាមកចំណាយលើការប្រជុំ ការធ្វើថ្នល់ ផ្សេងៗ ។ល។ លោកស្រីបញ្ជាក់បន្ថែមថា « នៅថ្នាក់ឃុំ តួនាទីជាប្រធានក្រុមប្រឹក្សាឃុំមានតួនាទីធំជាងគេក្នុងច្បាប់ តែការអនុវត្តជាក់ស្តែង គឺស្មៀនធំជាងប្រធានក្រុមប្រឹក្សាឃុំមិនឈ្នះស្មៀនទេ »។

លោកស្រីបានសំណូមពរថា « **សូមឲ្យរដ្ឋាភិបាលជួយរកដំណោះស្រាយបញ្ហាជូនប្រជាពលរដ្ឋក្នុងភូមិ ឃុំនេះ** »។

**<u>សូមបញ្ជាក់ថា</u>** ស្ថានភាពនៅក្នុងឃុំស្តៅ ក្នុងស្រុកសង្គមថ្មីទាំងមូល ហាក់មានការរឹតត្បឹតខ្លាំងដោយមានការបំបិទសិទ្ធិមិនឲ្យមានអង្គការណាអាចចូលមកធ្វើសកម្មភាព ឬចង់ធ្វើការអភិវឌ្ឍន៍បានឡើយ លើកលែងតែអង្គការការីតាស និងអង្គការទស្សនៈពិភពលោក ប៉ុណ្ណោះ។ ជាក់ស្តែង ពេលដែលតំណាងបុគ្គលិកនៃអង្គការខុមហ្វ្រែលបានចុះធ្វើករណីសិក្សានៅឃុំចំនួនពីរ ឃុំចំរើន និងឃុំស្តៅ គឺមានការរារាំងមិនឲ្យធ្វើសកម្មភាពសម្ភាសន៍ សាកសួរអ្វីបានឡើយ ពីព្រោះអភិបាលស្រុកសង្គមថ្មីមិនអនុញ្ញាត្តិ។ លោកស្រី សា សេត បានបញ្ជាក់ថា រាល់ពេលមានប្រជុំម្តងៗជាមួយថ្នាក់ស្រុក លោកអភិបាលស្រុកតែងតែហាមប្រាម និងប្រាប់ជារឿយៗ ថាមិនត្រូវអនុញ្ញាតិឲ្យជួបជាមួយអង្គការណា ឬស្ថាប័នណាទេ ទោះបីជាការទំនាក់ទំនង ឬកិច្ចសម្ភាសន៍ក្តី សូម្បីតែការផ្តល់បទសម្ភាសន៍ជាមួយខុមហ្វ្រែលនេះ គឺធ្វើជាលក្ខណៈលួចលាក់ បើចូលតាមឃុំ ស្រុកពិតជាមិនអាចបានទេ និងដោយសារលោកស្រីជាសមាជិកគណបក្ស សម រង្ស៊ី ។ ម្យ៉ាងទៀត លោកស្រីតស៊ូយូរណាស់មកហើយ គឺតាំងពីឆ្នាំ២០១០មកម្ល៉េះរហូតដល់ពេលនេះលែងខ្លាចស្លាប់ហើយ។

# III. ចំនួនស្រ្តីក្នុងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ( ស្ថិតិ និងតួនាទី )

*ការកើនឡើងចំនួនស្ត្រីនៅថ្នាក់ធ្វើសេចក្តីសម្រេចនៅមានកម្រិត ខណៈដែលបុរសនៅតែមានចំនួនច្រើនលើសលុបក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត.*[13] ។

## ១. ព្រឹទ្ធសភា

តំណាងស្រ្តីនៅក្នុងស្ថាប័នព្រឹទ្ធសភាមិនមានការប្រែប្រួលជាវិជ្ជមានទេ គិតចាប់ពីអាណត្តិទី១(ឆ្នាំ១៩៩៩) អាណត្តិទី២ (ឆ្នាំ២០០៥) និងអាណត្តិទី៣ (ឆ្នាំ២០១២) គឺនៅតែមានចំនួនដដែល ៩នាក់ (១៤,៧៥%) ប៉ុន្តែក្នុងឆ្នាំ២០១៥ សមាជិកព្រឹទ្ធសភាជាស្ត្រីកើនដល់១០នាក់ (១៦,៣៩%) នៃចំនួនសរុប ៦១នាក់

## ២. រដ្ឋសភា

*ចំនួនអ្នកតំណាងរាស្ត្រស្ត្រី បន្តធ្លាក់ចុះ ក្នុងឆ្នាំ២០១៥*

ឆ្នាំ២០១៥ ចំនួនអ្នកតំណាងរាស្ត្រស្ត្រី**បន្តធ្លាក់ចុះ**មកត្រឹម **២៤នាក់ (១៩,៥១%)**នៃអ្នកតំណាងរាស្ត្រសរុប១២៣នាក់ ។ ការបន្តធ្លាក់ចុះអ្នកតំណាងរាស្ត្រស្ត្រីនេះ ដោយសារតែសភាជាតិពុំមានគោលនយោបាយលើកកម្ពស់ស្ត្រីនៅក្នុងស្ថាប័នកំពូលមួយនេះ ដើម្បីរក្សាការពារចំនួនដែលមានស្រាប់ និងក្នុងការបង្កើនចំនួនតំណាងរាស្ត្រស្ត្រី ខណៈដែលការអនុវត្តរបស់ស្ថាប័ននេះគឺដើរស្របតាមខ្សែបន្ទាត់នយោបាយរបស់គណបក្សតែប៉ុណ្ណោះ ។ ជាក់ស្តែង **លោកជំទាវ ចែម សាវៃ** ជាតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានសុំលាលែងពីតំណែងដោយសារមានជំងឺ និងមានការសំរេចឲ្យលាលែងពីតំណែងដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ ។ ជាមួយគ្នានេះដែរ រដ្ឋសភាបានប្រកាសសុពលភាពអ្នកតំណាងរាស្ត្រថ្មីជំនួស**លោកជំទាវ ចែម សាវៃ** គឺ **ឯកឧត្តម កែវ ពិសិដ្ឋ** មកពីគណបក្សប្រជាជនកម្ពុជា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ ។ ការណ៍នេះ បង្ហាញឲ្យ

[13] សុន្ទរកថាស្វាគមន៍របស់លោកជំទាវ វេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងវេទិកាជាតិ ស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

ឃើញថា អ្នកដឹកនាំសភាជាតិមិនមានការយល់ដឹងអំពីយេនឌ័រ (Gender Sensitive) និងពុំមានការប្តេជ្ញាចិត្តខ្ពស់ដូចស្ថាប័ននីតិប្រតិបត្តិ ដែលបានកំណត់ចំនួនជាក់លាក់នៅក្នុងគោលនយោបាយរបស់ខ្លួន *«ត្រូវធានាក្របខណ្ឌពី២០% ទៅ ៥០%ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មីជាស្ត្រី និងដាក់ស្ត្រីជំនួសមន្ត្រីរាជការណាដែលចូលនិវត្តន៍*[14] » ដើម្បីអនុវត្ត និងខិតខំលើកស្ទួយដល់ការចូលរួមរបស់ស្ត្រី ក្នុងគោលបំណងធ្វើឲ្យមានសមភាពយេនឌ័រនៅកម្ពុជាស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ។

ក្នុងចំណោមតំណាងរាស្ត្រស្ត្រីទាំង២៨នាក់ បច្ចុប្បន្នមានចំនួនតែ **១៧នាក់ (១៩,៥៤%)**ប៉ុណ្ណោះនៃចំនួនសរុបបុរស-ស្ត្រី៨៧នាក់ត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មការទាំង១០នៃរដ្ឋសភា នីតិកាលទី៥ នេះ ក្នុងនោះមានតួនាទីជាប្រធាននៃគណៈកម្មការទី៨ និងទី៩ ចំនួន២នាក់ (២០%)នៃចំនួនសរុប១០នាក់ ។ តួនាទីជាអនុប្រធានចំនួន១នាក់(១០%)នៃចំនួនសរុប១០នាក់ និងមានចំនួនច្រើន ៦នាក់ (៦០%)នៃចំនួនសរុប១០នាក់មានតួនាទីជាលេខាធិការ ។

## ៣. រដ្ឋាភិបាល

*ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមានការកើនឡើងក្នុងឆ្នាំ២០១៣*

- ឧបនាយករដ្ឋមន្ត្រីស្ត្រីចំនួន**១នាក់ (១១,១១%)**ក្នុងចំណោម៩នាក់ ប៉ុន្តែមិនមានស្ត្រីក្នុងមុខតំណែងជាទេសរដ្ឋមន្ត្រី (សូន្យក្នុងចំណោមទេសរដ្ឋមន្ត្រីចំនួន១៥នាក់) ។
- រដ្ឋមន្ត្រីស្ត្រីចំនួន**៣នាក់ (១០,៧១%)**ក្នុងចំណោម២៨នាក់ដែលមានការកើនឡើងពី ៧,១៤% (២នាក់)ក្នុងចំណោម២៨នាក់ ក្នុងឆ្នាំ២០០៨ ។
- មានការតែងតាំងស្ត្រីក្នុងតំណែងរដ្ឋលេខាធិការយ៉ាងតិចចំនួន១នាក់ និងអនុរដ្ឋលេខាធិការយ៉ាងតិចចំនួន ១នាក់នៅគ្រប់ក្រសួង ស្ថាប័ននីមួយៗ ។ ចំនួនរដ្ឋលេខាធិការស្ត្រីមានការកើនឡើង ១២,៤៦% (២២នាក់)ពី៨,០៨% (១៦នាក់)ក្នុងចំណោម១៩៨នាក់នៅឆ្នាំ២០០៨ ទៅ ២០,៥៤% (៣៨នាក់)ក្នុងចំណោម១៨៥នាក់ នៅឆ្នាំ២០១៣ ។

[14] ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទវេទិកាជាតិស្តីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ។

- អនុរដ្ឋលេខាធិការជាស្ត្រី មានការកើនឡើងប្រមាណ ២% (១៥នាក់) ពី ១៦,០៩% (៣៣នាក់)ក្នុងចំណោម២០៥នាក់ នៅឆ្នាំ២០០៨ ទៅ ១៧,៥៨% (៤៨នាក់)ក្នុងចំណោម២៧៣នាក់ នៅឆ្នាំ២០១៣ ។

## ៤. តុលាការ

*សមាមាត្រស្ត្រីក្នុងស្ថាប័នតុលាការមានការកើនឡើងចាប់ពីឆ្នាំ២០០៨ ប៉ុន្តែតំណែងស្ត្រីមានតិចក្នុងការគ្រប់គ្រងកម្រិតនៃស្ថាប័នតុលាការ*

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនស្ត្រីមានការកើនឡើង ប៉ុន្តែបុរសនៅមានចំនួនច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងស្ថាប័នតុលាការ។

- ឆ្នាំ២០១៣ នៅស្ថាប័នតុលាការ មានចៅក្រមជាស្ត្រី ១៣,៩៦% (៣៧នាក់)ក្នុងចំណោម២៦៥នាក់ ដែលមានការកើនឡើងបន្តិចបន្តួចពី១៣,២០%ក្នុងឆ្នាំ២០១០។ ប្រទេសកម្ពុជាកំពុងឈានទៅជិតសម្រេចបាននូវគោលដៅផែនការយុទ្ធសាស្ត្រនារីរតនៈទី៣ ដែលបានកំណត់ថា មានចៅក្រមជាស្ត្រីចំនួន ១៥%ក្នុងឆ្នាំ២០១៣។ ផ្ទុយទៅវិញ មិនមានតំណាងស្ត្រីជាប្រធានឡើយ ។
- ព្រះរាជអាជ្ញាជាស្ត្រីមាន១០,២០% (១៥នាក់) ក្នុងចំណោម១៤៧នាក់ ។ ដូចនេះ ចំនួនព្រះរាជអាជ្ញាជាស្ត្រីបានកើនឡើងចំនួន៨% ចាប់ពីឆ្នាំ២០១០មក។
- ស្ត្រីជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកគណៈមេធាវី មាន ១៤,៨០% (៤នាក់) ក្នុងចំណោម២៧នាក់ (ក្នុងអាណត្តិទី៧ ឆ្នាំ២០១២-២០១៧) ។
- ក្នុងរយៈពេល៣ឆ្នាំកន្លងទៅចំនួនស្ត្រីដែលប្រកបវិជ្ជាជីវៈមេធាវីមានការថយចុះពី១៨% (៩៨នាក់) ក្នុងចំណោម៥៥១នាក់ នៅឆ្នាំ២០១០ មក ១៧,៦០% (១២៦នាក់)ក្នុងចំណោម៧១៦នាក់ នៅឆ្នាំ២០១៣ ។

## ៥. ថ្នាក់ក្រោមជាតិ

*បុរសមានចំនួនច្រើនក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅតាមរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ*

- បច្ចុប្បន្ននេះ មិនទាន់មានស្ត្រីជាអភិបាលរាជធានី ខេត្ត នៅឡើយ

- អភិបាលរងរាជធានី ខេត្តជាស្ត្រីមាន ២១% (២៥នាក់)ក្នុងចំណោម១១៩នាក់
- អភិបាលក្រុង ស្រុក ខណ្ឌជាស្ត្រី មានចំនួន ១,៥២% (៣នាក់) ក្នុងចំណោម១៩៧នាក់
- អភិបាលរងក្រុង ស្រុក ខណ្ឌជាស្ត្រី ចំនួន ៣០,៥៥% (១៩៤នាក់)ក្នុងចំណោម៦៣៥នាក់
- ស្ត្រីជាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានការកើនឡើងតិចតួច ចំនួន **១៣,៧៧% (៤៥៨នាក់)**ក្នុងចំណោម**៣៣២៤នាក់** សម្រាប់អាណត្តិទី២ ឆ្នាំ២០១៤ ក្នុងនោះក្រុមប្រឹក្សារាជធានី ខេត្តជាស្ត្រី មានចំនួន ១៣,២៣% (៥២នាក់)ក្នុងចំណោម៣៩៣នាក់ បើធៀបនឹងអាណត្តិទី១(ឆ្នាំ ២០០៩)មានចំនួនតែ ១០,១៦% (៣៨នាក់)ក្នុងចំណោម៣៧៤នាក់ ។ ចំណែកឯ ស្ត្រីជាក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ មានការកើនឡើងតិចតួចដែរ ១៣,៨៥% (៤០៦នាក់)ក្នុងចំណោម២៩៣១នាក់ សម្រាប់អាណត្តិទី២ ឆ្នាំ២០១៤ បើធៀបនឹងអាណត្តិទី១ ឆ្នាំ២០០៩ ស្ត្រីមាន ១២,៦៨% (៣៦៣ នាក់)ក្នុងចំណោម២៨៦១នាក់ ។

## ៦. ក្រុមប្រឹក្សាឃុំ សង្កាត់

*ចំនួនមេឃុំ ចៅសង្កាត់ស្ត្រី កើនឡើងបន្តិច ក្នុងឆ្នាំ២០១៥*

- ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី មានការ**កើនឡើងបន្តិចចំនួន ២០៥១នាក់ស្មើនឹង ១៧,៨៩%**ក្នុងចំណោម១១ ៤៥៩នាក់ ក្នុងឆ្នាំ២០១៥នេះ ធៀបនឹងឆ្នាំ២០១៤ មានចំនួនតែ២០៣៨នាក់ (១៧,៧៨%) ។
- **គឺកើនឡើង**ចំនួន មេឃុំ ចៅសង្កាត់ជាស្ត្រី **៦,៦១% ស្មើនឹង ១០៨នាក់** ដែលឆ្នាំ២០១៤ មានតែ ៩៥នាក់ (៥,៨១%) ប៉ុណ្ណោះ ។ ការកើនឡើងនេះ ដោយសារតែប្រធានក្រុមប្រឹក្សាជាបុរសខ្លះត្រូវបានលាលែងពីតំណែង ដូចជា មេឃុំ/ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ខ្លះស្លាប់ ខ្លះទៀតលាលែងពីតួនាទីដោយសារមានជំងឺមិនអាចធ្វើការបាន ឯខ្លះទៀតចាស់ខ្លាំងពេក។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានតំណាងតិចក្នុងមុខតំណែងធ្វើសេចក្តីសម្រេចសំខាន់មួយនេះ ថ្វីបើមានការកើនឡើងបន្តិចក្នុងឆ្នាំ២០១៥នេះក៏ដោយ ។
- ជំទប់ទី១ជាស្ត្រី មាន១១,៥៧% (១៨៩នាក់)
- ជំទប់ទី២ជាស្ត្រី មាន ១០,០៤% (១៦៤នាក់) ។

## IV. សេចក្តីសន្និដ្ឋាន និងសង្ខេប

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **តិចជាង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៧០,៨៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៧នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ តិចជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន ៧៧,៧៧% ស្មើនឹង៧៧នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម**បានថយចុះ** ពី៨៤%ឆ្នាំ២០១៤ មកត្រឹម ៧០,៨៣%ឆ្នាំ២០១៥ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មមានការ**កើនឡើងតិចតួចបំផុត** គឺពី ៧៦,៥៣%ឆ្នាំ២០១៤ ទៅ ៧៧,៧៧%ឆ្នាំ២០១៥ ។

ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានចុះបេសកកម្មមានចំនួន **៧០,៥៩%** (១២នាក់ក្នុងចំណោម១៧នាក់) **ច្រើនជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលមានចំនួនតែ**៥៨,៨២%** (៣០នាក់ក្នុងចំណោម៥១នាក់) ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** គឺពី ៨៣,៣៣% ឆ្នាំ២០១៤ មកត្រឹម ៧០,៥៩% ឆ្នាំ២០១៥ ។ រីឯភាគរយអ្នកតំណាងរាស្ត្របុរសក៏មានការ**ថយចុះដែរ** ពី ៧០% ឆ្នាំ២០១៤ មកត្រឹម ៥៨,៨២%ឆ្នាំ២០១៥ ។

ផ្ទុយទៅវិញ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ **តិចជាង**ភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួនដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង **៧១,៤៣%** (៥នាក់ ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួនដល់ទៅ**៩៧,៩២%** (៤៧នាក់ក្នុងចំណោម៤៨នាក់) ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ** ពី ៨៥,៧១% ឆ្នាំ២០១៤ មកត្រឹម៧១,៤៣% ឆ្នាំ២០១៥ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសមានការ**កើនឡើងខ្ពស់**គួរឲ្យកត់សម្គាល់ ពី៨៣,៣៣% ឆ្នាំ២០១៤ ទៅ ៩៧,៩២% ឆ្នាំ២០១៥ ។

គោលបំណងនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី **នៅតែ**មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន*

***១៨១លើក (៨០,៨៥%)*** *ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ* ***៥លើក (២,២២%)****ប៉ុណ្ណោះ។* តួលេខនេះបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានាមានការ****កើនឡើង*** *ខណៈដែលសកម្មភាពចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ មានការ****ថយចុះ****ទៅវិញ ។*

តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **តិចជាង** តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ។

ឆ្នាំ២០១៥ ចំនួនអ្នកតំណាងរាស្ត្រស្ត្រី**បន្តធ្លាក់ចុះ**មកត្រឹម **២៥នាក់ (១៩,៥១%)**នៃអ្នកតំណាងរាស្ត្រសរុប១២៣នាក់ ។ ការបន្តធ្លាក់ចុះអ្នកតំណាងរាស្ត្រស្ត្រីនេះ ដោយសារតែសភាជាតិពុំមានគោលនយោបាយលើកកម្ពស់ស្ត្រីនៅក្នុងស្ថាប័នកំពូលមួយនេះ ដើម្បីរក្សាការពារចំនួនដែលមានស្រាប់ និងក្នុងការបង្កើនចំនួនតំណាងរាស្ត្រស្ត្រី ខណៈដែលការអនុវត្តរបស់ស្ថាប័ននេះគឺដើរស្របតាមខ្សែបន្ទាត់នយោបាយរបស់គណបក្សតែប៉ុណ្ណោះ ។

ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ មានការ**កើនឡើងបន្តិចចំនួន** **២០៥១នាក់ស្មើនឹង ១៧,៨៩%** ក្នុងចំណោម ១១ ៤៥៩នាក់ ក្នុងឆ្នាំ២០១៥នេះ គឺ កើនមេឃុំ ចៅសង្កាត់ជាស្ត្រី ចំនួន **៦,៦១% ស្មើនឹង ១០៨នាក់** ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានតំណាងតិចក្នុងមុខតំណែងធ្វើសេចក្តីសម្រេចសំខាន់មួយនេះ ។

រដ្ឋសភាបានអនុម័តឲ្យមាន «ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី **(Women Parliamentarian Caucus)សមាជិការដ្ឋសភា»** ដែលហៅកាត់ថា **«កសកនស»**ជាផ្លូវការ ដោយមានសមាសភាពស្ត្រីជាតំណាងរាស្ត្រចំនួន៨រូបដែលជាក្បាលម៉ាស៊ីនដឹកនាំ ក្នុងនោះ៤រូបមកពីគណបក្សប្រជាជនកម្ពុជា និង ៤រូបទៀតមកពីគណបក្សសង្គ្រោះជាតិ និងមានសមាជិកាមកពីគណបក្សទាំងពីរដែលមានអាសនៈនៅក្នុងរដ្ឋសភា សរុបចំនួន ២៣រូប ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ទាក់ទងនឹងការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយត្រូវបានបរាជ័យ ។ ការបរាជ័យនេះ មូលហេតុចំបងដោយសារ ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរទាំងនៅក្នុងគណបក្សនយោបាយ និងនៅក្នុងច្បាប់បោះឆ្នោតក្នុងការកំណត់ចំនួនស្ត្រីច្បាស់លាស់សម្រាប់ការឈរឈ្មោះជាបេក្ខជន ក្នុងការបោះឆ្នោត បើទោះបីមានការបង្ហាញពីភាពរីកចម្រើនខ្លះក៏ដោយ ។

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុរទៅលើការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ឆ្នាំទី២ ក្នុងឆ្នាំ២០១៥ទាក់ទងនឹង***ការបំពេញ ឬ***

*អនុវត្តគោលនយោបាយពង្រឹងស្ថានភាព និង តួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួល បានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន* ជាលទ្ធផលបង្ហាញថា ម្ចាស់ឆ្នោត*ពេញចិត្តខ្លះចំនួន៣០,៦៧%* ដែលជាភាគរយខ្ពស់ជាងគេ ។ ភាគរយខ្ពស់បន្ទាប់ គឺ***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច*** *ចំនួន២៧,៦៣%* និង***ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល*** *ចំនួន២០,៦១%* ។ រីឯ ភាគរយទាបជាងគេ គឺ ***ពេញចិត្តច្រើន*** *ចំនួន១១,៣២%* និង***ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង****មានចំនួនតែ៨,១៤%* ប៉ុណ្ណោះ ។ តួលេខនេះ បង្ហាញឲ្យឃើញថា ម្ចាស់ឆ្នោតនៅពុំទាន់ពេញចិត្តនៅឡើយចំពោះរដ្ឋាភិបាលក្នុងការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានពិតប្រាកដ ។

ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយបើទោះបីមានការថយចុះខ្លះក៏ដោយ ។

៨២,៩២%បានការគាំទ្រ និងលើកទឹកចិត្តពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រីដោយយល់ថា ស្ត្រីជាដៃគូដ៏សំខាន់មិនអាចខ្វះបាន ស្ត្រីធ្វើការងារសម្រេចបានដូចបុរសដែរ ។ ចំណែកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួនឯងបាន និងកំពុងប្រើប្រាស់សក្តានុពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានា បើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់ ។ លើសពីនេះ បញ្ហាស្ត្រី និងកុមារក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រីចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់ ។

ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ ។

# ផ្នែក

# ឧបសម្ព័ន្ធ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦

# លទ្ធផលនៃការសង្កេតដោយសង្ខេប

## ស្តីពី ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖

## សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

របាយការណ៍ប្រចាំឆ្នាំ២០១៥នេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រផ្អែកលើការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាព និងការងាររបស់តំណាងស្ត្រីជាប់ឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការបំពេញការងាររបស់រាជរដ្ឋាភិបាលទាក់ទងនឹងកម្មវិធីនយោបាយស្តីពីបញ្ហាស្ត្រី និងកុមារ។

សំណួរចម្បង គឺតើស្ត្រីជាប់ឆ្នោតទាំងនោះធ្វើការបានលទ្ធផលយ៉ាងណាខ្លះ? មានការរើសអើងដែរឬទេ? តើអ្វីជាការប្រឈមរបស់ពួកគាត់? និងមូលហេតុអ្វី? ថាតើការពារការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញ និងទទួលបាននូវតួនាទី ភារកិច្ចស្របតាមច្បាប់ និងសិទ្ធិអំណាចពេញលេញបានកម្រិតណា?។ តើអ្វីខ្លះជាការបំពេញរបស់រដ្ឋាភិបាល ស្តីពីគោលនយោបាយទាក់ទងនឹងស្ត្រី និងកុមារ?

ការរកឃើញសំខាន់ៗ រួមមាន តំណាងរាស្ត្រចំនួន**៩៤នាក់ (ស្ត្រី១៧នាក់ និងបុរស៧៧នាក់)** ក្នុងនោះ ៤២នាក់មកពីគណបក្សប្រជាជនកម្ពុជាមាន**ស្ត្រី១២នាក់** និង**៥២**នាក់មកពីគណបក្សសង្គ្រោះជាតិ មាន**ស្ត្រី៥នាក់** ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១១០៧លើក** ចំនួននេះថយចុះចំនួន១៦៧លើក ពី១២៧៤លើកឆ្នាំ២០១៤ មកត្រឹម១១០៧លើកឆ្នាំ២០១៥។ អ្នកតំណាងរាស្ត្រស្ត្រីទាំង១៧នាក់នៃគណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន២៥០លើក។ ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយ។ ការរើសអើងនេះ មានការថយចុះពី១៩,៣៥%ឆ្នាំ២០១៤ មកត្រឹម១២,១៩%ឆ្នាំ២០១៥។ ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានលំបាក ក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ។ បន្ថែមលើនេះទៀត ម្ចាស់ឆ្នោតនៅពុំទាន់ពេញចិត្តនៅឡើយ ចំពោះរដ្ឋាភិបាលក្នុងការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹង ស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានពិតប្រាកដ។

ការបង្ហាញរបាយការណ៍សង្ខេបមានដូចជា *(១)ការចុះមូលដ្ឋាន(ការចុះតាមមណ្ឌល) របស់អ្នកតំណាងរាស្ត្រស្ត្រី (២)ការអភិវឌ្ឍន៍នៃចំនួនស្ត្រីជាប់ឆ្នោត (៣)ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលទាក់ទង នឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបញ្ហាស្ត្រី និងកុមារ (៤)ស្ថានភាព ស្តីពីការរើសអើងប្រឆាំងនឹងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និង(៥)ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ។*

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

**១. ការចុះមូលដ្ឋាន (ការចុះតាមមណ្ឌល)របស់អ្នកតំណាងរាស្ត្រស្រ្តី**

មានតំណាងរាស្ត្រចំនួន**៩៤នាក់ (ស្រ្តី១៧នាក់ និងបុរស៧៧នាក់)** ក្នុងនោះ **៤២នាក់**មកពីគណបក្ស ប្រជាជនកម្ពុជា មាន**ស្រ្តី១២នាក់** និង**៥២នាក់**មកពីគណបក្សសង្គ្រោះជាតិ មាន**ស្រ្តី៥នាក់** ក្នុងចំណោមតំណាងរាស្ត្រ១២៣នាក់ បានចុះមូលដ្ឋានសរុបចំនួន**១១០៧លើក** (គណបក្សប្រជាជនកម្ពុជាចំនួន**២៨៧**លើក ស្មើនឹង**២៥,៨៤%** និងគណបក្សសង្គ្រោះជាតិចំនួន**៨២១លើក** ស្មើនឹង**៧៤,១៦%)**។ ចំនួននេះថយចុះចំនួន១៦៧លើក ពី១២៧៤លើក ឆ្នាំ២០១៤ មកត្រឹម១១០៧លើក ឆ្នាំ២០១៥។

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង១៧នាក់នៃគណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន២៥០លើក ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខចែក អំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន១៩៧លើក ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន១៧លើក ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន១៧លើក និងការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិលចំនួន១២លើក ព្រមទាំងការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមាន៧លើក*។ ចំនួនសកម្មភាពនេះ មានការកើនឡើងបន្តិចចំនួន១២លើក **ពី២៣៨លើក** ឆ្នាំ២០១៤ ទៅ**២៥០លើក** ឆ្នាំ២០១៥ ។

បើប្រៀបធៀបពីគោលបំណងមួយ ទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការខុសគ្នាឆ្ងាយរវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**១៩៧លើក(៧៨,៨០%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានចំនួនតែ**៧លើក (២,៨០%)**ប៉ុណ្ណោះ*។ តួលេខនេះបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានការកើនឡើងចំនួន៧៥លើក ពី១២២លើកឆ្នាំ២០១៤ ទៅ១៩៧លើកឆ្នាំ២០១៥ ខណៈដែលសកម្មភាពចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋមានការថយចុះទៅវិញ ពី១២លើក ឆ្នាំ២០១៤ មកត្រឹមតែ៧លើក ឆ្នាំ២០១៥*។

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រី បានចុះបេសកកម្ម តិចជាងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ៧០,៨៣% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៧នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៤នាក់ តិចជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន៧៧,៧៧% ស្មើនឹង៧៧នាក់ ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយរបស់អ្នកតំណាងរាស្ត្រស្ត្រី ចុះបេសកកម្មបានថយចុះពី៨៤%ឆ្នាំ២០១៤ មកត្រឹម៧០,៨៣%ឆ្នាំ២០១៥ ខណៈដែលអ្នកតំណាងរាស្ត្របុរសចុះបេសកកម្ម មានការកើនឡើងតិចតួចបំផុត គឺពី៧៦,៥៣%ឆ្នាំ២០១៤ ទៅ៧៧,៧៧%ឆ្នាំ២០១៥។

ដោយធ្វើការប្រៀបធៀបនៅក្នុងគណបក្ស របាយការណ៍ឃ្លាំមើលរបស់ខុមហ្វ្រែលរកឃើញថា ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានចុះបេសកកម្មមានចំនួន**៧០,៥៩%** (១២នាក់ក្នុងចំណោម១៧នាក់) ច្រើនជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួន ដែលមានចំនួនតែ**៥៨,៨២%** (៣០នាក់ក្នុងចំណោម៥១នាក់)ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋានមានការ**ថយចុះ** គឺពី៨៣,៣៣% ឆ្នាំ២០១៤ មកត្រឹម៧០,៥៩% ឆ្នាំ២០១៥។ រីឯភាគរយអ្នកតំណាងរាស្ត្របុរសក៏មានការ**ថយចុះដែរ** ពី៧០% ឆ្នាំ២០១៤ មកត្រឹម៥៨,៨២%ឆ្នាំ២០១៥។

ផ្ទុយទៅវិញ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ តិចជាងភាគរយរបស់អ្នកតំណាងរាស្ត្របុរសនៃគណបក្សរបស់ខ្លួន ដែលបានចុះបេសកកម្ម គឺភាគរយស្ត្រីស្មើនឹង**៧១,៤៣%** (៥នាក់ក្នុងចំណោម៧នាក់) និងភាគរយបុរសមានចំនួនដល់ទៅ**៩៧,៩២%** (៤៧នាក់ក្នុងចំណោម៤៨នាក់)។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មតាមមូលដ្ឋាន មានការ**ថយចុះ**ពី៨៥,៧១% ឆ្នាំ២០១៤ មកត្រឹម៧១,៤៣% ឆ្នាំ២០១៥ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរស មានការ**កើនឡើងខ្ពស់** គួរឲ្យកត់សម្គាល់ពី៨៣,៣៣% ឆ្នាំ២០១៤ ទៅ៩៧,៩២% ឆ្នាំ២០១៥។

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានក្នុងឆ្នាំ២០១៥ តំណាងរាស្ត្រស្ត្រីមកពី គណបក្សប្រជាជនកម្ពុជាចុះធ្វើសកម្មភាពនៅមូលដ្ឋានបាន **តិចជាង**តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ។ ជាក់ស្តែង តំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជាចំនួន១២នាក់ បានធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួនតែ៨៥លើក គឺមានការ**ថយចុះជាងពាក់កណ្តាល**ចំនួន បើធៀបនឹងឆ្នាំ២០១៤ មានចំនួន១៥នាក់ បានធ្វើសកម្មភាពនៅមូលដ្ឋាន ចំនួន១៨២លើក។ ផ្ទុយទៅវិញ តំណាងរាស្ត្រស្ត្រីមកពីគណបក្សសង្គ្រោះជាតិ៥នាក់ បានខិតខំធ្វើសកម្មភាពនៅមូលដ្ឋានដល់ទៅ១៦៥លើក ក្នុងឆ្នាំ២០១៥ **គឺកើនឡើងទ្វេដង** បើធៀបនឹងឆ្នាំ២០១៤ មានចំនួន៦នាក់បានតែ៥៦លើកប៉ុណ្ណោះ។

ការ**ថយចុះ**ចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេស**តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា** ក្នុងរយៈពេលនេះការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា *(ទី១)តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាខ្វះ កិច្ចសហការក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន ទាំងការចុះមូលដ្ឋាន និងសកម្មភាពនៅរដ្ឋសភា (ទី២) តំណាងរាស្ត្រមួយចំនួន មិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងមានការយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះរួមមាន មន្ត្រីអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាពច្រើនហើយ* និង*(ទី៣) ការិយាល័យតំណាងរាស្ត្របំពេញការងាររបស់ខ្លួនមិនបានពេញលេញ*។ ដោយឡែក សកម្មភាព**តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ** មានការ**កើនឡើង** ក៏ព្រោះតែមិនសូវមានសកម្មភាពការងារចំពោះកិច្ចនៅរដ្ឋសភា មានបញ្ហាអំពីការដកតំណែងដកអភ័យឯកសិទ្ធិអ្នកដឹកនាំនៃតំណាងរាស្ត្ររបស់ខ្លួន និងបានធ្វើពហិការមិនចូលកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះ មានពេលវេលាចុះទៅមូលដ្ឋានបានច្រើន[1]។

## ២. ការអភិវឌ្ឍន៍នៃចំនួនស្ត្រីជាប់ឆ្នោត

### តំណាងរាស្ត្រស្ត្រីធ្លាក់ចុះ

ឆ្នាំ២០១៥ ចំនួនអ្នកតំណាងរាស្ត្រស្ត្រីបន្ត**ធ្លាក់ចុះ**មកត្រឹម **២៤នាក់ (១៩,៥១%)**នៃអ្នកតំណាងរាស្ត្រសរុប ១២៣នាក់។ ការបន្តធ្លាក់ចុះអ្នកតំណាងរាស្ត្រស្ត្រីនេះ ដោយសារតែសភាជាតិពុំមានគោលនយោបាយលើកកម្ពស់ស្ត្រីនៅក្នុងស្ថាប័នកំពូលមួយនេះ ដើម្បីរក្សាការពារចំនួនដែលមានស្រាប់ និងក្នុងការបង្កើនចំនួនតំណាងរាស្ត្រស្ត្រី ខណៈដែលការអនុវត្តន៍របស់ស្ថាប័ននេះ គឺដើរស្របតាមខ្សែបន្ទាត់នយោបាយរបស់គណបក្សតែប៉ុណ្ណោះ។ ជាក់ស្តែង **លោកជំទាវ ចែម សាវៃ** ជាតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រជាជនកម្ពុជា បានសុំលាលែងពីតំណែង ដោយសារមានជំងឺ និងមានការសំរេចឲ្យលាលែងពីតំណែងដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ ។ ជាមួយគ្នានេះដែរ រដ្ឋសភាបានប្រកាសសុពលភាពអ្នកតំណាងរាស្ត្រថ្មីជំនួស**លោកជំទាវ ចែម សាវៃ គឺឯកឧត្តម**

[1] សេចក្តីប្រកាសព័ត៌មានរបស់ខុមហ្វ្រែល ស្តីពី «ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២នៃនីតិកាលទី៥» កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

**វ៉េង ពិសិដ្ឋ** មកពីគណបក្សប្រជាជនកម្ពុជា នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥។ ការណ៍នេះបង្ហាញឲ្យឃើញថា អ្នកដឹកនាំសភាជាតិ មិនមានការយល់ដឹងអំពីយេនឌ័រ ឬរំញោចយេនឌ័រ (Gender Sensitive) និងពុំមានការប្ដេជ្ញាចិត្តខ្ពស់ដូចស្ថាប័ននីតិប្រតិបត្តិ ដែលបានកំណត់ចំនួនជាក់លាក់នៅក្នុងគោលនយោបាយរបស់ខ្លួន ***«ត្រូវធានាក្រុមខណ្ឌពី២០% ទៅ ៥០%ក្នុងការជ្រើសរើសមន្ត្រីរាជការថ្មីជាស្ត្រី និងដាក់ស្ត្រីជំនួសមន្ត្រីរាជការណាដែលចូលនិវត្តន៍[2]»*** ដើម្បីអនុវត្ត និងខិតខំលើកស្ទួយដល់ការចូលរួមរបស់ស្ត្រី ក្នុងគោលបំណងធ្វើឲ្យមានសមភាពយេនឌ័រនៅកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

**ចំនួនស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់កើនឡើង**

ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការ**កើនឡើងបន្តិចចំនួន២០៥១នាក់ស្មើនឹង១៧,៨៩%** ក្នុងចំណោម១១ ៤៥៩នាក់ ក្នុងឆ្នាំ២០១៥នេះ គឺកើនមេឃុំ ចៅសង្កាត់ជាស្ត្រីចំនួន**៦,៦១% ស្មើនឹង១០៨នាក់** ដែលឆ្នាំ២០១៤ មានតែ ៩៥នាក់ប៉ុណ្ណោះ។ ការកើនឡើងនេះ ដោយសារតែប្រធានក្រុមប្រឹក្សាជាបុរសខ្លះស្លាប់ ខ្លះទៀតលាលែងពីតួនាទី ដោយសារមានជំងឺ មិនអាចធ្វើការបាន ឯខ្លះទៀតចាស់ខ្លាំងពេក។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានចំនួនតិចក្នុងមុខតំណែងធ្វើសេចក្ដីសម្រេចសំខាន់មួយនេះ ថ្វីបើមានការកើនឡើងបន្តិចក្នុងឆ្នាំ២០១៥នេះក៏ដោយ។

**៣. ការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ទាក់ទងនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបញ្ហាស្ត្រី និងកុមារ**

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា [Cambodian Millennium Development Goals (CMDG)] ទាក់ទងនឹងការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្ដីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយត្រូវបានបរាជ័យ។ ជាក់ស្ដែងឆ្នាំ ២០១៥ តំណាងរាស្ត្រស្ត្រីមានចំនួនតែ១៩,៥១% និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១៧,៨៩% ដែលCMDG បានកំណត់ថា នៅឆ្នាំ២០១៥ *«មន្ត្រីជាប់ឆ្នោតជាស្ត្រីនៅថ្នាក់ជាតិយ៉ាងតិច៣០% និងថ្នាក់ឃុំ សង្កាត់២៥%»*។ ការពុំសំរេចបានតាមគោលដៅនេះ មូលហេតុចំបងដោយសារ ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរ ទាំងនៅក្នុងគណបក្សនយោបាយ និងនៅក្នុងច្បាប់បោះឆ្នោត ក្នុងការកំណត់ចំនួនស្ត្រីច្បាស់លាស់សម្រាប់ការឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត បើទោះបីមានការបង្ហាញពីភាពរីកចម្រើនខ្លះក៏ដោយ។

[3]ទោះបីជាប្រទេសកម្ពុជាបានធ្វើឲ្យមានភាពជឿនលឿនខ្លះទាក់ទងនឹងសមភាពយេនឌ័រ រួមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រីក៏ដោយ ក៏យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយបណ្ដើរៗបន្ថែមទៀត ដែលក្នុងនោះរួមមាន៖ (១)ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងក្នុងវិស័យសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ។ (២)វិសមភាពយេនឌ័រនៅមាននៅឡើយក្នុងវិស័យអប់រំ ជាពិសេសនៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ (៣)បញ្ហាសុខភាពស្ត្រី អាហារូបត្ថម្ភ អត្រាស្លាប់របស់ម្ដាយនៅតែជាបញ្ហាប្រឈមដ៏សំខាន់ បើប្រៀបធៀបទៅនឹងប្រទេសដទៃនៅក្នុងតំបន់។ (៤)ការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារីទៅតាមនីតិវិធីតុលាការ និងផ្លូវច្បាប់ ព្រមទាំងការផ្ដល់សេវាជួយជនរងគ្រោះ នៅពុំទាន់បានរលូន និងមិនទាន់ពេលវេលានៅឡើយ។

យោងតាមរបាយការណ៍ឃ្លាំមើលរដ្ឋាភិបាល អាណត្តិទី៥របស់ខុមហ្វ្រែល ម្ចាស់ឆ្នោតបានផ្ដល់ពិន្ទុនៅទូទាំង

[2] ប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទវេទិកាជាតិស្ដីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥។

[3] សុន្ទរកថាសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងពិធីបិទវេទិកាជាតិស្ដីពី *«ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ»* កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥។

២៤រាជធានី ខេត្តទៅលើការបំពេញកម្មវិធីនយោបាយរបស់រដ្ឋាភិបាលឆ្នាំទី២ ក្នុងឆ្នាំ២០១៥ទាក់ទងនឹង***ការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋាន*** ជាលទ្ធផលបង្ហាញថា ម្ចាស់ឆ្នោត***ពេញចិត្តខ្លះ****ចំនួន៣០,៦៧% (២០៨នាក់)* ដែលជាភាគរយខ្ពស់ជាងគេ។ ភាគរយខ្ពស់បន្ទាប់ គឺ***មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច****ចំនួន២៧,៦៣%(១២០នាក់)* និង***ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល*** *ចំនួន២០,៦១%(១៨៦នាក់)* ។ រីឯភាគរយទាបជាងគេ គឺ***ពេញចិត្តច្រើន****ចំនួន១១,៣២%(១២៧នាក់)* និង***ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង****ចំនួនតែ៨.១៤%(៧២នាក់)*ប៉ុណ្ណោះ។ តួលេខនេះបង្ហាញឲ្យឃើញថា ម្ចាស់ឆ្នោតនៅពុំទាន់ពេញចិត្តនៅឡើយ ចំពោះរដ្ឋាភិបាលក្នុងការបំពេញ ឬអនុវត្តគោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានពិតប្រាកដ។

## ៤. ស្ថានភាព ស្ដីពីការរើសអើងប្រឆាំងនឹងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយ បើទោះបីមានការថយចុះខ្លះក៏ដោយ។ ជាក់ស្តែង បុរសក្រុមប្រឹក្សាឃុំ សង្កាត់នៅតែរើសអើង និងមិនចង់សហការជាមួយស្ត្រី និងមានការរិះគន់ចំពោះស្ត្រីនៅឡើយ។ ការរើសអើងមានការថយចុះ គឺពី១៩,៣៥% ឆ្នាំ២០១៤ មកត្រឹម១២,១៩% ឆ្នាំ២០១៥។ តាមសំដីរបស់លោកស្រី ជា សុខុន សមាជិកក្រុមប្រឹក្សាឃុំដំរីជាន់ខ្លា ក្រុងស្ទឹងសែន មកពីគណបក្សប្រជាជនកម្ពុជា បញ្ជាក់ថា *«អាកប្បកិរិយារបស់បុរសហាក់មិនចង់សហការ មានការរើសអើងជាមួយពួកគាត់ ដែលជាស្ត្រីក្រុមប្រឹក្សាឃុំ ដោយពួកបុរសគិតថា ស្ត្រីសមត្ថភាពនៅអន់ការយល់ដឹងនៅមានកម្រិត»*។

ទោះបីជាយ៉ាងណាក៏ដោយ តាមការសិក្សា ៨២,៩២%បានការគាំទ្រ និងលើកទឹកចិត្តពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមានការផ្លាស់ប្ដូរអាកប្បកិរិយាឲ្យតម្លៃស្ត្រី ដោយយល់ថា ស្ត្រីជាដៃគូដ៏សំខាន់មិនអាចខ្វះបាន ស្ត្រីធ្វើការងារសម្រេចបានដូចបុរសដែរ។ ចំណែកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួនឯង បានប្រើប្រាស់សក្ដានុពលរបស់ខ្លួន មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានា បើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្ដោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់។

ចំណែកឯការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្ត្រី ស្របតាមតួនាទីរបស់ខ្លួននោះ របាយការណ៍ខុមហ្វ្រែលរកឃើញថា ប្រធានក្រុមប្រឹក្សាបានប្រគល់តែភារកិច្ចការងារខ្លះៗប៉ុណ្ណោះ ជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការរើសអើងប្រគល់តែភារកិច្ចខ្លះៗនេះ មានការថយពី ១៦,១២% ឆ្នាំ២០១៤ មកត្រឹម៩,៧៥%ឆ្នាំ២០១៥។

បើទោះបីតួលេខរើសអើងនេះ មានការថយចុះក៏ដោយ ក៏នៅតែបង្ហាញនូវការបន្តភាពរើសអើង និងនៅតែជាបញ្ហាបន្ទាន់ ដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ ចំពោះសមាជិកក្រុមប្រឹក្សាណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនពេញលេញ ដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្ដីពី *«ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់»* ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។

## ៥. ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ

ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះមិនបានទទួលថវិកា និងឃុំខ្លះទៀតនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ។

តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់មួយចំនួន។ ការមិនសូវមានតម្លាភាពថវិកានេះ ដោយសារកញ្ចប់ថវិការបស់ពួកគេមានការលាក់បាំងខ្លះៗ។ ឃុំ សង្កាត់ខ្លះថវិកាទាំងនោះមិនបានផ្សព្វផ្សាយ ឬបិទជាព័ត៌មាន ឬប្រជុំធ្វើបទបង្ហាញអ្វីឡើយ។ ជាក់ស្តែងនៅក្នុងឃុំចំនួន៤ ដូចជា***ឃុំស្គៅ*** *ស្រុកសង្គមថ្មី ខេត្តព្រះវិហារ* ថវិកាស្ថិតក្នុងការគ្រប់គ្រងរបស់ស្មៀនទាំងអស់ សមាជិកក្រុមប្រឹក្សាហាក់មិនដឹង ពេលមានគំរោងចង់ចំណាយលើកិច្ចការស្ត្រី និងកុមារម្តងៗ តែងមានការជជែកឈ្លោះប្រកែកតមាត់គ្នា។ ***ឃុំត្បូងក្រពើ*** *ស្រុកសន្ទុក ខេត្តកំពង់ធំ* សមាជិកក្រុមប្រឹក្សាឃុំមិនដឹងអំពីថវិកាមានប៉ុន្មាននោះទេ។ ***ឃុំអភិវឌ្ឍន៍*** *ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង* ពុំដែលដឹងថា មានថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ក៏ប៉ុន្តែបានថវិកាពីUNFPAចំនួន៥០០ដុល្លារអាមេរិក តែបច្ចុប្បន្នគេផ្តាច់វិញហើយ។ រីឯ ***ឃុំផ្សារឆ្នាំង*** *ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង* ពុំដែលមានថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារទេ។

ក្នុងចំណោម២៥ឃុំ មាន **១៧ឃុំ** មានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ។ ឯ **១០ឃុំ**ទៀតមានការ**ពិបាក**ក្នុងការដកថវិកាពីរតនាគារ ការទទួលបានថវិកានៅមានភាពយឺតយ៉ាវ និងស្មៀនមិនបើកថវិកាឲ្យគ្រប់ចំនួនតាមគំរោង។ ឃុំទាំង៩ដែលពិបាកដកថវិកា មានដូចជា*ឃុំស្គៅ* (ស្រុកសង្គមថ្មី ខេត្តព្រះវិហារ) *ឃុំត្បូងក្រពើ* (ស្រុកសន្ទុក ខេត្តកំពង់ធំ) *សង្កាត់កំពង់ធំ* និង *សង្កាត់អូរកន្ធរ* (ក្រុងស្ទឹងសែន ខេត្តកំពង់ធំ) *ឃុំទួលសុគី និងឃុំចក* (ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ) *ឃុំក្រាំងស្គារ និងឃុំអភិវឌ្ឍន៍* (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង) *ឃុំកំពង់ឆ្នាំង និងឃុំផ្សារឆ្នាំង* (ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង)។ គួរកត់សម្គាល់ថា មាន២ឃុំ សង្កាត់ក្នុងចំណោម២៥ឃុំ សង្កាត់ បានផ្តល់ចម្លើយផ្ទុយគ្នា ជាក់ស្តែង*១ឃុំនៅសង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ* ស្ត្រីសមាជិកក្រុមប្រឹក្សាសង្កាត់២នាក់មកពីគណបក្សប្រជាជនកម្ពុជា បានឆ្លើយផ្ទុយគ្នា ម្នាក់ថាពិបាក ម្នាក់ទៀតថា ងាយស្រួលដក និង *១ឃុំទៀត នៅឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង* មានស្ត្រីសមាជិកក្រុមប្រឹក្សាឃុំ២នាក់ ឆ្លើយចំលើយផ្ទុយគ្នាដែរ ម្នាក់មកពីគណបក្សសង្គ្រោះជាតិ ឆ្លើយថាពិបាកដក ឯម្នាក់ទៀតមកពីគណបក្សប្រជាជនកម្ពុជា ឆ្លើយថា ងាយស្រួលដក។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

១. លោកស្រី **សីនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រ ០១៧ ៤៩ ៤០ ០៤
២. លោក **គីម ឈន** អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល ០១៧ ៩៤ ២០ ១៩

**<u>បេសកកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមស្រប ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសក្តានុពលរួមរបស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលពង្រឹងនូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក លើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

*February 25, 2016*

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**A summary of Findings**
**On**
**Political Gender Watch Report: Assembly and Women Parliamentarians' and Empowerment of Women Commune Councilors in their performance at local levels**

This 2015 annual report is based upon observation, monitoring, and evaluation of the situation and performance of elected female parliamentarians at the national and local levels. And also government's fulfillment of its political platform concerning women's and children's issues.

The key questions included are: What achievements have been made? Are they discriminated against? What challenges do they face and why? How much protection is afforded them by the authorities and law regarding their participation in political decision making, leadership and performance? What is the government's policy regarding the fulfillment of promises related to women's and children's issues?

The key findings included data related to 1107 field visits made by 94 of 123 MPs, (17 female and 77 male), 42 MPs from CPP (12 female) and 52 from CNRP (5 female). This number is 167 less decreased than the 1274 visits made in 2014. 17 female MPs who have seats in the NA conducted 250 visits. Based on critical observation, the discrimination against female commune councilors still exists. The rate of discrimination decreased from 19.35% in 2014 to 12.19% in 2015. In some communes there is no budget for women's and children's affairs. In some it is difficult to access. In others it is received late and some don't receive enough. Overall transparency concerning budgets is still limited.

A summary of this report covers (1) visits to constituencies made by female MPs (2) a change in the number of female elected candidates, (3) the government's fulfillment of the Cambodian millennium development goals and women's and children's issues, (4) the situation regarding discrimination against female commune/sangkat councilors, and (5)the budget for women's and children's affairs.

**1. Constituencies Visits**

Ninety four MPs from both parties (17 female and 77 male) including 42 from CPP (12 female) and 52 from CNRP (5 female), conducted 1107 visits (287 or 25.84% made by CPP and 821 equal to 74.16% by CNRP). This number decreased by 167 times from 1274 visits in 2014 to 1107 in 2015.

In the period of report, seventeen female MPs who have seats in the NA conducted 250 visits including 197 attending meetings, visits, gift-giving and inauguration, 17 accompanying the leader, 17 strengthening the internal organization and its network, 12 attending public forums and 7 intervening and solving problems. This rate slightly increased by 12 times from 238 times in 2014 to 250 in 2015.

By comparison with the purposes of female elected parliamentarians, it showed that there were far more differences between the number of meetings, gift-giving and inaugurations, which amounted 197 times or 78.80%, and the number of interventions and solving problems, which only amounted to 7 times or 2.80% of the total number of visits. This figure shows an increase by 75 the number of visits involving meetings, gift-giving and inauguration from 122 in 2014 to 197 in 2015. There was a decrease in interventions made by female parliamentarians from 12 in 2014 to 7 in 2015.

The total percentage of field missions made by the female MPs' is less than those of their male counterparts: 70.83% made by 17 of 24 female MPs while 77.77% were made by 77 of 99 male parliamentarians. However, by comparison with 2014, this decreased from 84% in 2014 to 70.83% in 2015. Meanwhile, the percentage made by the male MPs also slightly increased from 76.53% in 2014 to 77.77% in 2015.

ទីស្នាក់ការកណ្តាល៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

By comparison with the party, this report indicated that the percentage of missions made by CPP female MPs (12 of 17 CPP female) are equal to 70.59%. This rate is higher than that of male MPs (30 of 51 CPP male) at 58.82%. By comparison with 2014, the percentage of missions made by the female CPP MPs decreased from 83.33% in 2014 to 70.59% in 2015 while the rate made by the male also decreased from 70% in 2014 to 58.82% in 2015.

At the same time, the percentage of missions made by the female MP from CNRP is less than the males at 71.43% made by 5 of 7 female MPs while 97.92% made by the 47 of 48 male MPs. By comparison with 2014, this rate decreased from 85.71% in 2014 to 71.43 in 2015 while the male visits highly increased from 83.33 to 97.92% in 2015.

Based on data received by COMFREL observers in 2015, the number of field visits made by the CPP female MPs is less than the CNRP. In fact, 12 CPP female MPs conducted 85 visits, which was half of the number when compared to 2014. 15 MPs made 182 visits. At the same time, 5 CNRP female MPs conducted 165 visits, which increased by three time compared to 2014, there were 6 MPs did only 56 visits.

There was decrease in the number of constituency visits made by MPs, in particular MPs from CPP, due to the following reasons; (1) Lacking cooperation from CPP MPs providing data related to the field visits and working activities in the NA, (2) Some CPP MPs did not really focus on their constituencies visits because they thought that these have been done by local authorities, working groups, government officials, and (3) the offices of MPs have not worked well. However, it was noted that the numbers of field visits made by CNRP MPs increased because there was a little work in the NA, after the removal of the CNRP top leadership from the first vice president in the NA. This led to a boycott of several NA sessions made by CNRP. Therefore, the CNRP had available time to conduct more field visits. The voters are still not satisfied with government performance regarding these issues.

**2. A change in the number of female elected candidates**

**A decrease in the number of female parliamentarians**

In 2015, the number of female MPs decreased by 24 (19.51%) out of 123 MPs in the NA. This decline in the number of female MPs was because the NA does not have clear policy to promote the women in order to keep the existing number while the practice of this body just followed the order of its political party. For instance, H.E. Mrs Cheam Savaiy, female elected parliamentarian from CPP, resigned as member of NA due to her health condition and an agreement on her resignation from the steering committee on 03 July 2015. Furthermore, the NA replaced her membership with H.E. Keo Piseth from CPP and publicly declared his validity on 06 July 2015. It meant that the president of NA does not have a concept of gender or gender sensitive and lack of commitment as the executive body, which clearly set in its policy "to ensure the framework from 20%-30% in selecting the female civil servants and replace the retired staff with female candidates" to practice and promote the women's participation aiming at contributing to gender equity in Cambodia in accordance with sustainable development goals of the United Nations.

**An increase in the number of female commune councilors**

The number of female commune councilors slightly increased by 2051 people (17.89%) among 11,459 commune councilors in 2015. This increased the number of commune/sangkat chiefs by 108 or 6.61%, there were 95 in 2014 because some chairmen of commune councilors had passed away, some had resigned due to illness and some had retired. Although the number of female commune councilors has increased, it still represents a small number.

**3. Government's fulfillment of its commitment of Cambodian millennium development goals and women's and children's issues**

The Cambodian millennium development goals (CMDG) regarding women's participation in decision-making in public and political sectors is a failure. In 2015, the number of female MPs was only 19.51% while the number of female commune/sangkat councilors was 17.89%. These fall short of the goals of the CMDG which state that "At least 30% of female MPs in the national level and 25% of female commune councilors in local level by 2015." This failure was due to a lack of written specific political party policy the election law which failed to specify the precise number of women candidates. Although there was some progress.

Although Cambodia made progress regarding gender equity and women empowerment, there are some challenges such as (1) women's participation in public, political and economic sector is limited, (2)

gender inequality still exists in the education sector, in particular in secondary high schools, (3) women's health, nutrition, mortality of mother are still a big concern compared to other countries and (4) addressing violence against women and girls in accordance with legal proceedings and providing health services to help the victims, which is limited.

Based on the 2015 annual 'Government Watch' report for the 5th mandate produced by COMFREL, voters in 24 provinces and capitals have a chance to score the government's performance in fulfilling political platform promises in the 2nd year, 2015 relating to performance and implementation of policy to strengthen the situation and role of women in the society, to enhance the morality and value of Cambodian women and any policies to provide basic rights for children. As a result, COMFREL found that 208 voters had "some satisfaction" or about 30.67%, with government's performance, which is the highest percentage. For the next score, 120 voters stated "no satisfaction" or "a little satisfaction" equal to 27.36%, while 186 scored "medium satisfaction" equivalent to 20.61%. The lowest score is "satisfaction", which has 11.32% with 127 votes and "almost satisfaction", which is 8.14% with 72 votes. This figure showed that the voters are still not satisfied with government performance regarding these issues.

**4. The situation of the discrimination against the female commune/sangkat councilors**

Discrimination against female commune councilors continued to exist although there was some decrease in the number of recorded incidents. In reality, the male commune/sangkat councilors still discriminate, don't cooperate and criticize female councilors. By comparison with 2014, the rate of discrimination decreased from 19.35% in 2014 to 12.19 in 2015. In an interview with Mrs. Chea Sokhom, a Domrey Chhonkla CPP commune councilor, she said that "the male commune councilors seemed not to cooperate with and still discriminate against the female because they think that the female's capacity and understanding are limited."

However, the result of interview showed that 82.92% of male commune councilors supported, encouraged and changed their behavior. They seemed to value them as important partners who are just as capable as their male counterparts. In addition, they use their capacity, confidence; bravery to express their opinion in the work place and meetings although challenges remain. Their tasks and opinions served the women's and children's interests.

Providing the tasks to female commune councilors by the chairman, the report also found that the chairman of commune councilors gave some tasks to them. By comparison with 2014, the rate of discrimination related in providing some tasks decreased from 16.12% in 2014 to 9.75 in 2015.

Although the rate of discrimination decreased, discriminatory behavior continued to exist. This is necessary to handle with whom were not provided the tasks in accordance with the law on "commune/sangkat administrative management", which is to ensure that all commune/sangkat councilors receive the tasks regarding their position.

**5. The budget for women's and children's affairs**

Some communes don't receive the budget for women's and children's affairs, some are difficulty in to withdrawing it, some receive it late, and some don't receive enough budget for their performance, and budget transparency is still limited.

Budget transparency is still a challenge for women's and children's affairs in some communes/sangkat. There was lack of budget transparency because the budget was hidden some. Some commune/sangkat didn't t announce or inform the public either through message boards, or meetings. For example, there were 4 communes affected in this way. In Sdau commune, New Society district, Preah Vihear province, the clerk controled this budget and the commune councilors don't know how much they have for women's and children's affairs. They is always disagremtns as to how the budget should be spent. In Tboung Kropau commune, Sounthouk district, Kompong Chhang province, the commune councilors do not know how much they have for the women's and children's affair. In Aphivod commune, Teuk Pos district, Kompong Chhang province, the comune councilors also don't know how much they have for the women's and children's affairs, but they just recieved 500$ from UNFPA. For Psar Chhang commune, Kompong chhang district, Kompong Chhang province, it doesn't have a budget for the women's and children's affars.

Among 25 communes, 17 communes found it easy to withdraw the budget for the women's and children's affairs. Ten found it difficult to withdraw because it was late in coming and the clerk doesn't give

the money as per the budget line. 9 communes are difficult to withdraw the budget including Sdau commune (New society district, Preah Vihear province), Tboung Kropau commune (Sonteuk district, Kompong Chhang province), Sangkat Kompong Thom and Oukonthor (Stengseng capital, Kompong Thom province), Taul Sopy and Chork commune (Oureang euy district, Tboung Kmom province), Kraung Ska and Aphivod commune (Teukpos district, Kompong Chhang province), and Kompong Chhang and Psar Chhang commune (Kompong Chhang district, Kompong Chhang province). It was noted that 2 of 25 communes/sangkat gave different answers. For example, in one commune in Kompong Thom district, Stengseng capital, Kompong Thom province, 2 female sangkat councilors from CPP gave different answers, one said it is difficult to withdraw the money and other one said it is easy to withdraw. In Aphivot commune, Teukpos district, Kompong Chhang province, 2 female commune councilors also gave different answers, one from CNRP said it is difficult to withdraw while the one from CPP answer that it is easy to withdraw.

*For more information, please contact:*

1. Mrs. **Sonket Sereyleak**, Education & Gender Coordinator of COMFREL
2. Mr. **Kim Chhorn**, Senior Program Coordinator of COMFREL



**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ **ទី១/ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក **ទី២/ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## អនុសាសន៍របស់ក្រុមអង្គការស្ត្រីនិងបណ្តាញបុរស លើសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីដំណើរការ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បណ្តាញយេនឌ័រនិងអភិវឌ្ឍន៍ បណ្តាញបុរសកម្ពុជា គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងបណ្តុំក្រុមស្ត្រីកម្ពុជា មានការព្រួយបារម្ភចំពោះដំណើរការ និងបញ្ញត្តិនៃសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីដំណើរការ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមិនបានយកចិត្តទុកដាក់លើកកម្ពស់ស្ត្រី ជាពិសេសស្ត្រីវ័យក្មេងក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ និងតួនាទីធ្វើសេចក្តីសម្រេច និងបញ្ហាជនងាយរងគ្រោះដូចជាជនជាតិដើមភាគតិច និងជនមានពិការភាព ដែលជួបប្រទះការលំបាកក្នុងដំណើរការបោះឆ្នោត។ តាមរយៈការប្រជុំពិនិត្យមើលលើសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាមួយអង្គការ និងបណ្តាញដែលយកចិត្តទុកដាក់លើបញ្ហាប្រឈមរបស់ស្ត្រីបានដាក់ចេញនូវអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងច្បាប់នេះ។ ទន្ទឹមនឹងនេះ ក្រុមអង្គការនិងបណ្តាញយើងខ្ញុំបានដាក់ចេញនូវអនុសាសន៍មួយចំនួនទាក់ទងនឹងសេចក្តីព្រាងសេចក្តីស្នើច្បាប់ ស្តីពីដំណើរការ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឲ្យសភាយុវជនគ្រាប់ពិភាក្សា និងអនុម័តនៅថ្ងៃទី០៨ មីនា ឆ្នាំ២០១៥ មុននឹងស្នើឲ្យគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិពិចារណាក្នុងការដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងសេចក្តីស្នើច្បាប់នេះ។ អនុសាសន៍សំខាន់ៗ រួមមានជាអាទិ៍

<u>*សេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ*</u>

១. បញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយនីមួយៗនៅគ្រប់មណ្ឌលត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម។

<u>*សេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីដំណើរការ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*</u>

២. បញ្ចូលស្ត្រីជាពិសេសស្ត្រីវ័យក្មេងឲ្យបានយ៉ាងតិចម្នាក់ក្នុងតួនាទីជាប្រធាន ឬអនុប្រធាន និងយ៉ាងតិច ៣០%ជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត។

៣. ជម្រុញឲ្យមានតំណាងជនជាតិដើមភាគតិច និងជនដែលមានពិការភាពក្នុងសមាជិកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត។

៤. គណៈកម្មការដែលតែងតាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត ត្រូវមានសមាសភាពជាស្ត្រី៣០%យ៉ាងតិច។

៥. បញ្ចូលស្ត្រីជាពិសេសស្ត្រីវ័យក្មេងឲ្យបានយ៉ាងតិចម្នាក់ក្នុងតួនាទីជាអគ្គលេខាធិការ ឬអគ្គលេខាធិការរង និងយ៉ាងតិច៣០%ជាមន្ត្រីបំរើការនៅអគ្គលេខាធិការដ្ឋាន។

៦. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានតួនាទីដូចខាងក្រោម៖

- លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារ សន្តិសុខ និងសណ្តាប់ធ្នាប់ ព្រមទាំងធានាថា ជនដែលជួបការលំបាកដូចជាស្ត្រី ជនជាតិដើមភាគតិច និងជនដែលមានពិការភាពអាចមានភាពងាយស្រួលចូលរួមបោះឆ្នោតក្នុងសម័យបោះឆ្នោត។
- ជំរុញឲ្យគណបក្សនយោបាយនីមួយៗរៀបចំបញ្ជីឈ្មោះបេក្ខភាពឆ្លាស់ប្រុស និងស្រីរបស់បេក្ខជនរបស់ខ្លួន។
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសជនជួបការលំបាកដូចជាស្ត្រី ជនជាតិដើមភាគតិច ជនដែលមានពិការភាព និងយុវជន អំពីការបោះឆ្នោត និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត។
- ជ្រើសរើស និងតែងតាំងមន្ត្រីដែលមានសមាសភាពស្ត្រីយ៉ាងតិច៣០% ចុះជួយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៧. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានឱកាសស្វ័យតសម្រាប់ដំណើរការ និងមានឱកាសសម្រាប់កសាងសមត្ថភាពពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួនរួមទាំងបញ្ហាយេនឌ័រដល់បុគ្គលិកគ្រប់រូប និងដល់ស្ត្រីគ្រប់លំដាប់ថ្នាក់ទាក់ទងនឹងការបំពេញភារកិច្ចរបស់ខ្លួន និងភាពជាអ្នកដឹកនាំ។

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

| | |
|---|---|
| -កញ្ញា សេង ភសី | អ្នកសម្របសម្រួលបណ្តាញ គ.ស.ន និងជាជំនួយការនាយិកាប្រតិបត្តិអង្គការសីលការ 017 93 33 36 |
| -កញ្ញា លឹម សេរីរ័ត្ន | តំណាងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា 012 58 72 42 |
| -លោកស្រី ចាន់ គន្ធា | អ្នកសំរបសំរួលកម្មវិធីថ្នាក់តំបន់នៃអង្គការ Jass SEA 012 85 42 95 |
| -លោក ឆាយ គីមស័រ | អ្នកសម្របសម្រួលបណ្តាញបុរសកម្ពុជា 012 62 78 37 |

## សេចក្តីថ្លែងការណ៍រួម
## នានា សមភាពយេនឌ័រស្ត្រី និងបុរសក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្នុងពេលដែលអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិកំពុងទទួលពាក្យបេក្ខជន និងបេក្ខនារីសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តាងនាមគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បណ្តាញស្ត្រីកម្ពុជា បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ បណ្តាញបុរសកម្ពុជា និងអង្គការសង្គមស៊ីវិលស្ត្រី ដែលធ្វើការលើសិទ្ធិស្ត្រី ស្នើសុំឲ្យមានវិធានការជ្រើសរើសសមាជិក ឲ្យមានសមភាពរវាងបុរស និងស្ត្រី។

ក្រុមការងារស្ត្រី ឃើញថាសមភាពយេនឌ័រ គឺជាវិធានការផ្តល់នូវយុត្តិធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលបានលើកឡើង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនារីរតនៈទី៤ បានទទួលស្គាល់ និងលើកឡើងពីសារៈសំខាន់នៅក្នុងតួនាទីសម្រេចចិត្ត ក្នុងវិស័យនយោបាយ និងមុខងារសាធារណៈ។ ការខ្វះខាតវិធានការពិសេសក្នុងប្រទេសកម្ពុជាកន្លងមក គឺជាឧបសគ្គចំបងរារាំងដល់ការបង្កើនចំនួនស្ត្រី ដែលមានចំនួន៥២% នៃប្រជាពលរដ្ឋកម្ពុជាក្នុងតួនាទីធ្វើសេចក្តីសម្រេច និងមុខងារសាធារណៈ។ ជាមួយគ្នានេះដែរ មាត្រា ៣ នៃអនុសញ្ញាស៊ីដ បានចែងថា "គ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដោយសមភាពជាមួយបុរស"។ បន្ថែមពីលើនេះទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ពិភពលោកក៏បានលើកនូវគោលដៅ សមភាពយេនឌ័រ ៥០%លើ៥០% នៅឆ្នាំ២០៣០។ ទន្ទឹមនឹងនេះ សេចក្តីថ្លែងការណ៍ផែនការសកម្មភាពទីក្រុងប៉េកាំង+២០ អាស៊ីប៉ាស៊ីហ្វិក ក៏បានលើកឡើងនៅក្នុងផ្នែកបុព្វកថា ត្រង់កថាខ័ណ្ឌទី២ "....ការលើកតម្កើងស្ត្រី និងការសម្រេចឲ្យបាននូវសមភាពរវាងស្ត្រី និងបុរសគឺជាបញ្ហាសិទ្ធិមនុស្ស និងជាលក្ខខណ្ឌមួយ នៃយុត្តិធម៌សង្គមដូច្នេះមិនគួរត្រូវបានចាត់ទុកថាត្រឹមតែជាបញ្ហារបស់ស្ត្រីនោះទេ....." បន្ថែមលើនេះទៀត "....ការផ្តល់ ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគឺជាបុរេលក្ខខណ្ឌដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា និងយុត្តិធម៌នៅក្នុងសង្គម..."។

អង្គការសង្គមស៊ីវិល និងបណ្តាញស្ត្រីស្នើដល់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិ និងតំណាងរាស្ត្រនៃគណបក្សទាំងពីរត្រូវធានាឲ្យបានសមភាពរវាងបុរស និងស្ត្រីក្នុង គ.ជ.ប ដោយសូមដាក់ជូននូវអនុសាសន៍ដូចខាងក្រោមនេះ ៖

១. បើប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាស្ត្រី ឬបុរស អនុប្រធានត្រូវតែជាភេទផ្ទុយ។
២.សមាជិក ៤ រូប នៃគ.ជ.ប ដែលជ្រើសរើសដោយគណបក្សនយោបាយនីមួយៗ ត្រូវតែមានស្ត្រីយ៉ាងតិច ១រូប ទៅ២រូប។

អង្គការសង្គមស៊ីវិល និងបណ្តាញស្ត្រីយើងខ្ញុំ ត្រៀមខ្លួនជានិច្ចដើម្បីធ្វើការសហការក្នុងការជំរុញកិច្ចការងារនេះឲ្យបានជោគជ័យ។

ភ្នំពេញ ថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០១៥

ទំនាក់ទំនងព័ត៌មានបន្ថែម៖
-លោកស្រី ធីតា ឃិះ នាយិកាប្រតិបត្តិអង្គការសិលការ និងជាប្រធានគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ០១២ ៨៣៨ ៤៦៤
-លោក ឆាយ គឹមស៊ រ អ្នកសម្របសម្រួលបណ្តាញបុរសកម្ពុជា នៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា ០១២ ៦២៧ ៨៣៧៣.

# គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

Committee to Promote Women in Politics

គណៈកម្មាធិការដឹកនាំ

**ធីដា ឃឹះ**
នាយិកាអង្គការស៊ីលាកា ជាប្រធានគណៈកម្មាធិការដឹកនាំ និងជាអគ្គលេខាធិការនៃ គ.ស.ន

**រស់ សុភាព**
នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា និងជាអនុប្រធានគណៈកម្មាធិការដឹកនាំ នៃ គ.ស.ន

**ថា ស៊ីនដាវ៉ែលាត**
នាយិកាមណ្ឌលព័ត៌មានស្ត្រី ក្នុងនាមជាសមាជិក គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**អង់ ចន្ធា**
នាយកគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា និងជាសមាជិក គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ហង្ស ពុទ្ធា**
នាយកគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជានិងជាសមាជិក គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**មឹម សម្បត្តិ**
នាយកប្រតិបត្តិអង្គការអភិវឌ្ឍន៍ និងការពារសិទ្ធិស្ត្រីកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ថែម ក័ណ្ណារុ**
នាយកប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីអភិវឌ្ឍន៍នៅកម្ពុជា និងជាសមាជិក គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**មីរ៉ាក់ មី ទ័រ**
ទីប្រឹក្សាបច្ចេកទេសនៃ គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ម្រេម ស្នូរ**
ទីប្រឹក្សាបច្ចេកទេសនៃ គណៈកម្មាធិការដឹកនាំនៃ គ.ស.ន

លេខ: ៤០២៣.ស.ល.ក

**សូមគោរពជូន**
**គណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភាជាតិ**

កម្មវត្ថុ: សំណើសុំឲ្យ គណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភាជាតិ ដើម្បីពិគ្រោះយោបល់បន្ថែមទៅលើ នីតិវិធីនៃការជ្រើសរើសតែងតាំងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាឲ្យមានការដាក់បញ្ចូលសមាជិកជាស្ត្រី។

យោងតាមគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចតុកោណ:ទី៤ បានទទួលស្គាល់ និងលើកឡើងពីសារៈសំខាន់របស់ស្ត្រីដែលមានចំនួន៥២% នៃប្រជាពលរដ្ឋកម្ពុជា ក្នុងតួនាទីសម្រេចចិត្ត និងការចូលរួមក្នុងវិស័យនយោបាយ និងមុខងារសាធារណៈ។ គោលនយោបាយទាំងពីរនេះក៏បានលើកឡើងពីការខ្វះខាតវិធានការពិសេសក្នុងប្រទេសកម្ពុជា ជាឧបសគ្គចំបងក្នុងការពន្លឿនដល់ការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច និងមុខងារសាធារណៈ។ ស្របជាមួយគ្នានេះដែរ មាត្រា ៣ នៃអនុសញ្ញាស៊ីដ បានចែងថា "គ្រប់ វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដោយសមភាពជាមួយបុរស" និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ពិភពលោកក៏បានកំណត់ថានឹងសម្រេចឲ្យបាន សមភាពយេនឌ័រ ៥០%:៥០% នៅឆ្នាំ២០៣០។ សេចក្តីថ្លែងការណ៍ផែនការសកម្មភាពទីក្រុងប៉េកាំង+២០ អាស៊ីប៉ាស៊ីហ្វិកក៏បានលើកឡើងនៅក្នុងផ្នែកបុព្វកថា ត្រង់កថាខណ្ឌទី២ "...ការលើកកម្ពស់ស្ត្រី និងការសម្រេចឱ្យបាននូវសមភាពរវាងស្ត្រីនិងបុរសគឺជាបញ្ហាសិទ្ធិមនុស្ស និងជាលក្ខខណ្ឌមួយ នៃយុត្តិធម៌សង្គមដូច្នេះមិនគួរត្រូវបានចាត់ទុកថាត្រឹមតែជាបញ្ហារបស់ស្ត្រីនោះទេ...." បន្ថែមលើនេះទៀត "...ការផ្តល់ ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគឺជាមធ្យោបាយល្អដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា និងយុត្តិធម៌នៅក្នុងសង្គម...."។

យោងលើមូលដ្ឋានថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោកក្នុងការលើកកម្ពស់ ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ បណ្តាញអង្គការសង្គមស៊ីវិលស្ត្រី មានជំនឿយ៉ាងមុតមាំថា គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិ នឹងពិនិត្យ លើនីតិវិធីនៃការជ្រើសរើសតែងតាំងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអនុញ្ញាតិឲ្យក្រុមការងារយើងខ្ញុំបានចូលជួបពិគ្រោះនៅ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៥ ពេលវេលាអាស្រ័យតាមការកំណត់របស់គណៈកម្មាធិការ។

សូម គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិ ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៥

ធីដា ឃឹះ

នាយិកាប្រតិបត្តិនៃអង្គការស៊ីលាកា និងជាប្រធានគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងនាំមុខបណ្តាញស្ត្រីដើម្បីទាំងអស់គ្នា

ភ្ជាប់មកជាមួយ: សេចក្តីថ្លែងការណ៍រួមស្តីពីអនុសាសន៍របស់ក្រុមអង្គការសង្គមស៊ីវិលស្ត្រី និងបណ្តាញស្ត្រី លើការជ្រើសរើសតែងតាំងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ចំលងជូន: ១.គណបក្សប្រជាជនកម្ពុជា
២.គណបក្សសង្គ្រោះជាតិ
សូមទំនាក់ទំនង: កញ្ញា ឈេង ភារី
មន្ត្រីសម្របសម្រួលគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ
លេខទូរស័ព្ទ: ០១៧ ៥០៣ ៣៣៦

ទីស្នាក់ការ គ.ស.ន ការិយាល័យ SILAKA ... ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥ ២៣) ... P.O.Box ...
អ៊ីម៉ែល: info@cpwp.net គេហទំព័រ: www.cpwp.net

# គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

Committee to Promote Women in Politics

គណៈកម្មាធិការដឹកនាំ

**ធីដា ខឹះ**
នាយិកាអង្គការស៊ីលាកា ជាប្រធានគណៈកម្មាធិការដឹកនាំ និងជាអ្នកលេខាធិការនៃ គ.ស.ន

**រស់ សុភាព**
នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា និងជាអនុប្រធានគណៈកម្មាធិការដឹកនាំ នៃ គ.ស.ន

**ជា ស៊ីនដារ៉ែណាត**
នាយិកា មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា និងជា សមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**គល់ បញ្ញា**
នាយកគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ហាង្ស ពុទ្ធា**
នាយកគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ទឹម សម្បត្តិ**
នាយកប្រតិបត្តិអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ថេប ច័ន្ទណារុ**
នាយកប្រតិបត្តិអង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**មីរ៉ាត់ មី ស៊ា**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ព្រុម ស្តុរ**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

## <u>លិខិតផ្សព្វផ្សាយសារព័ត៌មាន</u>

**អបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ជាមួយការរាំរបាំត្រុដិ**
**និងនាំយកសេចក្ដីថ្លែងការណ៍រួមរបស់ស្ត្រី**
**ក្រោមប្រធានបទ "ធានាសមភាពយេនឌ័រនៅក្នុង គ.ជ.ប"**
**ភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥**

គណៈកម្មាធិការលើកស្ទួយលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គ.ស.ន) រួមជាមួយក្រុមស្ត្រី មកពីបណ្ដាអង្គការនានា ដែលធ្វើការលើកកម្ពស់សិទ្ធិស្ត្រីនឹងប្រារព្ធពិធីអបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ជាមួយការរាំរបាំត្រុដិនិងនាំយកសេចក្ដីថ្លែងការណ៍រួមរបស់ស្ត្រីទៅកាន់រដ្ឋសភាជាតិ គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ក្រោមប្រធានបទ "ធានាសមភាពយេនឌ័រនៅក្នុង គ.ជ.ប"។

យុទ្ធនាការនេះធ្វើឡើងស្របពេលដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា និង គណបក្សនយោបាយទាំងពីរកំពុងជ្រើសរើសសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត។

**កាលបរិច្ឆេក និងទីតាំង៖**

- **កាលបរិច្ឆេក៖** ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥
- **ពេលវេលា៖** ម៉ោង ៧:៣០ នាទីព្រឹក
- **ទីកន្លែង៖** នៅមុខរដ្ឋសភាជាតិ

សន្និសិទសារព័ត៌មាននឹងប្រព្រឹត្តទៅ បន្ទាប់ពីបញ្ចប់ការដាក់សេចក្ដីថ្លែងការណ៍នៅគណបក្សសង្គ្រោះជាតិ។

យើងខ្ញុំសង្ឃឹមថា លោក/លោកស្រី នឹងចំនាយពេលវេលាដ៏មានតំលៃរបស់លោកអ្នកក្នុងការចូលរួមយកព័ត៌មានក្នុងយុទ្ធនាការនេះ។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**
ឈ្មោះ៖ កញ្ញា សេង រាសី
អ្នកសម្របសម្រួលនៃ គ.ស.ន
ទូរស័ព្ទលេខ: ០១២ ៧៦៥ ៦៤៣
អ៊ីម៉ែល: reaseys@silaka.org

[illegible] SILAKA [illegible]
ទូរស័ព្ទ: [illegible] P.O.Box [illegible]
[illegible] www.cpwp.net

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## អនុសាសន៍របស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ លើបទបញ្ញា និង នីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ បណ្តាញបុរសកម្ពុជា បណ្តុំស្ត្រីកម្ពុជា អង្គការ និងបណ្តាញសង្គមស៊ីវិល ដែលធ្វើការផ្ទាល់នៅតាមសហគមន៍ សង្កេតឃើញថា វិសមភាពយេនឌ័រនៅមានកំរិត ធ្វើឲ្យការចូលរួមរបស់ស្ត្រី និងបុរសនៅពុំទាន់ស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត។ យោងទៅលើបេសកកម្មរបស់ គ.ជ.ប ដែល "ធានាឲ្យមានការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស" ហេតុដូច្នេះហើយ ក្រុមការងារយើងខ្ញុំបានជួបប្រជុំពិភាក្សាចំនួនពីរដង ដោយលើកទី១នៅថ្ងៃទី ២៦ ខែមិថុនា និងលើកទី២នៅថ្ងៃទី ២០ ខែកក្កដា ដើម្បីលើកជាមតិយោបល់ ក្នុងការកែសម្រួល និងបំពេញបន្ថែមលើ សេចក្តីព្រាងនៃ បទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៥នេះ។ ការលើកឡើងជាអនុសាសន៍នេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីឲ្យប្រជាពលរដ្ឋកម្ពុជា ទាំងស្ត្រី និងបុរស មានឱកាសស្មើគ្នា ប្រកបដោយសមធម៌ ក្នុងដំណើរការចូលរួមចុះឈ្មោះបោះឆ្នោត។

យើងខ្ញុំសូមដាក់ជូននូវអនុសាសន៍សំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

១.សំណូមពរចាត់តាំងគណៈកម្មការចំពោះកិច្ចយេនឌ័រ ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោតដើម្បីធានាឲ្យដំណើរការនៃការចុះឈ្មោះបោះឆ្នោតផ្តល់ឱកាសអោយស្មើភាពចំពោះ ស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។

២. គណកម្មការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោតត្រូវមានយ៉ាងតិចស្ត្រីមួយរូប។

៣. ក្រុមការងារចុះឈ្មោះបោះឆ្នោតត្រូវមានយ៉ាងតិចស្ត្រីមួយរូប ទៅពីររូប។

៤. គ្រប់តួនាទីដែលត្រូវជ្រើសរើសត្រូវតែផ្សព្វផ្សាយឲ្យបានទូលំទូលាយក្នុងរយៈពេល១០ (ដប់) ថ្ងៃ យ៉ាងតិចនៃថ្ងៃធ្វើការ។ ករណីគ្មានបេក្ខនារីដាក់ពាក្យអំឡុងពេលខាងលើត្រូវពន្យាពេល ៥ថ្ងៃ នៃថ្ងៃធ្វើការបន្ថែមទៀត។

៥. រាល់ការផ្សព្វផ្សាយជ្រើសរើស ស្ត្រី ជនពិការ និងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្តឲ្យចូលរួម។

៦. រាល់ក្រុមសង្កេតការណ៍ លើការងារបោះឆ្នោត ទាំងសង្គមស៊ីវិល និងគណបក្សនយោបាយ ត្រូវតែមានស្ត្រីចូលរួមចំនួន ៥០%

៧. ស្នើសុំឲ្យរយៈពេលនៃការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ មេសា រហូតដល់ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៦។

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

- *កញ្ញា សេង រាសី មន្ត្រីសម្របសម្រួលនៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ០១៧ ៩៣៣ ៣៣៦*
- *លោកស្រី ស៊ីនកេត ស៊ីរីលក្ខណ៍ មន្ត្រីសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមព្រែល ០១៧ ៤៩៤ ០០៤*

# សេចក្តីថ្លែងការណ៍

## វិសោធនកម្មច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែមានវិធានការចាំបាច់សំរាប់លើកកម្ពស់ការអភិវឌ្ឍដែលមានចីរភាព និងប្រសិទ្ធិភាព

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយរួមជាមួយ បណ្តាញស្ត្រីដើម្បីទាំងអស់គ្នា បណ្តុំស្ត្រីកម្ពុជា អង្គការតំបន់ JassSEA បណ្តាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេងនៅកម្ពុជា សកម្មជនស្ត្រីវ័យក្មេងលើកិច្ចការអាស៊ាន និងបណ្តាញសង្គមស៊ីវិលធ្វើការផ្ទាល់នៅតាមសហគមន៍ មិនទទួលយកវិសមភាពយេនឌ័រនៅតាមមូលដ្ឋានទៀតទេ ដោយយើងសង្កេតឃើញថាការចូលរួមរបស់ស្ត្រី និងបុរសនៅពុំទាន់ស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត ដែលជាលទ្ធផលធ្វើឲ្យកម្ពុជាពុំសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងធ្វើឲ្យសេវាមូលដ្ឋានពុំបានទៅដល់ស្ត្រី ដែលជាប្រជាពលរដ្ឋភាគច្រើននៃប្រទេស ដោយការសម្រេចចិត្តទៅលើការវិនិយោគនានានៅមូលដ្ឋាននៅមានកម្រិត និងប៉ះពាល់ដល់ធ្ងន់ធ្ងរទៅដល់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

ស្របពេលដែលគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គ្រោងនឹងពិភាក្សាអំពី ការធ្វើវិសោធនកម្មច្បាប់ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅថ្ងៃពុធ ទី ២៣ ខែកញ្ញា ឆ្នាំ២០១៥ ខាងមុខនេះ ក្រុមការងារយើងខ្ញុំសូមស្នើអនុសាសន៍មួយចំនួន ក្នុងការកែសម្រួល និងបំពេញបន្ថែមលើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោមនេះ៖

១. ជំពូកទី ៧ មាត្រា៤៩ថ្មី បញ្ជីបេក្ខជន បេក្ខនារី នៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរស ពីលើដល់ក្រោម ៥០/៥០។
២. ជំពូក ១២ មាត្រា ១២ថ្មី សមាសភាពគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោត ត្រូវមានស្ត្រីយ៉ាងហោច ១រូប រវាងប្រធាន និងអនុប្រធាន ចំពោះសមាជិក ត្រូវមានស្ត្រី៥០%។
៣. ជំពូក ៩ មាត្រា ៨៩ថ្មី គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងរបស់ខ្លួន ដែលត្រូវមានស្ត្រី ៥០% និង មាត្រា ៩៨ថ្មី អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលបានចុះឈ្មោះសង្កេតការណ៍ត្រូវមានស្ត្រី ៥០%។

*ចំលងជូន៖*

ភ្នំពេញ, ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥

- *រដ្ឋសភាជាតិ*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *សារព័ត៌មាន*

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**

_ *កញ្ញា សេង រាសី មន្ត្រីសម្របសម្រួលគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ០១៧ ៩៣៣ ៣៣៦*

- *លោកស្រី ស៊ីនកេត ស៊ីរីកេសុណ៍ មន្ត្រីសម្របសម្រួលផ្នែក អប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល ០១៧ ៤៩៤ ០០៤*

# គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

## Committee to Promote Women in Politics

គណៈកម្មាធិការដឹកនាំ

**ធីដា ឃឹះ**
នាយិកាអង្គការស៊ីលាការ ជាប្រធានគណៈកម្មាធិការដឹកនាំ និងជាអគ្គលេខាធិការនៃ គ.ស.ន

**ម៉ម សុខចិន្ត្រា**
នាយកប្រតិបត្តិអង្គការអភិវឌ្ឍន៍ និងការពារសិទ្ធកុមារ និងជាអនុប្រធានគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**រស់ សុភាព**
នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ សម្រាប់កម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំ នៃ គ.ស.ន

**ជា ស៊ីនជាណែត**
នាយិកា មជ្ឈមណ្ឌលកិច្ចការស្ត្រីកម្ពុជា និងជា សមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**គល់ បញ្ញា**
នាយកគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**សំ គន្ធាមី**
នាយកស្តីទីគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ទិតយ ពន្លឺធារ៉ា**
នាយកប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីអភិវឌ្ឍន៍នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ម៉ារ៉ាត់ មី ម៉ា**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ព្រេម ស្ទុរ**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

លេខៈ ៨៨.១២៦៩

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

កម្មវត្ថុៈ សំណើសុំឲ្យ សម្តេច ពិនិត្យ និងពិចារណាចំពោះអនុសាសន៍ របស់ក្រុមអង្គការសង្គមស៊ីវិលស្ត្រីលើវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(គ.ស.ន) បណ្តាញស្ត្រីដើម្បីទាំងអស់ បណ្តុំស្ត្រីកម្ពុជា អង្គការតំបន់រតនះ បណ្តាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេងនៅកម្ពុជា សកម្មជនស្ត្រីវ័យក្មេងលើកិច្ចការអាស៊ាន និងបណ្តាញសង្គមស៊ីវិល ដែលធ្វើការងារទូលំទូលាយនៅតាមសហគមន៍សង្កេតឃើញថាវិសមភាពយេនឌ័រនៅមានកំរិតធ្វើឲ្យការចូលរួមរបស់ស្ត្រី និងបុរសនៅពុំទាន់ស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត ជាលទ្ធផលស្ត្រីជាប់ឆ្នោតនៅថ្នាក់មូលដ្ឋាននៅមានកម្រិតទាប ឧទាហរណ៍ ថ្នាក់ឃុំ សង្កាត់ មានតែ ១៧.៧៨% នៅឆ្នាំ២០១២, ថ្នាក់ខេត្ត និងស្រុក មានតែ ១២.១៣%នៅឆ្នាំ២០១៤។ លទ្ធផលនេះនៅមានកម្រិតតិចតួចដែលធ្វើឲ្យកម្ពុជាពុំសម្រេចបានគោលដៅសហស្សវត្ស ដែលប៉ះពាល់ដល់ការសម្រេចបាន ទៅលើផែនការវិនិយោគ និងការផ្តល់សេវាដល់ស្ត្រីកម្ពុជាដែលមានដល់ទៅ ៥១%នៃប្រជាពលរដ្ឋសរុប។

ស្របពេលដែលគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គ្រោងនឹងពិភាក្សាអំពីការធ្វើវិសោធនកម្មច្បាប់ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅថ្ងៃពុធ ទី ២៣ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមការងារយើងខ្ញុំបានលើកអនុសាសន៍ ក្នុងការកែសម្រួល និងបំពេញបន្ថែមលើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឲ្យស្ត្រី និងបុរសមានភាពស្មើគ្នាក្នុងដំណើរការបោះឆ្នោត។

អាស្រ័យហេតុដូចនេះ បណ្តាញអង្គការសង្គមស៊ីវិលស្ត្រីមានជំនឿយ៉ាងមុតមាំថា សម្តេច និងពិចារណានូវអនុសាសន៍ (ដែលភ្ជាប់មកជាមួយ) របស់បណ្តាញអង្គការសង្គមស៊ីវិលស្ត្រីពាក់ព័ន្ធនឹងការដាក់បញ្ចូលស្ត្រីនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ សង្កាត់ របស់គណបក្សនយោបាយ និងគួរតែធ្វើសេចក្តីសម្រេចចិត្ត តាមការគួរ។

សូម សម្តេច ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥

ប្រធាន

នាយិកាអង្គការស៊ីលាការ

ធីដា ឃឹះ ប្រធាន គ.ស.ន

លេខាធិការដ្ឋាន គ.ស.ន ការិយាល័យ ស៊ីលាការ ផ្ទះលេខ 558, 556 ផ្លូវ 380 សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855-23) 766 843, (855-23) 217 872, 210 505 P.O Box 821
អ៊ីម៉ែល: cpwp@camintel.com គេហទំព័រ: www.cpwp.net

# គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

## Committee to Promote Women in Politics

គណៈកម្មាធិការដឹកនាំ

**ធីដា ឃឹះ**
នាយិកាអង្គការសិលាការ ជាប្រធានគណៈកម្មាធិការដឹកនាំ និងជាអគ្គលេខាធិការនៃ គ.ស.ន

**ម៉ម សម្បត្តិ**
នាយកប្រតិបត្តិអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព និងជាអនុប្រធានគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ខេង សុខតារា**
នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំ នៃ គ.ស.ន

**ជា ស៊ុនដាណែត**
នាយិកា បណ្ដាញអាជីវកម្មស្ត្រីកម្ពុជា និងជា សមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**គល់ បញ្ញា**
នាយកគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**សំ គុន្ធាមី**
នាយកគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**កែម ម័ណ្ណារិទ្ធ**
នាយកប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីអភិវឌ្ឍន៍នៅកម្ពុជា និងជាសមាជិកគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ម៉ារ៉ាក់ ម៉ី ស៊ា**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

**ខ្មែម ស្ថុន**
ទីប្រឹក្សាបច្ចេកទេស នៃគណៈកម្មាធិការដឹកនាំនៃ គ.ស.ន

លេខៈ ៥.១៦.១៧

**សូមគោរពជូន**
**ឯកឧត្តម សម រង្ស៊ី**
**ប្រធានគណបក្សសង្គ្រោះជាតិ**

កម្មវត្ថុៈ សំណើសុំឲ្យ ឯកឧត្តម ពិនិត្យ និងពិចារណាចំពោះអនុសាសន៍ របស់ក្រុមអង្គការសង្គមស៊ីវិលស្ត្រីលើ
វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គ.ស.ន) បណ្ដាញស្ត្រីដើម្បីទាំងអស់ បណ្ដុំស្ត្រីកម្ពុជា អង្គការតំបន់JassSEA បណ្ដាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេងនៅកម្ពុជា សកម្មជនស្ត្រីវ័យក្មេងលើកិច្ចការអាស៊ាន និងបណ្ដាញសង្គមស៊ីវិល ដែលធ្វើការផ្ទាល់នៅតាមសហគមន៍សង្កេតឃើញថាវិសមភាពយេនឌ័រនៅមានក៏វិតធ្វើឲ្យការចូលរួមរបស់ស្ត្រី និងបុរសនៅពុំទាន់ស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត ជាលទ្ធផលស្ត្រីជាប់ឆ្នោតនៅថ្នាក់មូលដ្ឋាននៅមានកម្រិតទាប ឧទាហរណ៍ ថ្នាក់ឃុំ សង្កាត់ មានតែ ១៧,៧៦% នៅឆ្នាំ២០១២, ថ្នាក់ខេត្ត និងស្រុក មានតែ ១២.១៣%នៅឆ្នាំ២០១៤។ លទ្ធផលនេះនៅមានកម្រិតតិចតួចដែលធ្វើឲ្យកម្ពុជាពុំសម្រេចបានគោលដៅសហស្សវត្សរ៍ ដែលប៉ះពាល់ដល់ការសម្រេចបាន ទោះលើផែនការវិនិយោគ និងការផ្ដល់សេវាដល់ស្ត្រីកម្ពុជាដែលមានដល់ទៅ ៥២%នៃប្រជាពលរដ្ឋសរុប។

ស្របពេលដែលគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គ្រោងនឹងពិភាក្សាអំពីការធ្វើវិសោធនកម្មច្បាប់ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅថ្ងៃពុធ ទី ២៣ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមការងារយើងខ្ញុំបានលើកជាអនុសាសន៍ ក្នុងការកែសម្រួល និងបំពេញបន្ថែមលើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឲ្យស្ត្រី និងបុរសមានភាពស្មើគ្នាក្នុងដំណើរការបោះឆ្នោត។

អាស្រ័យហេតុដូចនេះ បណ្ដាញអង្គការសង្គមស៊ីវិលស្ត្រីមានជំនឿយ៉ាងមុតមាំថា **ឯកឧត្តម** និងពិចារណានូវអនុសាសន៍ (ដែលមានភ្ជាប់មកជាមួយ) របស់បណ្ដាញអង្គការសង្គមស៊ីវិលស្ត្រីពាក់ព័ន្ធនឹងការដាក់បញ្ចូលស្ត្រីនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ សង្កាត់ របស់គណបក្សនយោបាយ និងធ្វើសេចក្ដីសម្រេចចិត្ត តាមការគួរ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ភ្នំពេញថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥

ធីដា ឃឹះ

នាយិកាប្រតិបត្តិអង្គការសិលាការ
និងជាប្រធាន គ.ស.ន

ចម្លងជូន៖
- សម្ដេចនាយករដ្ឋមន្ត្រី
- អនុសាសន៍
- ឯកសារ
- កាលប្បវត្តិ

អាសយដ្ឋាន គ.ស.ន ... ភ្នំពេញ
ទូរស័ព្ទ: (855-12) 765 643, (855-23) 217 872, 216 902 P.O Box 821
អ៊ីម៉ែល: cpwp@cpwp.net , គេហទំព័រ: www.cpwp.net

# អនុសាសន៍គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

## ស្តីពី

## វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

| ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | អនុសាសន៍ |
|---|---|
| **ជំពូកទី២<br>ការគ្រប់គ្រងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** | |
| **មាត្រា ១២ ថ្មី**<br><br>សមាសភាពគណៈកម្មាខេត្តក្រុងរៀបចំការបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ និងសមាជិកពី ៣(បី) ទៅ៥(ប្រាំ)នាក់។<br><br>សមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ និងសមាជិក៣(បី)នាក់។<br><br>គណៈកម្មការការិយាល័យបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ លេខាធិការម្នាក់ និងដែលមានសមាជិកពី២(ពីរ)នាក់ ទៅ៤(បួន)នាក់ អាស្រ័យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអ្នកកំណត់សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ។<br><br>សមាជិកគ្រប់រូបរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គឺជាមន្ត្រីបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបង្កើត និងចាត់តាំងលេខាធិការដ្ឋានមួយជាជំនួយការឲ្យគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។ | **មាត្រា ១២ ថ្មី (ស្នើកែប្រែ)**<br><br>សមាសភាពគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ និងសមាជិកពី ៣(បី) ទៅ៥(ប្រាំ)នាក់។<br><br>សមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតរួមមាន ប្រធាន ម្នាក់ អនុប្រធានម្នាក់ និងសមាជិក៣(បី)នាក់។<br><br>គណៈកម្មការការិយាល័យបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ លេខាធិការម្នាក់ និងដែលមានសមាជិកពី២(ពីរ)នាក់ ទៅ៤(បួន)នាក់ អាស្រ័យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអ្នកកំណត់សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ។<br><br>សមាជិកគ្រប់រូបរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គឺជាមន្ត្រីបោះឆ្នោត <u>ដែលក្នុងនោះត្រូវមានយ៉ាងតិចស្ត្រី ០១(មួយ)រូប</u>។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបង្កើត និងចាត់តាំងលេខាធិការដ្ឋានមួយជាជំនួយការឲ្យគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត<u>ដែលត្រូវមានស្ត្រី ៥០%</u>។ |
| **ជំពូកទី ៧<br>ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** | |
| **មាត្រា ៤៩ ថ្មី (មាត្រា ៥៨ ចាស់)**<br><br>ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ។<br><br>បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែកក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។<br>បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង។ | **មាត្រា ៤៩ ថ្មី (មាត្រា ៥៨ ចាស់) (ស្នើកែប្រែ)**<br><br>ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ។<br><br>បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែកក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។<br>បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង<u>ដែលត្រូវមានស្ត្រី ៥០% និងត្រូវរៀបតាមលំដាប់</u> |

| | |
|---|---|
| | <u>ផ្លាស់ពីលើចុះមកក្រោម ។</u> |
| **មាត្រា ៥២ ថ្មី (មាត្រា ១០១ ចាស់កែប្រែ)**<br><br>ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយៈ<br>- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់<br>- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន<br>- បញ្ជីរាយនាមបេក្ខជន ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាក្នុងក្រុមប្រឹក្សាឃុំ សង្កាត់<br>- នាមត្រកូល នីមនាមខ្លួន អាសយដ្ឋាន លិខិតបញ្ជាក់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។<br>- ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ និងរូបថតបេក្ខជនម្នាក់ៗចំនួន៣សន្លឹក ទំហំ៤ x ៦ ថតចំពីមុខតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។ | **មាត្រា ៥២ ថ្មី (មាត្រា ១០១ ចាស់កែប្រែ) (ស្នើកែប្រែ)**<br><br>ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយៈ<br>- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់<br>- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន<br>- បញ្ជីរាយនាមបេក្ខជន ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ <u>និងមានចំនួនស្ត្រី ៥០%នៅក្នុងបញ្ជី។</u><br>- នាមត្រកូល នីមនាមខ្លួន អាសយដ្ឋាន លិខិតបញ្ជាក់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។<br>- ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ និងរូបថតបេក្ខជនម្នាក់ៗចំនួន៣សន្លឹក ទំហំ៤ x ៦ ថតចំពីមុខតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។ |
| **មាត្រា ៥៣ ថ្មី (មាត្រា ១០២ ចាស់)**<br><br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ។<br><br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជន នៅគ្រប់ទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។<br><br>ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣(បី)ថ្ងៃ។<br><br>គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃទទួលពាក្យឲ្យគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជីមួយច្បាប់ទុកជាឯកសារ។<br><br>បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល។ | **មាត្រា ៥២ ថ្មី (មាត្រា ១០១ ចាស់) (ស្នើកែប្រែ)**<br><br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ។<br><br>គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជន នៅគ្រប់ទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។<br><br>ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣(បី)ថ្ងៃ។<br><br>គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃទទួលពាក្យឲ្យគណបក្សនយោបាយណាដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន <u>ដែលមានស្ត្រីក្នុងបញ្ជី ៥០% និងមានលេខរៀងឆ្លាស់រវាងបេក្ខនារី និងបេក្ខជន</u> ហើយរក្សាគល់បញ្ជីមួយច្បាប់ទុកជាឯកសារ។<br><br>បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល។ |
| **ជំពូកទី ៩** | |

| ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ | |
|---|---|
| **មាត្រា ៨៩ ថ្មី (មាត្រា ១៤១ ចាស់កែប្រែ)**<br>គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងរបស់ខ្លួនមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជន តាមលំក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា៧៥ថ្មីនៃច្បាប់នេះ។<br>ពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ។ | **មាត្រា ៨៩ ថ្មី (មាត្រា ១៤១ ចាស់កែប្រែ) (ស្នើកែប្រែ)**<br>គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារ និងភ្នាក់ងារបម្រុងរបស់ខ្លួន ដែលមានស្ត្រី ៥០% មកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជន តាមលំក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា៧៥ថ្មីនៃច្បាប់នេះ។<br>ពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ។ |
| **មាត្រា ៩៨ថ្មី (មាត្រា ១៥០ ចាស់កែប្រែ)**<br>សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅតាមពេលវេលា និងបទបញ្ញា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ | **មាត្រា ៩៨ថ្មី (មាត្រា ១៥០ ចាស់កែប្រែ) (ស្នើកែប្រែ)**<br>សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលមានស្ត្រី ៥០% ក្នុងបញ្ជីអ្នកសង្កេតការណ៍ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅតាមពេលវេលា និងបទបញ្ញា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ |

5

ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១៥

**ឧបត្ថម្ភដោយ ៖**

Activity supported by the
Canada Fund for Local Initiatives

Activité réalisée avec l'appui du
Fonds canadien d'initiatives locales

Canada

NORWEGIAN PEOPLE'S AID

diakonia
PEOPLE CHANGING THE WORLD

Oxfam

OPEN SOCIETY
FOUNDATIONS